សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អ

KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

មាតិការរឿង Issue 179 June 29th. to July 13th. 2015

Free

១-គោលដៅលំហែកាយថ្មី............................០២
២-វត្តសុរិយារង្សីមានដំណោះស្រាយ.................០៣
៣-ផ្សេវបាល់ទាត់កុមារបានត្រូវបញ្ចប់.................០៤
៤-ផ្លូវថ្មើរជើងថ្មីៗទៀតនៅឡូវែល......................០៥
៥-រដ្ឋាភិបាលខ្មែរក្រោមក្នុងដំណើរទៅរក................០៨
៦-បាតុកម្មខ្មែរ-ឡាវនៅសេដ្ឋវិមាន......................១២
៧-លោក ប៉ាន សូ ឈរឈ្មោះជាបេក្ខជន.............២០
៨-អំពីអត្ថន័យនៃការស្បថ...............................២៤

**Office:** Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

# វិបត្តិនយោបាយនៅព្រះរាជាណាចក្រកម្ពុជា

**លិម គិមយ៉ា**
**តំណាងរាស្ត្រមណ្ឌលកំពង់ធំ**

បញ្ហាព្រំដែនកម្ពុជា-វៀតណាមបានក្លាយជាចំណុចដ៏តានតឹងជាថ្មីទៀត ក្រោយពីរកឃើញថា វៀតណាមបានព្យាយាមរំលោភលើបូរណភាពទឹកដីកម្ពុជា តាមរយៈរូបភាពផ្សេងៗ ។ ស្ថានការណ៍ចុងក្រោយនេះ រដ្ឋាភិបាលកម្ពុជាបានផ្លាស់ប្ដូរជំហររបស់ខ្លួនដោយបានចេញកំណត់ទូតដ៏កម្ររឿងព្រំដែននេះប្រឆាំងសកម្មភាពរបស់វៀតណាម ។

បញ្ហាអស់នេះ រាជរដ្ឋាភិបាលដឹកនាំដោយលោក ហ៊ុន សែន មិនដែលលើកយកមកនិយាយជាសាធារណៈនោះទេ បើតាមដឹងគឺគ្មានប្រតិកម្មអ្វីទាំងអស់គង់តែមានការតវ៉ាជាច្រើនដង និងមានចុះទៅពិនិត្យមើលនៅតំបន់ព្រំប្រទល់ដែនពីសំណាក់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ និងប្រជាពលរដ្ឋយ៉ាងណាក៏ដោយ ។ ខ្ញុំក៏បានចុះទៅជាច្រើនដងនៅខេត្តកំពង់ចាមនៅតំបន់ភូមិមេមត់ និងផ្ទះលោកប្រធានហេង សរិន ដោយខ្ញុំសង្កេតឃើញ "កងកំលាំងខ្មែរដែលយាមតាមព្រំប្រទល់ដែន ដូចជាគោរពបញ្ជាពីទាហ៊ានយួន"ឱ្យធ្វើទុក្ខបុកម្នេញប្រជាពលរដ្ឋខ្មែរដែលរស់នៅតាមព្រំប្រទល់ដែន ព្រមទាំងបិទភ្នែកចំពោះទាហ៊ានយួន ចូលមករំលោភលើបូរណភាពទឹកដីកម្ពុជា និងលើប្រជាពលរដ្ឋខ្មែរ ដូចជាជីកស្រះ ធ្វើថ្នល់ ធ្វើអាគារ ដកដំណាំ និងបាញ់ថ្នាំសំលាប់ដំណាំផ្សេងៗ ។ល។ បើប្រសិនណាជាកងកំលាំងខ្មែរណាមួយហ៊ានប្រឆាំង និង **តទៅទំព័រទី ១៨**


លឹម គិមយ៉ា

# ពិធីសច្ចាប្រណិធានរបស់សមាជិកថ្មី គណកម្មការអេស៊ាន-អាមេរិកាំង

## Swearing in Ceremony for Newly appointed Asian American Commissioners

**Boston Friday , June 26, 2015**

-ស្ត្រីពីររូប ២នាក់ទៅពីឡូវែល នឹងម្នាក់ពីបូស្តុន គឺ លា្យណា គូស៊ី - សូហ្វី ធីម - នឹង បណ្ឌិត ម៉ាបេល ឡាំ បានធ្វើសច្ចាប្រណិធានចូលកាន់ដំណែងជាសមាជិកថ្មីនៃគណកម្មការអេស៊ានអាមេរិកាំង មានទីតាំងនៅបូស្តុន នៅចំពោះមុខ ស៊ូហា្សន បំ ជាអ្នកជំរះបញ្ជីនឹង ដេបូរ៉ា បឺ ។ ហ្គោលប៊ី ជា អគ្គាហិរញ្ញិក ។

***BOSTON Friday, June 26, 2015***

Massachusetts State House Speaker Robert Deleo has appointed Ms. LiannaKushi and Ms. SophyTheam, both of Lowell to the Massachusetts Asian American Commissionand appointed Ms. Mabel Lam of Cambridge, MA. The Swearing-in Ceremony by the State Auditor Suzanne Bump.

The Asian American Commission (AAC) for the Commonwealth of Massachusetts was created by legislation on October 29, 2006. This commission recognizes **Continued to Page 12**


ស៊ូហា្សន បំ-ដេប ហ្គោលប៊ឺ-លា្យណា គូស៊ី-ម៉ាបែល ឡាំ នឹង សូហ្វី ធីម

REMEDIUM PHARMACY
ឳសថស្ថានរ៉ឹមីឌៀម
2 Vinal Square. North Chelmsford, MA 01863
ជាឳសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
- ផ្ទេរឬផ្លាស់ប្ដូរសេវាកម្ម
- ការលាយផ្សំឱសថ
- ជួយធ្វើសំបុត្រទិញថ្នាំ
- ការវេចខ្ចប់ឱសថ
- បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ
- ផ្លាស់ប្ដូរយោបល់ដោយរាក់ទាក់
ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ
FREE daily delivery | Bliterpack Packaging | Compounding Medication
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071

ការិយាល័យច្បាប់
រ៉ូសា និង តាំង


Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា


Andrew 'Bunna' Taing, Esq.
មេធាវី អែន ទ្រីវប៊ុណ្ណា តាំង

Law Office of
Rosa & Taing
ATTORNEY AT LAW

SERVICES
- Auto Accidents/ Personal Injury
- Bankruptcy
- Immigration
- Consumer Protection
- Real Estate Closings/Disputes
- Divorces Child Custody

តំណាងក្ដីដូចខាងក្រោម
- គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
- ក្ស័យធន
- អន្តោប្រវេសន៍
- ការពារអតិថិជន
- ទំនាស់ផ្នែកអចលនវត្ថុ
- លែងលះ និងអាណាព្យាបាលកិច្ច

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | help@attorneyrosa.com
www.attorneyrosa.com

# គោលដៅលំហែរកាយថ្មី នៃឆ្នេរសមុទ្រមើធីល ( ភាគ៣ )

## Destination Myrtle Beach in South Carolina (Part 3)







នៅសារមន្ទីរខាងរុក្ខជាតិ

**ដោយ សូបិន ពិន** **តពីលេខមុន**

មកដល់គោលដៅនៅក្នុងដំណើរ២ម៉ោងកន្លះពីទិសខាងត្បូងនៃ មើធីលប៊ិច... ហើយដើម្បីឱ្យយល់ពីតំបន់ ឆាឡេស្តុន ដ៏ល្បីល្បាញបានច្បាស់លាស់យើងត្រូវទិញសំបុត្រចូលទស្សនាឧទ្យានទាំងមូលដែលគេបានរក្សាតំបន់ទាំងមូលទំហំរាប់ពាន់អេ គឺឥតជាសារមន្ទីរឈ្មោះ "ម៉ាក់ណូល្យា" ដែលបង្កើតប្រវត្តិរបស់ខ្លួន តាំងពី ២០០ឆ្នាំមកហើយ។ ឆាឡេស្តុន Charleston ជាតំបន់កសិកម្មសុទ្ធសាធ គេដាំស្រូវ ដាំកប្បាស ធ្វើសំលៀកបំពាក់ ឥឡូវនេះស.រ.អា.មិនផលិតដំណាំទាំងនោះទៀតទេ ពីព្រោះប្រទេសនេះបានក្លាយទៅជាប្រទេសឧស្សាហកម្មជាន់ខ្ពស់ទៅហើយ គេនាំចូលអង្ករ ក្រណាត់ ពីប្រទេសពិភពលោកទី៣ដែលជាប្រទេសក្រីក្រ។

អ្នកត្បាញនៅតាមដងផ្លូវ ធ្វើកន្ត្រក់ កញ្ជើរទ្រនាប់ផ្សេងៗ ធ្វើដោយស្លឹកស្រូវ ឬស្លឹកស្មៅ គឺជាទម្លាប់កេរដូនតា ហើយធ្វើដោយវត្ថុធាតុដើមនាំមកពីជាង២០០ឆ្នាំមុន ដោយជនជាតិអាហ្វ្រិកកាំងខ្មៅដែលម្ចាស់ដីនាំមកជាទាសករកសិដ្ឋាន។ មិនសូវឃើញរូបចម្លាក់ធ្វើពីឈើដូចនៅតំបន់ពួកស្បែកខ្មៅឯទៀតៗទេ ទំនងមកពីវត្ថុធាតុដើមក្នុងតំបន់មិនសូវមាន។

នៅក្នុងបរិវេណតំបន់ដែលយើងទៅទស្សនាសារមន្ទីរ "ម៉ាក់ណូល្យា" ឈ្មោះខ្មែរគេហៅផ្កាត្របែកព្រៃយើងត្រូវជិះរថយន្តសណ្តោងដូចរថភ្លើងដោយមានអ្នកពន្យល់យើងគ្រប់ជំហ៊ានជាអ្នកបើកបរជូនយើងផង។ នៅតាមផ្លូវដែលអមដោយព្រៃរង្វើល តែដើមឈើខ្ពស់ៗចាស់ឆ្នាំព្រៃរនាមលិចទឹកធ្វើឱ្យយើងនឹកទៅដល់សត្វប្រពើ ត្រកួត ពស់ ដែលចិញ្ចឹមខ្លួន ដោយស៊ីសាច់សត្វដ៏ទៃ ដូចជាក្តាម ខ្ចង ត្រី មានរនាមខ្លះមានទឹកជ្រៅលាក់សត្វរាប់រយនាក់របស់ខ្លួនប្រុងប្រយត្នផង។ នៅសល់ចន្លោះផ្ទៃដីធំទូលាយជាកន្លែងដាំតំណាំ តែឥឡូវដើមកក់វែងៗ ដុះគជំនួសពេញទៅហើយដែរ។ គេនៅរក្សាបរិដ្ឋានមានរុក្ខជាតិនឹងសត្វដែលរស់នៅរាប់ទាំងសត្វស្លាបផង បានល្អណាស់ សូម្បីតែផ្ទះរបស់ទាសករស្បែកខ្មៅអាហ្វ្រិកាំងធ្វើពីឈើ ក៏នៅរក្សាបានប្រសើរដែរ ។

នៅតំបន់ដែលយើងទៅទស្សនានោះ ជាតំបន់សម្រាប់ដំណាំស្រូវនៅឆ្ងាយបន្តិច ទើបមានដំណាំកប្បាសដែលគេយកទៅត្បាញធ្វើជាក្រណាត់។ គឺដំណាំទាំងនោះហើយដែលគេបញ្ជូនមកធ្វើការកាត់ដេរជាខោអាវនៅតំបន់រោងចក្រតំបាញដូចជានៅឡូវែលយើងនេះជាដើម។ ម្ចាស់នៃកសិដ្ឋានដ៏ធំទូលាយនោះ ជាជនស្បែកសមានអងគ្លេសមានបារាំងមានអ៊ីឡង់ជាដើម មានផ្ទះសង់ជាវិមាន ធំស្កឹមស្កៃមានច្រើនបន្ទប់ ហើយប្រើអ្នកបំរើច្រើនគ្នា... ពីផ្ទះដ៏សម្បើមនោះ គឺសម្រាប់គ្រប់គ្រង់អ្នកបំរើស្បែកខ្មៅរាប់រយនាក់របស់ខ្លួន... នៅជុំវិញផ្ទះមានលំអដោយសួនឧទ្យានប្រកបដោយដើមផ្កាគ្រប់មុខមានទាំងកន្លែងលេងកីឡាវាយកូនគោល ឬប្រណាំងសេះនឹងកន្លែងប្រដេញបាញ់សត្វជាដើម ។ នៅជំនាន់សង្គ្រាមក្នុងស្រុករដ្ឋអំណាចបានកៀងគរទាសករជំទង់ៗពីឆាឡេស្តុននេះ ឱ្យទៅច្បាំងដណ្តើមអំណាចធ្វើឱ្យបាត់ប្រជាពលរដ្ឋខ្មៅយ៉ាងច្រើនតែទោះជាយ៉ាងនេះក្តី ក៏ចំនួនប្រជាពលរដ្ឋមិនបានចុះថយច្រើនទេ ដោយសារបន្ទាប់ពីសង្គ្រាមទៅទាហ៊ានដែលនៅសេសសល់បានត្រឡប់មករស់នៅក្រុងកំណើតរបស់ខ្លួនវិញ ធ្វើឱ្យស្ថិតិបង្ហាញថានៅសល់ប្រជាពលរដ្ឋខ្មៅពី៦០-៧០ភាគរយរស់នៅឆាឡេស្តុននៅឡើយ ។

ក្រៅពីតំបន់ដែលគេថែរក្សាមានសំណង់ "ហាយវេ" ជាច្រើនដែរ តែមុខរបរពាណិជ្ជកម្មមិនសូវជាហ៊ឹកហ៊ាក់ខ្លាំងខ្លាណាស់ទេ ព្រៃរនាមជាច្រើនធ្វើឱ្យគេនឹកទៅដល់ការបរបាញ់សត្វកាងារនៃសាទសមុទ្រដំណាំដាំដុះតំបន់កំសាន្តឆ្នេរសមុទ្របានក្លាយទៅជាគុណសម្បត្តិនៃតំបន់ភាគខាងត្បូងឈៀងខាងកើតនៃស.រ.អា.ទៅហើយ ។

យើងបានធ្វើដំណើរក្នុងតំបន់ឆាឡេតុននេះពេញមួយថ្ងៃសំដៅទៅរកអ្វីដែលប្លែកពីតំបន់ឯទៀតៗ ដោយស្វែងរកអ្នកធ្វើអត្ថាធិប្បាយពន្យល់បន្ថែមផង តែស.រ.អា.មិនខុសគ្នាច្រើនប៉ុន្មានទេ ដោយសារតំបន់នេះក្រីក្រពិត ក៏ប៉ុន្តែពលរដ្ឋអាមេរីកាំងមិនរហាម រហូតដល់បាត់បង់ស្មារតីលក់សិទ្ធសេរីភាពដើម្បីបំពេញក្រពះ ដូចប្រទេសសេដ្ឋកិច្ចទី៣ទេ ។ ប្រទេសនេះមានគំរូអភិវឌ្ឍន៏របស់គេមិនឱ្យទាបជាងឋានៈជាមនុស្សនឹងសង្គមថ្លៃថ្នូរនោះទេ ទោះជានៅជនបទដាច់ស្រយាលយ៉ាងណាក៏ដោយ ។ យើងបានទៅសាកសួ្បងរកភោជនីយដ្ឋាននៃអ្នករស់នៅក្នុងតំបន់ មុននឹងចេញដំណើរមក មើធីលប៊ិច វិញនាវេលាល្ងាចតែមិនបានភ្លក់ម្ហូបសំណាងតិចនោះទេ ដោយសារមិនសូវសម្បូរ រកមិនជួបប្រទះតែភោជនីយដ្ឋានធម្មតាសម្រាប់ទេសចរដែលនឹងធ្វើឱ្យ ប៉ុណ្ណារ៉ូ សប្បាយចិត្តជាងគេទៅវិញ ដោយស្រួលរកម្ហូប ដូចជាដំឡូងចៀន ហំប៊ឺក្លឺ ពិហ្សាជាដើម...។ យើងត្រឡប់មកដល់សណ្ឋាគារវិញយប់ល្ងម ពន្លឺនៃទីក្រុងបន្ទាញពីល្បែងកំសាន្តភោជនីយដ្ឋានផ្សព្វផ្សាយគួរឱ្យស្រក់ទឹកមាត់កង់ចក្រដឹកគូរសង្សារឡើងលើមេឃយ៉ាងខ្ពស់

តទៅទំព័រទី ២៣





# វត្តសុរិយារង្សីមានដំណោះស្រាយថ្មី

**ខ្មែរផុសស.រ.អា.**

**ហ្វីឡាដែលហ្វៀះ** វត្តសុរិយារង្សី ឬវត្តខាងជើងដែលពីដើមគេសំគាល់ថា "វត្តកម្ពុជាក្រោម" មានទំនាស់យ៉ាងជ្រាលជ្រៅមួយចាប់តាំងពីព្រះគ្រូចៅអធិការមុនចូលទិវង្គត់ទៅ ។គណកម្មការវត្តជាប់ឆ្នោតថ្មី បន្ទាប់ពីអាណត្តិលោក ថាច់ ជិន ចេញទៅ១-លោក ងូ ថាច់ ងុក ប្រធានថ្មី នឹងព្រះសង្ឃ២អង្គដែលគង់នៅក្នុងវត្ត ទើបមកដល់ថ្មីនាពេលនោះមានទំនាស់នឹងគ្នា រហូតដល់មានការប្តឹងប្តល់គ្នាទៅតុលាការមិនព្រមឱ្យគណកម្មការថ្មីមកកាន់ការក្នុងវត្តអស់រយៈពេល៤-៥ឆ្នាំ ២-រីឯវត្តក៏មានរឿងជាមួយ "ក្រុមត្រួតពិនិត្យក្រុង" ថែមទៀត ដោយបានចាក់ស៊ីម៉ង់សង់ទីធ្លាដោយគ្មានប្រឡាយទឹក ម្ល៉ោះហើយធ្វើឱ្យឧបាសកឧបាសិការជើងវត្តជាច្រើនឈប់ត្រឡប់មកធ្វើបុណ្យនៅវត្តកម្ពុជាក្រោមនេះ វត្តដែលធ្លាប់តែល្បីល្បាញពុទ្ធបរិស័ទធ្លាប់តែមកធ្វើបុណ្យកកកុញបែរជាស្ងាត់ជ្រងំ។

ព្រះតេជគុណ យ៉ាន តូន ជាព្រះសង្ឃគង់ប្រចាំវត្តសុរិយារង្សីមានពុទ្ធដីការប្រាប់ខ្មែរផុសកាលពីថ្ងៃទី២០មិថុនា២០១៥នេះថា ស្ថានភាពបានធូរស្រាលបន្តិចហើយ ដោយតុលាការបានចាត់ ១-ឱ្យមានតាំងដំណាងម្ខាង២នាក់ឱ្យមកគ្រប់គ្រងខាងលោក ង៉ូ ថាច់ង៉ុក មានលោក ង៉ូ ថាច់ង៉ុក នឹង លោក អេនឌី ថាច់ អាង រីឯខាង


ព្រះតេជគុណ យ៉ាន តូន

ព្រះសង្ឃមានលោក សឺង ជុំ នឹងលោក ថាច់ ហុង ជាអ្នកគ្រប់គ្រងរួម ២-សម្រេចឱ្យជាងពីសាលាក្រុងឱ្យមកជួសជុលទីធ្លាចាក់ស៊ីម៉ង់ហើយនោះឱ្យមកធ្វើផ្លូវបង្ហូរទឹកភ្លៀងឱ្យត្រឹមត្រូវដោយចំណាយប្រាក់វត្តចំនួន៦-៧០០០ដុល្លាសម្រាប់ជាង។ នៅពេលសួរថា តើស្ថានភាពទំនាក់ទំនងគ្នាបានប្រសើរឡើងហើយឬនៅ? លោកមានសង្ឃដីការតបថា នៅមើលបំណាំគ្នាខ្លះនៅឡើយ ! តែពុទ្ធ


លោក ត្រាន ម៉ានរិន

បរិស័ទដែលមិនសប្បាយចិត្តដោយឮពាក្យចរចាមអារាមថាព្រះសង្ឃចង់បំបែកខ្មែរលើខ្មែរក្រោម ក៏បានចេញទៅធ្វើបុណ្យនៅវត្តផ្សេងៗ រីឯអ្នកដែលមិនជឿនៅចូលចិត្តវត្តក៏នៅតែបន្តមកធ្វើបុណ្យនៅវត្តសុរិយារង្សីដដែល! ។

លោក ត្រាន ម៉ានរិន ធ្លាប់ជាអ្នកគាំទ្រវត្តយូរមកហើយ និយាយនៅថ្ងៃដដែលនោះថា រឿងផ្តើមឡើងនៅពេលគណកម្មការថ្មីចង់ដេញលោកចេញពីវត្តតែតុលាការបានចេញបញ្ជា កាលពី៦-៧ខែមុនមិនអនុញ្ញាត្តិឱ្យបណ្តេញនរណាចេញពីវត្តទេ ឱ្យថែររក្សាមានលោកក្នុងវត្ត...តុលាការបានទុកពេលឱ្យ២ឆ្នាំសម្រាប់ដោះស្រាយវិបត្តតែបើដោះមិនបានទេនឹងទៅដល់ "លក់វត្តចែកលុយគ្នា"...ឥឡូវនេះមានភាពស្ងប់ស្ងាត់ដោយទាំងសងខាងសម្ងំស្ងៀមនៅឡើយ មិនមាននរណាជាអាជ្ញាកណ្តាលសម្រាប់ជួយជម្រុញការនេះទេ។

លោក ង៉ូ ថាច់ង៉ុក នៃគណកម្មការម្ខាងទៀតនិយាយនៅថ្ងៃ២៤នេះថា មានបង្កើតតំណាងសម្រាប់ធ្វើការងារតម្រូវការត្រួតពិនិត្យក្រុងនោះ មែនតែយើងនៅតែមានការលំបាកនឹងធ្វើការទាក់ទងជាមួយនឹងលោកទាំង២អង្គនោះដដែល យើងកំពុងពិនិត្យលើចំណាយសម្រាប់ជួសជុលនោះ រីឯប្រាក់ជួសជុលនោះមានរួចទៅហើយ មិនមានបញ្ហាអ្វីទេ ពីព្រោះប្រាក់នៅក្នុងធានាគារមានទាំងសងខាង ក៏ប៉ុន្តែដល់ជួសជុលរួចហើយគេនឹងវាយតម្លៃវត្ត ថាតើលក់នឹងបានតម្លៃប៉ុន្មានរួចហើយគេនឹងចែកគ្នាជា២អ្នកយកវត្តនឹងប្រគល់ប្រាក់ពាក់កណ្តាលរួមទាំងលុយនៅក្នុងធានាគារ

តទៅទំព័រទី ១០







# រដូវបាល់ទាត់កុមារបានត្រូវបញ្ចប់



**Lowell Soccer: Final mach of the season**

**ខ្មែរផុសស.រ.អា.**

ប៉ុណ្ណារ៉ូ អាយុ៥ឆ្នាំ បានទទួលគុបរង្វាន់ពីគ្រូបង្ហាត់កីឡាបាល់ទាត់"ខូជ"របស់គេជាលើកដំបូង កាលពីថ្ងៃសៅរ៍ទី១៣ មិថុនា កន្លងទៅ នាចុងបញ្ចប់កម្មវិធីប្រកួតរដូវផ្ការីក។ បន្ទាប់ពីព្រឹលធ្លាក់សន្ធឹកសន្ធាក់ នារដូវរងារកន្លងទៅនេះ "សមាគមលីសា" ឬក៏ LYSA (Lowell Youth Soccer Association) បានបើកទីលានកីឡាបាល់ទាត់កុមារឡើងវិញ ទទួលកុមារប្រមាណ ៩០០នាក់ អាយុពី៣-១៦ឆ្នាំ ឱ្យចុះឈ្មោះលេងកីឡាបាល់ទាត់ក្រោមការដឹកនាំរបស់ប្រធាន វ៉ែតនីយ អេលិយ៉ុត អភិបាលក្រុងឡូវែល ។








ចូលក្នុងក្រុមមួយពាក់អាវស ដែលមានឈ្មោះថា "យូសឹក ដុលហ្វីន U6 Dolphin" មានគ្នា១១នាក់ដែលក្នុងនោះមានកុមារី២នាក់ផង ប៉ុណ្ណារ៉ូពាក់លេខ១៦ បានធ្វើការប្រកួតចុងក្រោយរបស់ខ្លួនជាមួយក្រុមអាវប្រផេះឈ្មោះ"យូសឹក វ៉ែរីយ័រ U6Warriors"។ ការប្រកួតថ្ងៃនោះមានពេល១ម៉ោងចែកជា២វគ្គ បានលទ្ធផលអាវសឈ្នះបាន៤ទល់នឹង២ធ្វើឱ្យប៉ុណ្ណារ៉ូរីករាយណាស់ ។ ក៏ប៉ុន្តែមុននឹងរីករាយ បន្ទាប់ពីរត់ដេញបាល់យ៉ាងនឿយហត់ក្រោមកំដៅថ្ងៃ៨០អង្សា ក៏អស់កម្លាំងចិត្តគេចទៅអង្គុយកំសត់ម្នាក់ឯងក្រោមប្លប់ឈើមួយដើម គេរអ៊ូថា ក្រុមរបស់គេមិនចូលចិត្តគេទេ បានជាមិនចែកបាល់ឱ្យគេបានទាត់ផង ។ ទាល់តែមានការពន្យល់ពីឪពុករបស់គេអំពីក្បួនលេងបាល់ទាត់នឹងរបៀបលេងបាល់រួមគ្នា នឹងតួនាទីរបស់កីឡាករម្នាក់ៗ ទើប ប៉ុណ្ណារ៉ូ ព្រមចូលទៅប្រកួត ហើយជួយមិត្តក្នុងក្រុម ដើម្បីទាត់បាល់យកឈ្នះវិញ។

ឪពុកម្តាយនឹងក្រុមគ្រួសារបានតាមដានស្រែកលើកទឹកចិត្តកូនដែលកំពុងប្រកួតតែរៀងៗខ្លួន នៅលើទីលានដែលមានទីប្រកួតប្រមាណ ១០ ធ្វើឱ្យបរិវេណកីឡាដ្ឋាន"អេដវឺឌ"ក្លាយជាអ៊ូអរ ដូចជាពិធីបុណ្យយ៉ាងអ៊ឹកធឹកមួយដែរ។ រៀងរាល់ថ្ងៃសៅរ៍ **តទៅទំព័រទី ១០**

THE LOWELL FLOWER HOUSE

Flower arrangement and Decoration for all occasions

209 Chelmsford St, Lowell, MA 01851

Tel: 978-455-0999, (978) 529-8627

By Sereysophana Yauk, a Talent Cambodian Artist












# ផ្លូវថ្មីដើរជើងថ្មីៗទៀតនៅឡូវែល

**ដោយ រីក ហាវ ជីអ័រ**

**ប្រែសម្រួលដោយខ្មែរផុសស.រ.អា.**



Richard Howe

កាលពីអំឡុងឆ្នាំ ៦០ អ្នករៀបចំគម្រោងក្រុងនៅស.រ.អា.នេះ គេគិតថា "មនុស្សរស់នៅក្រៅក្រុងតែមកធ្វើការនៅក្នុងក្រុង" ដូច្នេះគេគូសហើយគូសវាសទៀតដើម្បីសម្រួលការបើកបរទៅនឹងមកពីកន្លែងធ្វើការនៅក្នុងក្រុងឱ្យបានលឿនជាទីបំផុត។ គេគិតថា មនុស្សទាំងនោះនឹងប្រើរថយន្តផ្ទាល់ខ្លួននឹងមានមនុស្ស២-៣នាក់ប៉ុណ្ណោះដែលនឹងធ្វើដំណើរដោយជើងនឹងមានតិចតួចទេដែលនឹងប្រើរថយន្តឈ្នួលក្រុង។ ដោយសារអារម្មណ៍ផ្ដាប់មុខនោះហើយដែលផ្លូវខ្វែង "សំសុងកុណិចត័រ Sampson Connector" ជាឈ្មោះផ្លូវការរបស់ផ្លូវលឿន ផ្លូវមាន៤ខ្សែ បានភ្ជាប់សាលាក្រុងឡូវែលទៅ"ឡូវែលកុណិចត័រ Lowell Connector"នោះ។ ពីដើមសំសុងកុណិចត័រគឺជាផ្លូវពីរដាច់ពីគ្នា គឺផ្លូវ Dutton St។ នឹងផ្លូវ Thorndike St។ តែមកដល់ឆ្នាំ១៩៦០ ផ្លូវទាំងពីរបានត្រូវបញ្ចូលរួមតែ១វិញ។

អ្នករៀបគម្រោងក្រុងទាំងនោះបានគិតមានចន្លោះ...ពីព្រោះនៅពេលពលរដ្ឋប្ដូរទីកន្លែងទៅក្រៅក្រុងអស់ទៅគេបានគិតគួរនោះ ត្រឹមត្រូវហើយ ក៏ប៉ុន្តែបានបានទុកដីធ្លីទំនេធំទូលាយនៃកណ្ដាលក្រុងឱ្យប្រឹងរស់យ៉ាងលំបាក។ ក៏ប៉ុន្តែសំណាងល្អដែរ ដែលពលរដ្ឋអាមេរិកាំងសព្វថ្ងៃ

**តទៅទំព័រទី ២៧**

# A More Walkable Lowell

**By Richard P. Howe Jr.**

In the 1960s, urban planners in American concluded that people would all live in the suburbs but work in the city so they designed and redesigned roadways to allow people to drive to and from their jobs in the cities as quickly as possible. They assumed everyone would own his or her own car and that there would be few walkers and little use of public transportation. That mindset gave Lowell the Sampson Connector which is the official name of the high-speed, four-lane road running from City Hall to the Lowell Connector. The Sampson Connector used to be two separate roads - Dutton Street and Thorndike Street - but in the 1960s they were merged into one.




The city planners miscalculated. When people moved to the suburbs, so did their jobs. This left large areas of downtown cities vacant and struggling to survive. Fortunately, many Americans today have embraced city living and places like downtown Lowell are showing new life. An important component of this new urban living is the ability to walk, ride a bike, or take public transportation rather than drive a privately owned car everywhere.

One of the biggest challenges facing the city of Lowell in 2015 is how to undo the poorly designed roadways from the past. It is too expensive to do them over entirely, so they must be modified to make them easier and safer for use by walkers and bicyclists.

This is especially important along the Sampson Connector because that is a stretch of roadway filled with important and interesting places. Starting at the Pollard Memorial Library on Merrimack Street and heading south towards the Lowell Connector, there is the Smith Baker Center, the Arts League of Lowell Gallery, **Continued to page 27**




# អគ្គរដ្ឋអាជ្ញា ម៉ូរ៉ា ហ៊ីលី បើកការិយាល័យចូលរួម សហគមន៍

## AG HEALEY LAUNCHES COMMUNITY ENGAGEMENT DIVISION

ភូមិភាគដែលទើបនឹងបើកជាលើកដំបូង ផ្តោតទៅលើទំនាក់ទំនងជាមួយសហគមន៍នៅ


ម៉ូរ៉ា ហ៊ីលី បង្ហាញខ្លួនជានាយកភូមិភាគ ម៉ក់ូនី បារ៉ូស


ម៉ូរ៉ា ហ៊ីលី ជាអគ្គរដ្ឋអាជ្ញាអាមេរិក រដ្ឋម៉ាសាឈូសេត

ក្នុងរដ្ឋទាំងមូលដឹកនាំដោយនាយកមកពីការិយាល័យជនភៀសខ្លួន នឹងអន្តោប្រវេសន៍

First-of-its-kind division focused on engaging with residents across the state to be led by former director of Office for Refugees and Immigrants

បូស្តុនៈក៏សាងឡើងនៅលើពាក្យសន្យារបស់អគ្គរដ្ឋអាជ្ញា ម៉ូរ៉ា ហ៊ីលី នៅពេលឃោសនាភូមិភាគចូលរួមសហគមន៍បានត្រូវបង្កើតឡើង ។ នេះជាលើកដំបូងបង្អស់ ដែលភូមិភាគរបៀបនេះ នឹងនាំអគ្គរដ្ឋអាជ្ញាព្រមទាំងកិច្ចការរបស់លោកស្រីទៅក្នុងគេហដ្ឋាននឹងក្នុងសហគមន៍ពាសពេញរដ្ឋទាំងមូល ។

"នេះគឺជាអង្គការច្បាប់របស់ពលរដ្ឋ ដែលមានសារៈសំខាន់ណាស់សម្រាប់ខ្ញុំអ្នករស់នៅក្នុងរដ្ឋទាំងអស់ត្រូវផ្ជាប់ទំនាក់ទំនងមកការិយាល័យយើង នឹងស្គាល់កាងាររបស់យើង" ថ្លែងដោយអគ្គរដ្ឋអាជ្ញា ម៉ូរ៉ា ហ៊ីលី "បទពិសោធន៍របស់ខ្ញុំទៅជុំវិញរដ្ឋយើងថា អ្នកក្រុងជាច្រើនមិនទាន់យល់គ្រប់គ្រាន់ នឹងប្រើប្រាស់ការិយាល័យអគ្គរដ្ឋអាជ្ញានៅឡើយទេ។ ភូមិភាគថ្មីមួយនេះ នឹងជួយធានាដល់ពលរដ្ឋ ថានឹងអាចរកធនធានដែលខ្លួនត្រូវការ ដើម្បីដោះស្រាយបញ្ហារបស់ខ្លួនបាន" ។

នាយកមួយរូបឈ្មោះ ម៉ក់ូនី បារ៉ូស មកពីការិយាល័យជនភៀសខ្លួន នឹងអន្តោប្រវេសន៍ នឹងអ្នកទទួលខុសត្រូវខាងផ្នែកទំនាក់ទំនងម្នាក់ទៀតឈ្មោះ វីលី បូឡិក នឹងមកធ្វើឱ្យភូមិភាគនេះមានដំណើតការ ។

BOSTON - Building on her promise to run an inclusive and responsive office, Attorney General Maura Healey today launched her office's Community Engagement Division. The first-of-its-

តទៅទំព័រទី ០៩




# REMEDIUM PHARMACY



2 VINAL Square
N. Chelmsford, MA 01863

Phone: **(978) 251-7070**

## FREE Daily Home Delivery

**Blisterpack Packaging**

**Friendly Consultations**

**Compounded Medications**

**Easy Transfers**

បុគ្គលិកទាំងអស់របស់ឱសថស្ថានរីមីឌីមយើងខ្ញុំមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបំរើសេវាផ្តល់ឱសថជូនដល់សហគមន៍ខ្មែរ។ គេទាំងអស់គ្នាបានត្រៀមរួចជាស្រេចដើម្បីជួយ និង ត្រៀមបំរុងជានិច្ច ដើម្បីប្រើគ្រប់ជំនាញ និងការពិសោធន៍ក្នុងការបំរើលោកអ្នក។




ឱសថស្ថានរីមីឌីម ផ្តល់ជូនលោកអ្នកនូវៈ

**ជូនឱសថឲ្យដល់លំនៅស្ថានដោយឥតគិតថ្លៃ**

**ដាក់ឱសថក្នុងបន្ទះបែងចែកឱសថសំរាប់ប្រើតាមពេល**

**ការពិគ្រោះយោបល់យ៉ាងរាក់ទាក់ស្និទស្នាល**

**មានផ្តល់ជូនម្សៅថ្នាំលាយ**

**ភាពងាយស្រួលក្នុងការផ្ទេរចេញចូល**



Cristina គ្រីស្ទីណាៈ
គ្រីស្ទីណាមានការពិសោធន៍គ្រប់គ្រាន់នៅក្នុងកិច្ចការបំរើសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង៣ឆ្នាំមកហើយ។អ្នកស្រីគឺជាឱសថការិនីដែលគ្រប់គ្រងឱសថស្ថាន រីមីឌីម នេះ ហើយគាត់ក៏អាចធ្វើការពិគ្រោះអំពីឱសថ ជូនលោកអ្នកដល់ផ្ទះផងដែរ។ ដោយសារការផ្តល់នូវសេវាកម្មផ្នែកឱសថនេះ បានច្បាស់លាស់ទើប អ្នកស្រីអាចបង្កើត បាននូវចំណងមិត្តភាពយ៉ាងល្អប្រពៃក្នុងសហគមន៍ខ្មែរក្នុងក្រុងឡូវែល ហើយអ្នកស្រីមានសេចក្តីរីករាយណាស់ដើម្បីរង់ចាំបំពេញនូវបំណងរបស់លោកអ្នកដែលត្រូវការឱសថ។



Kelly ខែលលីៈ
គឺជាឱសថការិនីយើងដែលអាចនិយាយភាសាខ្មែរហើយដែលយកចិត្តទុកដាក់ចេះជួយលោកអ្នក។ គាត់ជាឱសថការិនី ចេញពីមហាវិទ្យាល័យឱសថសាស្រ្តរដ្ឋម៉ាសាឈូសេត និង ពេញចិត្តធ្វើការបំរើសហគមន៍ខ្មែរដែលគាត់ក៏ជាសមាជិកម្នាក់នៃសហគមន៍នេះដែរ។



Pahim លោកប៉ាហ៊ីមៈ
គឺជាបុគ្គលម្នាក់ដែលមានការគោរពច្រើននៅក្នុងសហគមន៍ខ្មែរ គាត់ក៏ជាសមាជិកម្នាក់នៅក្នុងគណកម្មការវត្តត្រៃរតនារាម ហើយធ្លាប់មានការពិសោធន៍ជាច្រើនឆ្នាំក្នុងការជួយសហគមន៍ដែលត្រូវការព្យាបាលជម្ងឺ។ ក្នុងរយៈកាលកន្លងមក គាត់ធ្លាប់បានធ្វើការយ៉ាងច្រើនជួយគាំទ្រដល់អ្នកជម្ងឺនៅមជ្ឈមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែលនិងមណ្ឌលសុខភាពពេទ្យមេត្តាព្រមទាំងធ្លាប់បានចូលរួមចំណែកក្នុងការថែទាំដោយឱសថសំរាប់សហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង២ឆ្នាំផងដែរ។ ក្នុងនាមជសមាជិកម្នាក់នៃឱសថស្ថានរីមីឌីម គាត់នឹងបន្តធ្វើការបំរើឱ្យកាន់តែខ្លាំងខ្លាថែមទៀតដើម្បីបំពេញនូវតំរូវការក្នុងការផ្តល់ឱសថដល់លោកអ្នក។



Daniela ដានីញែលឡាៈ
មានជំនាញច្បាស់លាស់ក្នុងការវេចខ្ចប់ឱសថដាក់ក្នុងបន្ទះពង្រាយថ្នាំសំរាប់ប្រើតាមពេល ហើយធ្លាប់ឆ្លងកាត់ការថែទាំអ្នកជម្ងឺខ្មែរដែលរស់នៅក្នុងក្រុងឡូវែលនេះអស់រយៈពេលជាង៣ឆ្នាំមកហើយ។ ប្រសិនបើលោកពេញចិត្តនឹងការប្រើថ្នាំដាក់ក្នុងបន្ទះបែបនេះ ដានីញែលឡាពេញចិត្តណាស់នឹងធ្វើកិច្ចការនេះជូនលោកអ្នក។



Dary ដារីៈ
តែងបានយកចិត្តទុកដាក់ជាប់ជានិច្ចក្នុងសេវាកម្មផ្តល់ឱសថ ដើម្បីបំពេញតាមតំរូវការនៃសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈជាង២ឆ្នាំមកហើយ ហើយតែងទទួលបាននូវការកោតសរសើរពីសំណាក់អតិថិជនដែលបានជួបប្រាស្រ័យជាមួយគាត់។ ក្នុងឋានៈជាអ្នកបច្ចេកទេសម្នាក់របស់ឱសថស្ថាន គាត់មានការយល់ដឹងយ៉ាងជ្រៅជ្រះអំពី តំរូវការ និងប៉ិនប្រសប់ក្នុងការផ្តល់សេវាជូនលោកអ្នកនិងចេះសំដែងនូវការគោរពយ៉ាងទន់ភ្លន់ចំពោះលោកអ្នកផងដែរ។



Kassandraកាសាន់ដ្រាៈ
គឺជាបុគ្គលិកដែលមានការពិសោធន៍ច្រើនក្នុងការធ្វើទំនាក់ទំនងជាមួយសហគមន៍ខ្មែរ និងស្បានិសសដែលរស់កក្នុងងក្រុងឡូឡូវែលលនេះ។
លោកអ្នកអាចនឹងពេញចិត្តអំពីភាពរាក់ទាក់រាល់ពេលនិយាយឆ្លើយឆ្លងតាមទូរស័ព្ទជាមួយនាង និងប៉ិនប្រសប់ក្នុងការរៀបចំឱសថជូនលោកអ្នកនៅរាល់ពេលដែលលោកអ្នកត្រូវការ។

# រដ្ឋាភិបាលខ្មែរក្រោមក្នុងដំណើរទៅរកមាតុភូមិ

**ដោយ ពិន សំខុន**

**ឡូវែល:** មនុស្សប្រមាណ៣០០នាក់មកពីគ្រប់ទិសទីនៃអាមេរិកខាងជើងដែលភាគច្រើននិយាយភាសាខ្មែរបែបរដឹនបានមកប្រារព្ធពិធីបុណ្យពេញមួយថ្ងៃយ៉ាងឧឡារិករៀបចំឡើងដោយ "សហព័ន្ធខ្មែរកម្ពុជាក្រោម"ដើម្បីជាការ "រំលឹកខួបទី៦៦នៃការបាត់បង់ដីខ្មែរផ្នែកខាងត្បូង" ដែលគេហៅថាកម្ពុជាក្រោមនៅឡូវែលនាភោជនីយដ្ឋានខ្មែរដ៏ធំទូលាយមួយឈ្មោះសំពៅមាសក្រោមអធិបតីភាពនៃរដ្ឋាភិបាលខ្មែរក្រោម ដែលអង្គកាសហប្រជាជាតិឱ្យឈ្មោះថា "UNPOU nrepresented Nationsand People Organisation អង្គការពលរដ្ឋដែលគ្មានប្រទេស"។

ដំណាងពលរដ្ឋគ្មានប្រទេសដែលបានមក-នាថ្ងៃនេះមានលោកប្រាក់ សេរីវុឌ្ឍ អនុប្រធានមកពីកាលីហ្វ័រញ៉ា លោក ត្រាន់ យ៉ាប់ មកពីញូជ័រយឺជានាយករដ្ឋបាលលោកស្រី សឹង ស៊ុនិត តំណាងស្ត្រីកម្ពុជាក្រោមមកពីផែនស៊ុវេនា លោក ត្រាន់ ម៉ាន់រិន មកពីផែនស៊ុវេនា នឹងលោក ត្រឹង ងា មកពីជចជ្យា ដំណាងភូមិភាគ។ លោក ថាច់ ង៉ុកថាច់ ដែលជាប្រធានកំពុងជាប់រវល់នៅសភាយូរ៉ុប នៃទីក្រុងប្រ៊ុកសែលប្រទេសបែលហ្សិក។ សម្លេងនៃមន្ត្រីខ្មែរក្រោមទាំងនោះតំណាងឱ្យ




ជនជាតិភាគតិចដើមកំណើតខ្មែរជិត១៧លាន-នាក់(ស្ថិតិដែលខ្មែរផុសទទួលបានពីវៀតណាមនាដែលដីសណ្តរអមទន្លេមេគង្គខ្មែរមាន៩៣ភាគរយនៃពលរដ្ឋទាំងមូលរស់នៅទីនោះ)រស់នៅតាមដងទន្លេមេគង្គក្រោមការគ្រប់គ្រងនៃប្រទេសវៀតណាមដែល៤ឆ្នាំម្តង ត្រូវទៅធ្វើសេចក្តីរាយការណ៏លំអិតជូនអ.ស.ប.ស្តីអំពីការអនុវត្តន៏សិទ្ធិមនុស្សនៃជនជាតិភាគតិចខ្មែរក្រោមដោយមានវត្តមាននៃមន្ត្រីជាន់ខ្ពស់ប្រទេសវៀតណាមនៅទីនោះផង។

គណកម្មការបុណ្យផ្តើមកម្មវិធីតាំងពីម៉ោង៩ព្រឹកតាមគន្លងព្រះពុទ្ធសាសនាមានសូត្រមន្តប្រគេនចង្ហាន់ព្រះសង្ឃ រំលឹកវិញ្ញានក្ខន្តបុព្វបុរសនៅចំពោះព្រះភ័ក្ត្រព្រះសង្ឃខ្មែរក្រោម៥អង្គដែលនិមន្តពីរដ្ឋផ្សេង១នឹងកាណាដា។ ពិធីករ



បង្ហាញខ្លួនមន្ត្រីនៃសហព័ន្ធខ្មែរកម្ពុជាក្រោម



បូពា សុខ និង សុបិន ពិន ជាពិធីករ

នាថ្ងៃនេះមាន សូបិន ពិន នាយិកាខ្មែរផុស ស.រ.អា.នឹង បូពា សុក ម្ចាស់ពាណិជ្ជកម្មដែលដឹកនាំកម្មវិធីតាំងពីព្រឹករហូតដល់អាធ្រាតមានជាអាទិ៍នាពេលរសៀលនៃថ្ងៃអាទិត្យនោះ ១-ការបង្ហាញដំណើរការណ៏រដ្ឋបាលសហព័ន្ធខ្មែរកម្ពុជាក្រោម ដោយលោក ត្រាន់ យ៉ាប់លោករៀបរាប់នឹងបង្ហាញរូបភាពពីរចនាសម្ព័ន្ធសហព័ន្ធយ៉ាងល្អិតល្អន់បណ្តាលឱ្យមានចំណងទាក់ទងដ៏រឹងមាំសម្រាប់ការពារបងប្អូនខ្មែរក្រោមជូនភ្ញៀវដែលមកស្តាប់យ៉ាងយកចិត្តទុកដាក់-

២-ប្រវត្តិនៃការបាត់បង់ទឹកដីខ្មែរភាគខាងត្បូងដោយលោក ត្រាន ម៉ាន់រិន លោករំលឹកប្រវត្តិយ៉ាងវែងនៃការបាត់បង់ទឹកដីនឹងការព្រមឡើងសោយរាជ្យរបស់ស្តេចយួនការដាយជាថ្នូរនឹងការឱ្យដីខ្មែរក្រោមទៅយួន។ បង្ហាញសក្ខីកម្មនៃការធ្វើបាបទារុណកម្មបំបាត់ពូជសាសន៏របស់យួននឹងការតស៊ូរបស់បងប្អូនខ្មែរទាំងក្នុងនឹងក្រៅស្រុករួមគ្នា រហូតដល់បានជីវភាពប្រសើរបន្តិចនាសព្វថ្ងៃនេះ។ លោកថាដោយសារទំនាក់ទំនងសម័យថ្មីយ៉ាងលឿននេះ យួនវាខ្លាចយើងស្រែកទៅអ.ស.ប.ឡើងទៀតវ៉ាទៅធ្វើបាតុកម្មរាប់ពាន់នាក់នៅអាមេរិក នៅកាណាដា នៅយូរ៉ុប មិនឈប់ឈរទាំងអស់គ្នាឆ្ងល់ថា ប្រទេសណាជាអ្នកជួយ? ទាំងអស់គ្នានោះមិនដឹងទេថា បានលុយមកពីណា ខ្ញុំប្រាប់ទៅចុះ! គឺបងប្អូនទាំងអស់គ្នានោះហើយជាអ្នកជួយសហព័ន្ធឱ្យយើងមានសកម្មភាពទៅជួយដល់បងប្អូនយើងនៅឯស្រុកឯណោះ ហើយធ្វើឱ្យយួនគ្នាវាច្រណែនថា រដ្ឋយួនជួយខ្មែរច្រើជាងជួយយួនទៅទៀត...

៣-តស៊ូរបស់ខ្មែរក្រោមទាំងនៅក្នុងនឹងនៅក្រៅវៀតណាមមានបញ្ចាំងរូបភាពដោយលោក ប្រាក់ សេរីវុឌ្ឍ ដែលបង្ហាញពីការទាក់ទងយ៉ាងជិតស្និទ្ធសុខទុក្ខរវាងខ្មែរក្រោមនិងខ្មែរកណ្តាលនៅគ្រប់ដំណាក់ការនៃការវិវឌ្ឍនយោបាយនៅកម្ពុជា រហូតមកដល់សព្វថ្ងៃ ។

៤-ការតស៊ូស្ត្រីខ្មែរក្រោមដោយលោកស្រី សឹង ស៊ុនិត... លើកឡើងពីការតស៊ូនៃស្ត្រីខ្មែរក្រោម ដើម្បីបុព្វហេតុបងប្អូនញាតិមិត្តរួមឈាមមួយបុរសដោយគ្មានញញើតរំដោះពីក្រញាំទុក្ខទោសនៅឯកម្ពុជាក្រោមដោយកម្មុយនីស្តវៀតណាម។

៥-នាវេលាល្ងាចឡើងបន្តដោយការបង្ហាញបន្ថែមដោយសកម្មភាពតស៊ូតាមផ្លូវច្បាប់នៅលើឆាកអន្តរជាតិដោយក្រុមខ្មែរក្រោម ដើម្បីការពារក្រុមគ្រួសារដែលមិនបានគេចចេញរួចពីការគ្រប់គ្រងរបស់យួនកុម្មុយនីស្តតាំងពី២០ឆ្នាំមកហើយ ដោយមេធាវីហាវ៉ៃរបស់សហព័ន្ធ លោក ជស គូព័រ ។ គឺជាការផ្តើមសកម្មភាពអហឹង្សារបស់សហព័ន្ធខ្មែរកម្ពុជាក្រោមដោយប្រើសិទ្ធជាខ្មែរក្រោមជាម្ចាស់ស្រុកនឹងប្រព័ន្ធច្បាប់ **តទៅទំព័រទី ១០**

ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៏
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្តីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

adventures await
Greater Merrimack Valley
Convention & Visitors Bureau
For more fun things to see & do
and great places to eat & stay, visit...
www.merrimackvalley.org

តមកពីទំព័រទី ០៦ អគ្គរដ្ឋ អាជ្ញា...

kind division will bring the Attorney General's Office and its work into neighborhoods and communities across the Commonwealth.

"This is the people's law firm and it's important to me that people across our state are connected with our Office and the work we do," said AG Maura Healey. "My experience traveling around the state taught me that many residents do not understand the full scope and reach of the Attorney General's Office. This new division will help ensure people are connected with the resources they need to help solve their problems."

To lead the division, the AG has tapped Marcony Almeida-Barros. Almeida-Barros most recently served as the Acting Executive Director for the Office for Refugees and Immigrants (ORI) and previously worked as the office's chief of staff. Prior to working for ORI, Almeida-Barros was the Director of Organizing and Deputy Executive Director for the Massachusetts Immigrant and Refugee Advocacy Coalition, where he worked on immigration reform at the federal level and directed the organization's outreach, legislative and advocacy efforts.

# តើធ្វើដូចម្តេច ដើម្បីជៀសវាងជំងឺពុកឆ្អឹង?



ខាងក្រោមនេះ ជាវិធីសាស្ត្រមួយចំនួនដែលធ្វើឱ្យអ្នកជៀសវាងពីជំងឺពុកឆ្អឹង៖

-ទទួលទានអាហារដែលសម្បូរជាតិ កាល់ស្យូម ដូចជាទឹកដោះគោ បន្លែពណ៌បៃតង និងសណ្តែក។ ហើយត្រូវជៀសវាងការសេពគ្រឿងស្រវឹង និងការញ៉ាំជាតិ កាហ្វេអ៊ីនច្រើនពេក។

-ធ្វើលំហាត់ប្រាណ ដូចជាការរត់ ដើម្បីធ្វើចលនាសរសៃឈាមបេះដូង។

-ទទួលយកវីតាមីន D ពីពន្លឺព្រះអាទិត្យ និងសារធាតុបំប៉នបន្ថែម ហើយត្រូវចាប់ផ្តើមពិនិត្យកម្រិតវីតាមីន D នៅពេលអ្នកមានអាយុ៣០ឆ្នាំ។

-ពិនិត្យរកជំងឺពុកឆ្អឹង ប្រសិនបើអ្នកមានប្រវត្តិគ្រួសារមានជំងឺពុកឆ្អឹង។

-នៅពេលអ្នកមានជំងឺពុកឆ្អឹងកម្រិតមធ្យមទៅករណីធ្ងន់ធ្ងរ អ្នកជំងឺជាច្រើនបានទទួលភាពជោគជ័យក្រោយពេលប្រើថ្នាំមួយចំនួន ដូចជា Fosamax, Reclast និង Prolia ៕


## Neighborhood Physical Therapy




**337 Westford Street. Lowell, MA 01851**

**978-455-4320**

- Auto Accident Injuries
- Work Injuries
- We provide transportation

- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅកន្លែងធ្វើការ
- យើងខ្ញុំមានផ្តល់ការជញ្ជូនសម្រាប់លោកអ្នក





LEGEND

**AUTO BODY INC.**

**(978) 458-2085**

**Services**

- Auto Body
- Auto Mechanics
- Foreign and Domestics
- State and Insurance Certified

Towing - **978-815-9957** (K.C)

**មានបម្រើ**

- ជួសម៉ាស៊ីនយានយន្ត
- ប្រភេទយានយន្តក្នុង និងក្រៅប្រទេស

**តួយានយន្ត**

- បញ្ជាក់ប័ណ្ណធានារ៉ាប់រងទទួលស្គាល់ដោយរដ្ឋ

**ដឹកឡានត្រូវថូវ** 978-815-9957 (ខេ-ស៊ី)



**115 Rock St. Unt #7 Lowell, MA 01854**

## តមកទំព័រទី ០៤ រដូវបាល់ទាត់...

នារដូវផ្ការីកសភាពអ៊ូអររបៀបនេះបានកើតឡើងតាំងពិព្រឹកព្រលឹមរហូតដល់ល្ងាចដោយកីឡាករទាំង៩០០នាក់ បានផ្លាស់វេណគ្នាមួយក្រុមម្តង១ប្រកួតយ៉ាងព្យាយាមមានខ្លះបានចូលមករួមក្នុងសមាគមកីឡាបាល់ទាត់នេះច្រើនឆ្នាំមកហើយទេពកោសល្យក្នុងការលេងបាល់ទាត់ក៏មានកាន់តែខ្ពស់ដោយមានការណែនាំពី"ខូជ"វិជ្ជាជីវៈ ធ្វើឱ្យកុមារា នឹង កុមារី មានកម្លាំងមាំមួនពូកែដូច គ្នា។

មានវិទ្យាល័យឯកទេសមួយចំនួនដែលនៅ


ថមី និង ថេល័រ អនាគតជើងឯកខាងបាល់ទាត់ថតជាមួយគ្រួសារនៅវិទ្យាល័យអាក់តុន MA

ជុំវិញដំបន់ឡូវែលនេះ ដូចជាសាលានៅក្រុង "អាកថុន" នៅប្រហែល១ម៉ោងពីឡូវែល គេមកតាមដានសិស្សដែលឧស្សាហ៍ព្យាយាមហាត់ ហើយរៀនពូកែទាក់ទាញឱ្យអាហារូបករណ៍ទៅរៀននៅវិទ្យាល័យដ៏ល្បីឈ្មោះរបស់គេដែលឪពុកម្តាយនឹងលែងភ័យពីអនាគត់របស់កូនទៀតហើយ។ មានកូនខ្មែរមួយចំនួនហើយដែលបានដើរតាមផ្លូវដ៏មានសំណាងល្អនេះ ដូចជា "ថមី" នឹង "ថេល័រ" ជាកូនលោក ផៃល ស ប៉ូលិសតុលាការបន្ទាប់ពីបានទទួលអាហារូបកណ៍នៅវិទ្យាល័យអាក់តុន ឥឡូវបានអាហារូបករណ៍ខ្ពស់ម្នាក់មួយទៀត ទៅរៀននៅមហាវិទ្យាល័យដ៏ល្បីឈ្មោះនៅ"អូហាយូ"នឹងមួយទៀតនឹងទៅចូលរៀននៅមហាវិទ្យាល័យ"សៅ ការ៉ូឡាយូណា"។

Lowell Youth Soccer Association P.O. Box 2034 Lowell, MA 01852-2344978-399-8764lowellsoccer@sportsmanager.us

## តមកទំព័រទី ០៣ វត្តព្រះពុទ្ធរង្សី

បូកចូលជាមួយគ្នារួចចែកជា២ផ្នែក...ការនេះយើងសម្រេចគ្នារួចហើយ មេធាវីទាំងសងខាងក៏បានព្រាងលិខិតចុះហត្ថលេខាមេធាវីទាំងពីរខាងនឹងហត្ថលេខាសាក្សីពីសាលាក្រុងរួចទៅហើយទៀតដែរ... ខាងគេនឹងយកវត្តខាងយើងនឹងយកលុយ។ នៅពេលសួរថា តើនឹងមានលទ្ធភាពសម្រុះសម្រួលគ្នាបានឬទេ? លោក ង៉ូ ថាច់ង៉ុក តបថា មិនបានទេ ពីព្រោះលោកទាំង២អង្គនោះធ្វើនយោបាយ។

ជាថ្មីម្តងទៀត វត្តអារាមខ្មែរនៅស.រ.អា.នេះ ពុំមានការគ្រប់គ្រងគំរូពុទ្ធចក្របន្តិចណាឡើយ... វត្តជាច្រើនមានទំនាស់ តែគ្មានដំណោះស្រាយ ម្ល៉ោះហើយក្តីក្តាំគ្នាច្រើនឆ្នាំ រលាយឧបាសក-ឧបាសិកាជើងវត្តស្ទើរអស់រលីងពីខ្លួន ថែមទាំងធ្វើឱ្យអាសោចន៍ដល់ព្រះពុទ្ធសាសនាថេរវាទ យ៉ាងដំណំទៀតផង... គេល្មមដល់ពេលនាំគ្នាគិតគូរថែរទាំព្រះពុទ្ធសាសនាខ្លះផងហើយទេដឹង? ៕

## តមកទំព័រទី ០៨ រដ្ឋាភិបាលខ្មែរក្រោមក្នុងដំណើរទៅរក...

ហើយបានផ្លែផ្កាយ៉ាងគួរឱ្យគាបចិត្តសម្រាប់ជនជាតិភាគតិចខ្មែរដែលកំពុងរស់នៅឯវៀតណាមឯណោះ។

ចលនាសហព័ន្ធខ្មែរកម្ពុជាក្រោមបានផ្តើមរូបរាងជាដំបូងបង្អស់នាឆ្នាំ១៩៨៥ នៅក្នុងសន្និបាទពិភពលោកខ្មែរក្រោមមួយនៅទីក្រុងញូយ៉ក។ ១០ឆ្នាំក្រោយមក១៩៩៦ ឈ្មោះ "សហព័ន្ធខ្មែរកម្ពុជាក្រោម" KKF KhmerKrom Federation ក៏បានកើតឡើងជាអង្គការនយោបាយនៅក្នុងមហាសន្និបាតខ្មែរក្រោម នៅទីក្រុង តូរុងតូ ណាប្រទេសកាណាដា។ គឺជាទំព័រថ្មីនៃការតស៊ូដើម្បី


រាំកំសាន្តនៅពេលចប់កម្មវិធី

យុត្តិធម៌ ដោយប្រើអហឹស្សា ដើម្បីជាប្រយោជន៍ដល់ប្រជាជនខ្មែរក្រោមរាប់សិបលាននាក់ ជាពិសេស ដើម្បីសិទ្ធធ្វើសេចក្តីសម្រេចវាសនាជាតិដោយខ្លួនឯង។ ពាក្យស្លោកមួយផ្ទាំងដែលនិយាយពី"ដំណើរទៅរកមាតុភូមិ" គឺជាអត្ថន័យ "សិទ្ធធ្វើសេចក្តីសម្រេចវាសនាជាតិដោយខ្លួនឯង" នោះហើយ៕


# វិធីព្យាបាលដោយកាយវប្បកម្មនៅមេរីម៉ែក-វ៉ាលី, និងនៅ វូបឿន

## Merrimack Valley Physical Therapy And

## Physical Therapy of Woburn

**Mission Statement:** សេចក្តីថ្លែងការអំពីគោលបំណង

ផ្តល់គុណភាពក្នុងការថែរក្សាសុខភាព, ធ្វើឲ្យមានសុខភាពប្រសើរឡើង និង ដំណើរជីវិតឲ្យមានភាពសកម្មជាងមុន, យើងមានជើថាការជំជួយដល់មនុស្សឲ្យមានរាងកាយនិងស្មារតីមាំមួនតាមរយៈការព្យាបាលធ្វើលំហាត់ប្រាណ,និងជួយដល់អ្នកជម្ងឺបានជាសះស្បើយឡើងវិញបាន.

To provide quality health care in order to promote healthier and more active lifestyles. We believe in helping people strengthen their bodies and minds through therapeutic exercise and helping people recover from injuries.

- Back Issue Program :ការបញ្ចេញកម្មវិធីផ្នែកខាងក្រោយ
- Pre-natal Program :កម្មវិធីមុនកំណើតកូន
- Pre and Post-Operative Care :ថែទាំមុននិងក្រោយពេលព្យាបាលជម្ងឺ
- Injuries dues to auto accident :របួសមកពីគ្រោះថ្នាក់ពីរថយន្ត
- Worker's Compensation Claims :ទាមទារសំណងសម្រាប់អ្នកពលកម្ម
- Slips and Falls :រអិលដួល
- Sport Injuries :របួសកីឡា
- Experience in documentation for litigation purposes :បទពិសោធន៍ឯកសារមានប្រយោជន៍ក្នុងការវិវាទ
- Translations in Khmer and Vietnamese now available:មានការបកប្រែជាភាសាខ្មែរនិងវៀត-ណាម

សូមទាក់ទងនិង:សេរីណា វ៉ាន-យ៉ាញ, ទូរស័ព្ទលេខ:៩៧៨-៥៦៩-៣១២០,Contact Serina Van-Danh at 978-569-3120,
ការណាត់ជួបជាមួយយើងខ្ញុំតាមរយៈអាសយដ្ឋាន២កន្លែងខាងក្រោម៖

To schedule an appointment, please contact us at one of our 2 locations:

Lawrence :
225 Essex St. Unit 1E
Lawrence, MA 01840
Tel: 978-208-0402/978-258-2908

Woburn :
400 West Cummings Park, Suite 1400
Woburn, MA 01801
Tel: 781-938-1223

# លោក ប៉ាន់ សូ ឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាក្រុងឡូវែល

***ខ្មែរផុសស.រ.អា.***

*បច្ចុប្បន្នជាសាស្ត្រាចារ្យវិទ្យាល័យឡូវែល តាំងពី១៨មកហើយ កាលពីអតីតកាលនៅកម្ពុជាជានាយទាហ៊ានវិជ្ជាជីវធ្លាប់ជាសមាជិកគណកម្មការនាយកអង្គការសមាគមនានាច្រើនដង លោក ប៉ាន សូ អាយុ៦៨ឆ្នាំ បានសម្រេចចិត្តឈរឈ្មោះជាដំណាងឱ្យប្រជាពលរដ្ឋឡូវែលបោះឆ្នោតជាសមាជិកក្រុមប្រឹក្សាសាលាក្រុងឡូវែលសម្រាប់អាណត្តិឆ្នាំ២០១៦-២០១៧នេះ ។*

*លោកទើបនឹងបានចេញសេចក្តីថ្លែងកាណ៏មួយ បញ្ជាក់ពីនយោបាយរបស់លោកដូចតទៅ :*

**ជូនចំពោះប្រជាពលរដ្ឋខ្មែរ ជាទីគោរព និងជាដំណឹង :**

ខ្ញុំឈ្មោះ ប៉ាន សូ (PAN SO) ជាបេក្ខជនសមាជិកក្រុមប្រឹក្សានៅទីក្រុងឡូវែល (Lowell City Councilor) ។ ខ្ញុំជាគ្រូបង្រៀននៅសាលាហៃស្គូលឡូវែល ។ មូលហេតុនៃការសំរេចចិត្តរបស់ខ្ញុំ:

**១-**សហរដ្ឋអាមេរិក ជាប្រទេសប្រជាធិបតេយ្យ ដូច្នេះសហគមន៏អាចនឹងរុងរឿងបាន លុះត្រាតែប្រជាពលរដ្ឋទាំងអស់យល់ និងចូលរួមក្នុងនយោបាយអាមេរិក ។ គឺរួមគ្នាបោះឆ្នោតរើសតំណាងក្នុងរដ្ឋាភិបាល ។

**២-** ដើម្បីរើសតំណាង លុះត្រាតែប្រជាពលរដ្ឋអាចពិភាក្សានូវបញ្ហាសំរាប់ដំណាងជួយដោះស្រាយ ។

**៣-** ដើម្បី និងអាចធ្វើការពិភាក្សាឱ្យបានគ្រប់ៗគ្នាយើងត្រូវរៀបប្រព័ន្ធទាក់ទងទូរទាំងសហគមន៏ ។

**៤-** ប្រព័ន្ធទាក់ទង គឺជាការរៀបសហគមន៏អោយមានរបៀបមួយដែលសមាជិកទាំងអស់អាចចូលរួមពិភាក្សាដោះស្រាយបញ្ហាដែលមានក្នុងសហគមន៏តាមរបៀបប្រជាធិបតេយ្យដោយមិនគិតពីជំនឿខុសៗគ្នាពីការរស់នៅពីសាសនា ឬពីបក្សនយោបាយ ។ ពោលគឺគិតពីគំនិតរួមធ្វើអោយសហគមន៏រីកចំរើននៅអនាគត ដោយជួយកូនចៅទាំងអស់អោយមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ។


លោក ប៉ាន សូ

**៥-** បញ្ហាសំខាន់ៗមាន

ក- រៀបចំរបៀបដឹកនាំថ្មីសំរាប់សហគមន៏

- ប្រព័ន្ធទាក់ទង

**ខ-**ការសិក្សា: សហគមន៏ រឺប្រទេសជាតិរុងរឿង លុះត្រាតែកូនចៅដែលជាអ្នកបន្តវេនមានតំរិះខ្ពង់ខ្ពស់ ។

**គ-**បង្កើតការងារ ។

**ឃ-** សន្តិសុខ ។

**ការស្នើសុំ:**សូមបោះឆ្នោតអោយខ្ញុំ!ខ្ញុំនឹងធ្វើតាមគំនិតបងប្អូន ឬធ្វើដូចតទៅ :

**១-**រៀបចំរបៀបខាងលើ តាមការពិភាក្សាជាមួយបងប្អូន ។ នេះជារបៀបប្រជាធិបតេយ្យដែលយើងត្រូវរៀបចំសំរាប់កូនចៅអោយធ្វើតាម ដើម្បីសេចក្តីសុខ និងរីកចំរើននៅអនាគតរបស់ពួកគេ ។

**តទៅទំព័រទី ១៣**


## យើងខ្ញុំយកចិត្តទុកដាក់ដើម្បីឲ្យលោកអ្នកញញឹម។
## *លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់!*





លោកអ្នកទទួលបានអត្ថប្រយោជន៍ទាំងអស់របស់លោកអ្នកនៅក្នុងកម្មវិធីស្តង់ដារ MassHealth និងកម្មវិធី Medicare រួមទាំងសេវាកម្មជាច្រើនទៀត។

- លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់ ដែលរួមមាន៖ *
  - ពិគ្រោះយោបល់នៅការិយាល័យ និងសម្អាតធ្មេញ
  - ដាក់ក្រាសធ្មេញទាំងមូលនិងដោយផ្នែក
  - ប៉ះធ្មេញ
  - ដាំធ្មេញ
- ចំណាយបដិភាគ $0 សម្រាប់គ្រប់សេវាកម្ម
- ប័ណ្ណ លោកអ្នកមានសុខភាពល្អ សម្រាប់ទិញទំនិញពាក់ព័ន្ធនឹងសុខភាពដែលមិនមានវេជ្ជបញ្ជា (រហូតដល់ $140ក្នុងមួយឆ្នាំ / $35 ក្នុងមួយត្រីមាស) *
- សេវាកម្មដឹកសមាជិកទៅកាន់និងមកពីកន្លែងណាត់ជួប *
- អាចហៅទូរស័ព្ទទៅកាន់សមាជិកក្រុមការងារនៃគម្រោង SWH បាន 24/7

SWH
SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅ:
**1-888-566-3526**(ខ្សែទូរស័ព្ទឥតគិតថ្លៃ) **TTY/TDD:711**
**www.seniorwholehealth.com/SNP**
យើងខ្ញុំបើកដំណើរការចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ ប្រាំពីរ (7) ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើលោកអ្នកមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធីស្តង់ដារ MassHealth ក៏ប៉ុន្តែមិនមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធី Medicare ផ្នែក A និង/ឬក៏ផ្នែក B លោកអ្នកប្រហែលជា អាចចុះឈ្មោះនៅក្នុងកម្មវិធីជម្រើសថែទាំសុខភាពមនុស្សចាស់ MassHealth Senior Care Options (SCO) របស់យើងខ្ញុំបាន។
លោកអ្នកដែលឆ្លើយតបទៅនឹងលក្ខខណ្ឌខាងលើអាចចុះឈ្មោះបានគ្រប់ពេលវេលារៀងរាល់ឆ្នាំ។

* *លក្ខខណ្ឌកំណត់អាចត្រូវបានអនុវត្ត*

គម្រោងសុខភាពទាំងមូលរបស់មនុស្សចាស់ គឺជាគម្រោងថែទាំសុខភាព HMO SNP ដែលមានការសម្របសម្រួល និងកិច្ចសន្យាផ្តល់- ទទួលសេវាកម្មនៃកម្មវិធី Medicare និងកិច្ចសន្យាជាមួយ Commonwealth of Massachusetts/កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះធ្វើឡើងដោយស្ម័គ្រចិត្ត និងអាស្រ័យទៅលើការបន្តកិច្ចសន្យាប្រចាំឆ្នាំ។ ព័ត៌មានអំពីអត្ថប្រយោជន៍នៅក្នុងឯកសារនេះ គឺជាសេចក្តីសង្ខេបមួយ មិនមែនជាសេចក្តីពិពណ៌នាលម្អិតអំពីអត្ថប្រយោជន៍ទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យគម្រោង។ លក្ខខណ្ឌកំណត់ ប្រាក់បដិភាគ ឬក៏លក្ខខណ្ឌកម្រិតផ្សេងៗទៀតអាចត្រូវបានអនុវត្ត។អត្ថប្រយោជន៍ របមន្ត បណ្តាញអ្នកផ្តល់សេវាកម្ម និងបណ្តាញឱសថស្ថាន អាចត្រូវបានផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករា នៃឆ្នាំនីមួយៗ។ លោកអ្នកត្រូវតែបន្តបង់បុព្វលាភផ្នែក B របស់លោកអ្នក ប្រសិនបើបុព្វលាភនោះមិនកំពុងត្រូវបានបង់ដោយភាគីណាមួយផ្សេងទៀតនៅឡើយទេ។ គម្រោងនេះត្រូវបានបង្កើតឡើងសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានជំនួយវេជ្ជសាស្ត្រដែលទទួលបានទាំងពីរដ្ឋ និងកម្មវិធី Medicare។
H2224_2015_104kh Accepted 12/7/2014

# បាតុកម្មខ្មែរ_ឡាវនៅវិមានកាពីតូល

**ដោយ ប៉ែន សុខផល**

**វ៉ាស៊ីនតោនឌីស៊ី:** ប្រជាពលរដ្ឋខ្មែរ ខ្មែរក្រោម ម៉ុងតាញ៉ា នឹងឡាវអាមេរិកាំងប្រមាណ ៦០០នាក់ បានទៅជួបជុំគ្នានៅមុខ "វិមានកាពីតូល" អាមេរិកាំងកាលថ្ងៃទី២៧ មិថុនានេះ ដើម្បីសំដែងការឈឺចាប់ចំពោះប្រទេសវៀតណាម ដែលបានឈ្លានពានប្រទេសកម្ពុជានឹងប្រទេសឡាវ នាឱកាសប៉ុន្មានថ្ងៃមុនបុណ្យឯករាជ្យស.រ.អា. "យូឡាយហ្វ័ត" នឹងមុនឱកាសដែល ង្វៀង ភូជុង អគ្គលេខាបក្សកុម្មុយនីតស្តវៀតណាមមកចុះហត្ថលេខាសេដ្ឋកិច្ចនឹងទិញអាវុធពីស.រ.អា. នៅថ្ងៃទី១០កក្កដាខាងមុខ។

ប្រជាពលរដ្ឋអាមេរិកាំងដើមកំណើតខ្មែរ ខ្មែរក្រោម ម៉ុងតាញ៉ា នឹងដើមកំណើតឡាវ មានប្រវត្តិត្រូវប្រទេសវៀតណាមឈ្លានពានដណ្ដើមយកបូរណភាពទឹកដីដូចគ្នា តាំងតែពីពី៣០ឆ្នាំមុនមកក្នុងពេលដែលប្រទេសទាំងពីរនេះជាប់វឹកវរដោយចលនាកុម្មុយនីស្តពីភពលោកនៅអាស៊ី ក្នុងប្រទេសរបស់ខ្លួន។

មកពីតំបន់ឆ្ងាយៗនៃសហរដ្ឋអាមេរិកមកចូលរួមប្រជុំធ្វើបាតុកម្ម ដូចជាសមាជិកគណបក្សសង្គ្រោះជាតិទៅពីឡូវែលរដ្ឋម៉ាសាឈូសិតទៅពីញូយ៉ក ពីហ្វីឡាដែលហ្វៀពីកាលីហ្វ័រញ៉ា ពីញូជើស៊ី នឹងពីវៀជីនៀសហគមន៍ឡាវនៅអាមេរិកក៏ដូចគ្នា ចេញថែមមកពី ន័រការ៉ូឡាយណា ជួបជុំគ្នា ដើម្បីបញ្ចេញមតិឱ្យប្រធានាធិបតីនឹងព្រឹទ្ធសមាជិកអាមេរិកាំងបានដឹងពីការឈឺចាប់របស់សហគមន៍ជនភាគតិចរងគ្រោះដោយប្រទេសវៀតណាម ដែលនៅតែបន្តរនយោបាយវាតទឹកដីឆ្លៀតឱកាសដែលពីភពលោកមូលមតិគ្នាបណ្ដេញកម្មុយនីស្តចេញពីកម្ពុជាពីឡាវ នឹងពីវៀតណាមខាងត្បូងនាអំឡុងឆ្នាំ១៩៧៨-៧៩បែជាទៅរំដោះយកប្រទេសទាំងនោះជាសម្បត្តរបស់ខ្លួនថែមទាំងធ្វើបាបដល់ប្រជាជនដែលខ្លួនថារំដោះបាននោះទៅវិញ ។










មិនមានមន្ត្រីផ្លូវការអាមេរិកាំងណាចេញមកទទួលបាតុករអាមេរិកាំង មកពីប្រទេសអាស៊ីអគ្នេយ៍ទេ ក៏ប៉ុន្តែញត្តិរបស់បាតុករបានត្រូវបញ្ជូនទៅដល់អ្នកកាន់អំណាចអាមេរិកាំង នឹងអ្នកកាសែត "វីអូអេ" ក៏នៅទីនោះ ដែលការផ្សព្វផ្សាយរបស់គេនឹងបានឮដល់ប្រទេសកម្ពុជានឹងឡាវនឹងវៀតណាមផងដែរ។

បាតុកម្មរួមប្រទេសដែលកម្រនឹងធ្វើបានផ្ដើមនៅម៉ោង១១ព្រឹក ចប់ទៅវិញ នៅវេលាម៉ោងពារសៀល ហើយក្រុមបាតុករក៏ចេញដំណើរយ៉ាងឆ្ងាយត្រឡប់មកផ្ទះសម្បែងវិញ ដោយគ្មាននឿយហត់ ពីព្រោះគេមិនបានបំភ្លេចប្រជាពលរដ្ឋរួមឈាមនៅក្នុងប្រទេសគេទេ៕

# គណបក្សសង្គ្រោះជាតិនៅអាមេរិកបែកជាបី

**ដោយ ខ្មែរផុសស.រ.អា.**

**ឡូវែល:** គ្មាននរណាយល់ច្បាស់ពីរចនាសម្ព័ន្ធគណបក្សសង្គ្រោះជាតិនៅសហរដ្ឋអាមេរិកនេះទៀតឡើយ បន្ទាប់ពីទស្សនកិច្ចលោកប្រធានគណបក្សនៅឡូវែលកាលពីថ្ងៃ២៤មក ។ ដោយចង់បានព័ត៌មានច្បាស់ពីការវិវត្តន៍ថ្មីៗចុងក្រោយនេះ យើងបានធ្វើបទសម្ភាសន៍ជាមួយលោក វណ្ណៈ ម៉ែន ជាប់ឆ្នោតជាប្រធានគណបក្សនៅស.រ.អា. ជំនួសលោក ស៊ុន្នួន ខឹម កាលពីថ្ងៃ១០ឧសភា ២០១៥ធ្វើនៅភោជនីយដ្ឋានសំពៅមាសមក ។ បន្ទាប់ពីដំណើរទស្សនកិច្ចលោក សម រង្ស៊ី មកទីក្រុងឡូវែលមក លោក ឆាន ទូច ក៏បានត្រូវលោក សម រង្ស៊ី តែងតាំងឱ្យទៅជាប្រធានសង្គ្រោះជាតិនៅស.រ.អា.ជំនួសលោក វណ្ណៈ ម៉ែន វិញ ចលនាមិនសប្បាយចិត្តនឹងទង្វើរបស់ប្រធានគណបក្សសង្គ្រោះជាតិបានផុសផុលឡើងសារជាថ្មីម្ដងទៀត បន្ទាប់ពីសមាជិកមួយចំនួនមានការ



ម៉ែន វណ្ណៈ



ឆាន ទូច

**តទៅទំព័រទី ២៣**

**Continued from page 01**

## Swearing in Ceremony ...

that the Asian American community is the fastest growing minority group in Massachusetts. The goal of the AAC is to recognize, as well as highlight, the vital contributions of Asian Americans to the social, cultural, economic and political life of the Commonwealth. Additionally, the AAC is involved in identifying and addressing the various needs and challenges that currently face the Asian American community. The Commission provides a permanent, effective voice for Asian Americans, and is comprised of 21 diverse members who are appointed by the Governor, Attorney General, Auditor, Senate President, Speaker of the House of Representatives, Secretary of State, and the Treasurer.

For more information **please visit http://www.aacommission.org/**



គណកម្មការ អេស៊ាន-អាមេរិកាំង ខុមុនវាំលរដ្ឋម៉ាសាឈូសិត

តមកពីទំព័រទី ១១

## លោក ប៉ាន សូ ឈរឈ្មោះជាបេក្ខជន...

**២-**ភារកិច្ចរបស់ខ្ញុំ គឺបំរើសហគមន៏ដោយនាំយកការសំរេចចិត្តរបស់សហគមន៏ទៅពិភាក្សាដោះស្រាយជាមួយរដ្ឋាភិបាលតាមលក្ខណៈដែលតម្រូវអោយធ្វើ។ រហូតមកដល់ថ្ងៃនេះ យើងមិនដែលបានទាមទារ ថវិការ បំរុងទុក ពីរដ្ឋាភិបាលមកអភិវឌ្ឍន៏សហគមន៏របស់យើងឡើយ។ យើងគួរចាប់ផ្តើមពីពេលនេះតទៅ។

**៣-**ខ្ញុំនិងរៀបចំអោយមានសាមគ្គីភាពក្នុងសហគមន៏ តាមរយៈប្រព័ន្ធទាក់ទង។ យើងរួមគ្នាដោះស្រាយបញ្ហាសង្គមខ្មែរ និងរៀបចំគំរូល្អដល់កូនចៅទៅអនាគត។

**៤-**ខ្ញុំនិងពិភាក្សាជាមួយបងប្អូន ដើម្បីធ្វើសហគមន៏នៅទីក្រុងឡូវែលឱ្យមានលក្ខណៈប្រជាធិបតេយ្យគំរូដល់សហគមន៏ដ៏ទៃទៀត។

**៥-**បង្កើតប្រព័ន្ធទាក់ទងគ្រប់សហគមន៏ខ្មែរទាំងអស់នៅសហរដ្ឋអាមេរិក និងទូរទៅទាំងពិភពលោក ដើម្បីខ្មែរអាចជួយគ្នា និងការពារគ្នាទៅវិញទៅមកទោះជារស់នៅកន្លែងណាក៏ដោយ។ អំណឹះតទៅ"គ្មានខ្មែរណាមួយគួររស់នៅដោយព្រួយបារម្ភណ៏ឡើយ"។ ខ្ញុំនិងពិភាក្សាជាមួយបងប្អូនបន្ថែមនៅពេលខាងមុខ។

**ដោយសេចក្តីគោរព និងរាប់អាន**

ប៉ាន សូ៦- ៩ -១៥ សូមអរគុណ។

**To Khmer people9**

Dear Sir/Madam

My name is PAN SO, a teacher at Lowell High School. I'm running for the position of Lowell councilor whose election will be held on November 3, 2015.

Background ideas

1- The United States of America is the best democratic in the world. Therefore, the community could prosper only when all of the people understand and participate in the American politics, meaning to come together to select the representatives in the government.

2- In order to select a representative people need to allocate the problems and issues then discuss and make decision for the representative to carry on for assistances from the government.

3- To include everyone in the discussion process, we need to establish a communication network throughout the community. The communication network will enable everyone to participate in the decision making process upon solving any community problems and issues, regardless the different background believes, whether in religions or politics.

4- Some important issues are:

a. Establish a new leadership system in the community – The communication network. It's the foundation of the democratic making decision process.

b. Education: The community could prosper only if the children have high education

c. Job creation: Organizing a Community Investors Committee (Usually, private investors) – Most of resources may be available at the fingers tips.

d.Safety & Security: Children with higher education and job availability are parts of the crime reduction. The collaboration between communities and government is another part for safety and security.

Proposal: Please, vote me for Lowell city councilor. I will be a person of your ideas or I will do the following at your consent.

1- Establishing the communication networkand starting to discuss to solve the most urgent problems and issues.

2- My duty is to facilitate the process of making decision and represent the community's decision by taking it to government office for further consideration. Until now we haven't claimed any budgets set aside for community development from the government. We should start it now.

3- Promoting unity in the community that would make Lowell a real democratic model for others.

4- Establishing the communication network between all Khmer communities in the U.S.A and around the world, so that Khmers could help and protect each other no matter where they are living. From now on, "NoKhmer should live in fear".

I will discuss with you more sometimes soon.

Best Regards,

Thank you,Pan So. 6/9/15




ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# រដ្ឋាភិបាលព្រងើយនឹងដីកាបង្គាប់ឱ្យចាប់ខ្លួន ឧក្រិដ្ឋជនសង្គ្រាមជាប់ចោទ

**ដោយ ឃួន ណារិម និង ហ៊ូលលី រ៉ូបិនស៊ិន |**

**June 18, 2015**

ឯកសារដែលប្រកាសជាចំហចេញដោយសាលាក្តីកាលពីថ្ងៃពុធបង្ហាញថា នគរបាលយុត្តិធម៌មិនបានព្រងើយនឹងដីកាចាប់ខ្លួន លោក មាស មុត អតីតមេបញ្ជាការកងទ័ពជើងទឹកខ្មែរក្រហម និងជាឧក្រិដ្ឋជនសង្គ្រាមជាប់ចោទដោយធ្វើឱ្យរដ្ឋាភិបាលបំពានច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

រួមជាមួយអតីតមេស្រុក អ៊ឹម ចែម លោក មាស មុត ក៏ជាប់ចោទដោយកំបាំងមុខពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិកាលពីខែមីនាដែរ។ ការខកខានរបស់រដ្ឋាភិបាល និងអង្គការសហប្រជាជាតិមិនបានចាប់ខ្លួនអ្នកទាំងពីរ គឺបង្ខំឱ្យចៅក្រមចេញការដីកាចោទប្រកាន់កំបាំងមុខបានរងការរិះគន់យ៉ាងខ្លាំងពីក្រុមអង្គការសិទ្ធិមនុស្ស។

ការសន្និដ្ឋានកើតមានជាទូទៅនៅពេលដែលអវតក បានចេញដីកាបង្គាប់ឱ្យចាប់ខ្លួន និងនៅពេលដែលនគរបាលយុត្តិធម៌មិនព្រមអនុវត្តតាមដីកា ប៉ុន្តែមិនមានការបញ្ជាក់ជាផ្លូវការទេ។

កាលពីថ្ងៃពុធសាលាក្តីខ្មែរក្រហមបានចេញឯកសារសម្ងាត់ពីមុនក្នុងនោះមានដីកាបង្គាប់ឱ្យចាប់ខ្លួនលោក មាស មុត ដែលចេញកាលពីថ្ងៃទី១០ខែធ្នូឆ្នាំ២០១៤ និងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លោក ម៉ាក ហាម៉ុន (Mark Harmon) ចោទគាត់ដោយកំបាំងមុខដែលរៀបរាប់យ៉ាងល្អិតល្អន់នូវការបដិសេធរបស់អតីតមេបញ្ជាការកងទ័ពជើងទឹករូបនេះថា មិនគោរពតាមដីកាកោះហៅឱ្យចូលខ្លួនកាលពីថ្ងៃទី២៦ខែវិច្ឆិកា និងការមិនសហការពីនគរបាលយុត្តិធម៌។

សេចក្តីសម្រេចនេះនិយាយថា នៅថ្ងៃទី១៩ខែធ្នូ តំណាងនគរបាលយុត្តិធម៌ម្នាក់បាននិយាយថាគាត់មិនអាចផ្តល់ "ការប៉ាន់ស្មានគួរឱ្យជឿបាន" ថា ពេលណាដីកានោះនឹងត្រូវអនុវត្ត និងថា សេចក្តីសម្រេចចុងក្រោយជាការទទួលខុសត្រូវរបស់គណៈកម្មការសន្តិសុខនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬយ៉ាងណាទេ។ សេចក្តីសម្រេចនិយាយថា លិខិតមួយច្បាប់ផ្ញើជូនគណៈកម្មការនេះមិនទទួលបានការឆ្លើយតបឡើយ ហើយពេលកំណត់ថ្ងៃទី១៨ខែកុម្ភៈនឹងនាំ មាស មុត មកជំនុំជម្រះនៅសាលាក្តីបានកន្លងផុត។

សេចក្តីសម្រេចនិយាយថា "ឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពេញចិត្តដែល មាស មុត មិនលាក់ខ្លួន គឺនគរបាលយុត្តិធម៌ដឹងទីកន្លែងដែល មាស មុត រស់នៅ គឺនគរបាលយុត្តិធម៌មានមធ្យោបាយទាក់ទងដើម្បីអនុវត្តដីកា ហើយពួកគេបានខកខានមិនបំពេញការទទួលខុសត្រូវរបស់ខ្លួនដែលប្រគល់អាណត្តិដោយកិច្ចព្រមព្រៀង អវតក ច្បាប់អវតក និងច្បាប់អន្តរជាតិ"។

ឯកសារក៏និយាយដែរថា នៅរវាងថ្ងៃទី១៥ខែកញ្ញាឆ្នាំមុនដល់ថ្ងៃទី៣ខែមីនាឆ្នាំនេះ ពេលដែល មាស មុត និង អ៊ឹម ចែម ត្រូវបានចោទប្រកាន់នោះ សាលាក្តីបានស្នើការធ្វើបច្ចុប្បន្នភាពលើការអនុវត្តដីកាចាប់ខ្លួនជនសង្ស័យដែលមិនប្រាប់ឈ្មោះទី២។

លោក ម៉ៅ ច័ន្ទតារា ប្រធានសន្តិសុខនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអះអាងថា លោកទើបតែបានទទួលដីកាចាប់ខ្លួននេះនៅសប្តាហ៍មុន។

ឧត្តមសេនីយ៍ ច័ន្ទតារា បានមានប្រសាសន៍ថា "មិនមានន័យថា យើងមិនអើពើនឹងដីកាអនុវត្តការចាប់ខ្លួននោះទេ ប៉ុន្តែមន្ត្រីរបស់យើងបានចុះទៅឱ្យភូមិរបស់ មាស មុត នៅខេត្តបាត់ដំបងដើម្បីសិក្សាផលប៉ះពាល់សង្គមសន្តិសុខ និងមតិប្រជាជន។ ដូច្នេះនៅពេលពួកគេត្រឡប់មកវិញ យើងនឹងធ្វើការវាយតម្លៃលើការចុះសិក្សារបស់ពួកគេ"។

នៅពេលសួរ ថាតើនគរបាលយុត្តិធម៌នឹងចាប់ខ្លួន មាស មុត ឬយ៉ាងណានោះ ឧត្តមសេនីយ៍ ច័ន្ទតារា បានឆ្លើយតបថា "ខ្ញុំមិនអាចនិយាយនៅពេលនេះបានឡើយ"។ លោកបានបដិសេធមិនឆ្លើយសំណួរថែមទៀតទេ។

មាស មុត ដែលជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មផ្សេងទៀតត្រូវគេចោទពីបទធ្វើវិសុទ្ធិកម្មទាហានរបស់ខ្លួនផ្ទាល់ និងសម្លាប់ជនបរទេសដែលចាប់បាននៅដែនសមុទ្របាននិយាយបន្ទាប់ពីរងការចោទប្រកាន់នោះថា លោក "ខ្វល់នឹងការដាំពោត និងដំឡូងមី" ជាងសកម្មភាពសាលាក្តី។ លោកបានបដិសេធការចោទប្រកាន់លើរូបលោក។

អ៊ឹម ចែម រងការចោទប្រកាន់ថា បានសម្របសម្រួលវិសុទ្ធិកម្មនិងការសម្លាប់នៅតំបន់ទិសពាយព្យ និងប្រឈមការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដែលគេសង្ស័យថា អ្នកស្រីបានប្រព្រឹត្តនៅមណ្ឌលសន្តិសុខ និងការដ្ឋានធ្វើការដែលអ្នកស្រីបដិសេធចោលទាំងអស់។

ការស៊ើបអង្កេតក្នុងសំណុំរឿង00៣និង 00៤

**តទៅទំព័រទី ១៥**

# Gov't Ignored Arrest Warrant For Accused War Criminal

**BY HOLLY ROBERTSON AND KHUON NARIM | JUNE 18, 2015**

Judicial police ignored an arrest warrant for former Khmer Rouge navy commander and accused war criminal Meas Muth, putting the government in breach of the rules of the Extraordinary Chambers in the Courts of Cambodia (ECCC), declassified documents released by the tribunal Wednesday show.

Along with former district commander Im Chaem, Meas Muth was also charged in absentia with crimes against humanity in March. The failure of the government and the U.N. to secure the pair's arrest—forcing the judge to issue charges in absentia—came under heavy criticism from rights groups.

Speculation was rife at the time that the ECCC had issued arrest warrants and that judicial police had refused to execute them, but there was no official confirmation.

On Wednesday, the Khmer Rouge tribunal released previously classified documents, including the arrest warrant for Meas Muth—dated December 10, 2014—and International Co-Investigating Judge Mark Harmon's decision to charge him in absentia, which details the former navy chief's refusal to heed a November 26 summons and the non-cooperation of the judicial police.

The decision states that on December 19, a judicial police representative said he was unable to give a "reliable estimate" for when the warrant would be executed and that the final decision rested with the ECCC's Security Commission. A letter to the commission went unanswered, it says, and a February 18 deadline to bring Meas Muth before the tribunal passed.

"The International CIJ [Co-Investigating Judge] is satisfied that Meas Muth is not in hiding; that the Judicial Police know where Meas Muth resides; that the Judicial Police have the material means to execute the Warrant; and that they have failed to discharge their responsibilities as mandated by the ECCC Agreement, ECCC Law, and the Internal Rules," the decision says.

The document also states that between September 15 last year and March 3 this year, when Meas Muth and Im Chaem were charged, the tribunal had been requesting updates on the execution of an arrest warrant for a second, unnamed suspect.

Mao Chandara, chief of security at the ECCC, claimed he only received the arrest warrant a week ago.

"It does not mean we have ignored the order to implement the arrest warrant, but our officials went down [to Meas Muth's village in Battambang province] to study the social impact, the security and the opinion of the people," General Chandara said. "So when they come back, we will do an evaluation of their study."

Asked if judicial police would then arrest Meas Muth, Gen. Chandara replied: "I cannot say right now." He declined to answer further questions.

Meas Muth—who among other crimes is accused of purging his own soldiers and killing foreigners captured at sea—said after being charged that he was more "concerned with planting my corn and cassava" than the actions of the tribunal. He denies the charges against him.

Im Chaem is accused of coordinating purges and executions in the Northwest Zone and faces charges for crimes she allegedly committed at a security center and worksite, all of which she denies.

Investigations in the Khmer Rouge tribunal's cases 003 and 004—which deal with crimes committed under Pol Pot by cadre who were not members of the highest echelon of the regime—began in 2009 and have long been resisted by the government, with even Prime Minister Hun Sen vocalizing his opposition to the cases.

Judge Harmon has been investigating the cases alone because his Cambodian counterpart, You Bunleng, has refused to assist. **Continued to Page 15**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# គណបក្សសង្គ្រោះជាតិគ្រោងកោះហៅ លោក ហ៊ុន សែន ទៅសាកសួរ

**ដោយគុច ណារ៉ែន** | **June 17, 2015**

លោក អ៊ុំ សំអាន តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិដែលបានជួយដឹកនាំយុទ្ធនាការរបស់គណបក្សប្រឆាំងក្នុងពេលថ្មីៗនេះ ដើម្បីលាតត្រដាងការលុកលុយរបស់វៀតណាមចូលក្នុងទឹកដីកម្ពុជា បានមានប្រសាសន៍កាលពីម្សិលមិញថា លោកគ្រោងកោះហៅលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យចូលសភាដើម្បីសាកសួរជុំវិញបញ្ហាខាងលើនេះ នៅពេលសភាបើកសម័យប្រជុំនៅខែក្រោយ ។

ក្នុងរយៈពេល១ខែមកនេះ លោក អ៊ុំ សំអាន រួមជាមួយលោក ម៉ៅ មុនីវណ្ណ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបានដឹកនាំការធ្វើដំណើរទៅកាន់តំបន់នានាតាមបណ្តោយព្រំដែនភាគខាងកើតរបស់កម្ពុជាក្នុងខេត្តត្បូងឃ្មុំ ខេត្តរតនគិរី និងខេត្តស្វាយរៀង ដែលនៅទីនោះអ្នកភូមិនិយាយថា ទាហាននិងជនស៊ីវិលវៀតណាមបានទន្ទ្រានចូលទឹកដីរបស់ពួកគាត់ ។

លោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំងបានមានប្រសាសន៍ថា ការធ្វើដំណើរចុះទៅពិនិត្យមើលព្រំដែនទាំងនេះ គឺជាផ្នែកនៃកិច្ចប្រឹងប្រែងមួយដើម្បីឱ្យរដ្ឋាភិបាលពិនិត្យសើរើឡើងវិញនូវសន្ធិសញ្ញាព្រំដែនបំពេញបន្ថែមឆ្នាំ២០០៥ដ៏ចម្រូងចម្រាសជាមួយវៀតណាម ហើយគណបក្សសង្គ្រោះជាតិបាននិងកំពុងជំរុញឱ្យបញ្ចេញផែនទីដែលរដ្ឋាភិបាលប្រើប្រាស់នៅក្នុងការអនុម័តសន្ធិសញ្ញានោះ ។

ក្រោយរដ្ឋាភិបាលបដិសេធមិនបញ្ចេញផែនទីទាំងនោះ លោក អ៊ុំ សំអាន បានមានប្រសាសន៍ថា គណបក្សសង្គ្រោះជាតិគ្មានជម្រើសឡើយក្រៅតែពីកោះហៅលោក ហ៊ុន សែន រួមជាមួយលោក ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស និងលោក វ៉ា គឹមហុង ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជាឱ្យមកបង្ហាញវត្តមាននៅចំពោះមុខសម័យប្រជុំសភាពេញអង្គ ។

តទៅទំព័រទី ២២

## តមកទំព័រទី ១៤ រដ្ឋាភិបាលព្រងើយនឹងដីកាបង្គាប់ឱ្យ...

របស់សាលាក្តីខ្មែរក្រហមដែលទាក់ទិននឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅសម័យ ប៉ុល ពត ដោយកម្មាភិបាលដែលមិនមែនជាសមាជិកថ្នាក់ខ្ពស់បំផុតនៃរបបនេះ បានចាប់ផ្តើមនៅឆ្នាំ២០០៩ ហើយមានការប្រឆាំងជំទាស់យូរមកហើយពីសំណាក់រដ្ឋាភិបាល សូម្បីតែលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បញ្ចេញការប្រឆាំងរបស់លោកចំពោះសំណុំរឿងទាំងនេះដែរ ។

ចៅក្រម ហាម៉ុន បាន និងកំពុងស៊ើបអង្កេតសំណុំរឿងនេះតែម្នាក់ឯង ពីព្រោះសមភាគីកម្ពុជារបស់លោក គឺលោក យូ ប៊ុនឡេង មិនព្រមជួយឡើយ ។ បុគ្គលិកកម្ពុជានៅសាលាក្តីនេះបានធ្វើតាមគំរូរបស់ចៅក្រមជាតិរូបនេះ ។

ក្នុងលិខិតមួយចុះផ្សាយដោយកាសែតថៃ ឌឹ ណេហ្សិន កាលពីថ្ងៃទី៤ខែមិថុនា លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសពេលនោះ បានបដិសេធថា លោក ហ៊ុន សែន និងរដ្ឋាភិបាលមិនបានជ្រៀតជ្រែកចូលក្នុងកិច្ចការរបស់សាលាក្តីលើសំណុំរឿង០០៣និង០០៤ទេ ។

លោក គួង បានសរសេរថា "តាមការពិត ចៅក្រមអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអញ្ជើញជនសង្ស័យបួននាក់មកសាកសួរប៉ុណ្ណោះ គឺម្នាក់សម្រាប់សំណុំរឿងលេខ០០៣ និងបីនាក់សម្រាប់សំណុំរឿងលេខ០០៤។ រហូតមកដល់ពេលនេះ គ្មានដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវបានចេញចំពោះមនុស្សទាំងនេះទេ" ។

លោក ជុំ សុន្ទរី អ្នកនាំពាក្យក្រសួងការបរទេសសព្វថ្ងៃបានមានប្រសាសន៍ថា លោកមិនអាចអត្ថាធិប្បាយអំពីលិខិតរបស់អ្នកកាន់ការមុនរបស់លោកបានទេ ពីព្រោះលោកមិនបានឃើញលិខិតនោះ ប៉ុន្តែលោកបានរំឭកឡើងវិញនូវជំហរជាសាធារណៈរបស់រដ្ឋាភិបាលអំពីសាលាក្តីនេះ ។

លោកបានមានប្រសាសន៍ថា "ជំហររបស់រដ្ឋាភិបាលកម្ពុជាច្បាស់លាស់ គឺមិនជ្រៀតជ្រែកចូលក្នុងកិច្ចការរបស់សាលាក្តីខ្មែរក្រហមទេ" ។

សេចក្តីសម្រេចមួយផ្សេងទៀតដែលចេញដោយចៅក្រម ហាម៉ុន កាលពីថ្ងៃពុធ បង្ហាញថាឯកសារសម្ងាត់ពីមុនបានឱ្យដឹងជាសាធារណៈ បន្ទាប់ពីក្រុមការពារក្តីរបស់លោក មាស មុត បានស្នើឱ្យមានការប្រកាសជាចំហនៃការដាក់ស្នើទាំងអស់ដែលពួកគេបានធ្វើទៅតុលាការមុនពេលលោកត្រូវមានឈ្មោះជាសាធារណៈថា ជាជនសង្ស័យ ។

ចៅក្រម ហាម៉ុន បានសម្រេចថា ឯកសារទាំងអស់គួរត្រូវបញ្ចេញឱ្យដឹង ដើម្បីឱ្យសាធារណជនអាចមើលយ៉ាងយកចិត្តទុកដាក់ "ជាអត្ថបទពេញលេញ និងត្រឹមត្រូវ" របស់ពួកគេ ៕ **និត**

# CNRP Plans to Summon Hun Sen for Questioning

**BY KUCH NAREN | JUNE 17, 2015**

CNRP lawmaker Um Sam An, who has helped lead the opposition's recent campaign to reveal Vietnamese incursions into Cambodian territory, said Tuesday that he plans to summon Prime Minister Hun Sen to the National Assembly for questioning over the issue when sittings resume next month.

Along with fellow CNRP lawmaker Mao Monyvann, Mr. Sam An has for the past month led trips to areas along Cambodia's eastern border in Tbong Khmum, Ratanakkiri and Svay Rieng provinces where villagers say Vietnamese soldiers and civilians have encroached on their land.

Opposition leader Sam Rainsy has said the trips are part of an effort to have the controversial 2005 supplemental border treaty with Vietnam re-examined, and the CNRP has been pushing for the release of the maps the government uses in enacting that treaty.

Following the government's refusals to release the maps, Mr. Sam An said the party has no choice but to summon Mr. Hun Sen—along with Foreign Minister Hor Namhong and border committee chairman Var Kimhong—to come before a full session of the National Assembly.

"We have requested the government give us the map but the government has repeatedly denied us, and there is no clear answer regarding the border issues, which we cannot accept," said Mr. Sam An, who as a student leader in 2005 protested against the border treaty with Vietnam.

"The reason for our plan to summon them is because, firstly, they declined to give us those maps and, secondly, because Prime Minister Hun Sen on Tuesday sent me some answers that did not address my concerns," he added.

Mr. Sam An said that he would ask the government leaders to reveal the names of two villages traded to Vietnam to allow Cambodia to retain the village in Kompong Cham province that National Assembly President Heng Samrin calls home.

"[Mr. Hun Sen] did not tell me the names of the villages and their locations and just stated that he already explained it in the National Assembly in 2012, but at that time he didn't name the villages that were swapped," he said.

Mr. Sam An said it was impossible—according to his copy of the 1952 map that the government says it uses as the basis for land swaps and demarcation with Vietnam—for Mr. Samrin's village to have been inside Vietnam, and thus to have required such a swap.

National Assembly spokesman Chheang Vun said the Assembly's standing committee would meet next week—following Friday's funeral proceedings for late CPP and Senate President Chea Sim—to schedule next month's agenda for sittings.

**Continued to Page 22**

**Continued from page 14**

# Gov't Ignored Arrest Warrant For...

Cambodian staff at the tribunal have followed the lead of the national judge.

In a letter published by Thai newspaper The Nation on June 4, then-Foreign Affairs Ministry spokesman Koy Koung denied that Mr. Hun Sen and the government had meddled in the tribunal's work on cases 003 and 004.

"As a matter of fact, the ECCC judges have invited four suspects for questioning only—one for Case No 003 and three for Case No 004," Mr. Koung wrote. "So far, no arrest warrants have been issued for these people."

The Foreign Affairs Ministry's current spokesman, Chum Sounry, said he could not comment on his predecessor's letter because he had not seen it, but reiterated the government's public position on the tribunal.

"The position of the Cambodian government is clear: not to interfere in the work of the Khmer Rouge tribunal," he said.

Another decision released by Judge Harmon on Wednesday shows that the previously classified documents were made public after Meas Muth's defense team requested the declassification of all submissions they had made to the court before he was publicly named as a suspect.

Judge Harmon ruled that all of the documents should be released so the public could peruse them in their "full and proper context."

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# សហភាពអឺរ៉ុបសន្យាផ្តល់មូលនិធិប្រហែល១១លានដុល្លារ សម្រាប់កំណែទម្រង់ការចុះឈ្មោះបោះឆ្នោត

**ដោយ គុច ណារ៉េន** | June 23, 2015

លោក ហង្ស ពុទ្ធា អ្នកនាំពាក្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានមានប្រសាសន៍កាលពីម្សិលមិញថា សហភាពអឺរ៉ុបបានសន្យាផ្តល់ប្រាក់ជាង១១លានដុល្លារដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) សម្រាប់រយៈពេល៣ឆ្នាំក្រោយ ដើម្បីជួយក្នុងការចុះឈ្មោះបោះឆ្នោតមុនការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០១៧ និងការបោះឆ្នោតជាតិឆ្នាំ២០១៨។

ចាប់តាំងពីការបង្កើតគ.ជ.ប.ដែលមានពីរគណបក្សកាលពីថ្ងៃទី១៣ ខែមេសា ដែលបានជំនួសគ.ជ.ប.ចាស់ដែលត្រូវបានចោទប្រកាន់ចំពោះភាពមិនប្រក្រតីដ៏រាលដាលជុំវិញការបោះឆ្នោតចាប់តាំងពីត្រូវបានបង្កើតឡើងកាលពីខែមករាឆ្នាំ១៩៩៨ សហភាពអឺរ៉ុប និងប្រទេសជប៉ុនកំពុងពិភាក្សាជាមួយសមាជិកគណៈកម្មការរបស់ខ្លួនអំពីលទ្ធភាពនៃការផ្តល់មូលនិធិនេះ។

លោក ហង្ស ពុទ្ធា បានមានប្រសាសន៍ថា លោក ហ្សង់ ហ្វ្រង់ស័រ កូតាំង



តទៅទំព័រទី ២៧

# EU Commits More Than $11 Million for Voter Registry Reform

**BY KUCH NAREN | JUNE 23, 2015**

The European Union has committed to provide more than $11 million to the National Election Committee (NEC) over the next three years to assist with voter registration before the 2017 commune elections and 2018 national election, election committee spokesman Hang Puthea said Monday.

Since the April 13 creation of the bipartisan NEC, which replaced the old NEC that had been accused of overseeing massive electoral irregularities since its formation in January 1998, the E.U. and Japan have been in talks with its commissioners over the possibility of providing funds.

E.U. Ambassador Jean-Francois Cautain on Monday called a meeting with the NEC, which is chaired by former CPP lawmaker Sik Bunhok, and announced that the E.U. Parliament would make 10 million euros (about $11.3 million) available to the NEC later this year, Mr. Puthea said.

"The European Union revealed that it would help provide 10 million euros, effective from January 2016 to 2019 for the period **Continued to Page 27**

# លោក ហ៊ុន សែន ក្លាយជាប្រធានគណបក្សប្រជាជនកម្ពុជាថ្មី និង មានអនុប្រធានថ្មីពីររូបទៀត

**ដោយម៉ិច ដារ៉ា** | June 22, 2015

រយៈពេលជិត២៥ឆ្នាំបន្ទាប់ពីគណបក្សប្រជាជនកម្ពុជាត្រូវបានបង្កើតឡើងគណបក្សកាន់អំណាចនេះកាលពីថ្ងៃសៅរ៍បានប្តូរថ្នាក់ដឹកនាំខ្លួនជាលើកដំបូង ដោយបានជ្រើសរើសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើជាប្រធានរបស់គណបក្ស និងលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស ខេង និងលោកប្រធានព្រឹទ្ធសភា សាយ ឈុំ ជាអនុប្រធាន។

បន្ទាប់ពីមរណភាពលោក ជា ស៊ីម នៅថ្ងៃទី៨ខែមិថុនា ជាមនុស្សដ៏មានឥទ្ធិពលនៃរបបកុម្មុយនិស្តនៅទសវត្សរ៍ឆ្នាំ១៩៨០ ដែលបានធ្វើជាប្រធានគណបក្សប្រជាជនកម្ពុជាពីពេលបង្កើតបក្សក្នុងឆ្នាំ១៩៩១ គណបក្សនេះបានធ្វើសន្និបាតពិសេសដើម្បីជ្រើសរើសលោក ហ៊ុន សែន អតីតអនុប្រធានបក្សឱ្យកាន់តំណែងនេះ និងជំនួសរូបលោកពីអនុប្រធាន។

លោក ស ខេង និងលោក សាយ ឈុំ ដែលជាអគ្គលេខាធិការរបស់គណបក្សប្រជាជនកម្ពុជាដែរ បានទទួលគោរមងារ "សម្តេច" នៅថ្ងៃទី១៤ខែមិថុនា ហើយអ្នកទាំងពីរជាមនុស្សជំនិតកាន់តំណែងអនុប្រធាននៅពេលលោក ហ៊ុន សែន លាលែងតំណែងនេះ។



ប៉ុន្តែសន្លឹកឆ្នោតដែលប្រគល់ទៅឱ្យសមាជិកគណៈកម្មាធិការកណ្តាល៥០៨នាក់ដែលមានវត្តមាននៅថ្ងៃសៅរ៍ មិនបានផ្តល់ឱកាសសម្រាប់ការជ្រើសរើសទេ ដោយសន្លឹកឆ្នោតតែមួយមានដាក់ឈ្មោះលោក ហ៊ុន សែន ជាប្រធាន និងទាំងលោក ខេង ទាំងលោក ឈុំ ជាអនុប្រធាន។ សមាជិកអាចត្រឹមតែ "យល់ព្រម" "មិនយល់ព្រម" ឬ "អនុបវាទ" ប៉ុណ្ណោះ។

សេចក្តីប្រកាសព័ត៌មានដែលចេញដោយគណបក្សប្រជាជនកម្ពុជាក្រោយពីសន្និបាតនោះបាននិយាយថា "សន្និបាតបានបន្តជ្រើសតាំងលោក ហ៊ុន សែន ដោយផ្ទាល់ និងជាសម្ងាត់ជាប្រធាន លោក ស ខេង ជាអនុ ប្រធាន និង សាយ ឈុំ ជាអនុប្រធាន"។

នៅល្ងាចថ្ងៃសៅរ៍ លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានសរសេរលើទំព័រហ្វេសប៊ុកផ្ទាល់របស់លោកថាសមាជិកតែម្នាក់ប៉ុណ្ណោះនៃគណៈកម្មាធិការកណ្តាលដែលមានវត្តមានមិនបានបោះឆ្នោតយល់ព្រមនឹងសន្លឹកឆ្នោតជាកញ្ចប់មានលោក ហ៊ុន សែន លោក ខេង និងលោក ឈុំ នោះទេ។

សេចក្តីប្រកាសព័ត៌មានរបស់គណបក្សប្រជាជនកម្ពុជាបាននិយាយដែរថា លោក ហ៊ុន សែន ត្រូវបានគេអះអាងបញ្ជាក់ជាថ្មីថាជាបេក្ខជននាយករដ្ឋមន្ត្រីសម្រាប់ការបោះឆ្នោតជាតិឆ្នាំ

តទៅទំព័រទី ២១



# អត្ថប្រយោជន៍បន្ថែម។ ចំណាយ $0។

ប្រសិនបើលោកអ្នកមានអាយុ 65 ឬចាស់ជាងនេះ និងមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard គំរោងរបស់យើងអាចផ្តល់ជូនលោកអ្នកនូវអត្ថប្រយោជន៍ច្រើនជាង Original Medicare។

ជាមួយនឹង UnitedHealthcare® Senior Care Options (HMO SNP) គ្រូពេទ្យ មន្ទីរពេទ្យ និងការចំណាយលើថ្នាំដែលមានវេជ្ជបញ្ជារបស់លោកអ្នកគឺស្ថិតនៅក្រោមប័ណ្ណដែលមានភាពងាយស្រួលមួយ។ លើសពីនេះ លោកអ្នកនឹងទទួលបានអត្ថប្រយោជន៍បន្ថែម--ដោយអ្នកឥតចំណាយអ្វីសោះ។ អត្ថប្រយោជន៍បន្ថែមទាំងនោះរួមមាន៖

- តម្លៃរួមចំណែក **$0** សម្រាប់ការសំអាតការប៉ះ និងការដាក់ធ្មេញ និងអ្វីៗជាច្រើនទៀត។
- តម្លៃរួមចំណែក **$0** សម្រាប់ថ្នាំដែលគេចេញថ្លៃឲ្យ។
- តម្លៃរួមចំណែក **$0** សម្រាប់វ៉ែនតា
- តម្លៃរួមចំណែក **$0** សម្រាប់ការធ្វើដំណើរទៅជួបវេជ្ជបណ្ឌិតតាមការណាត់។



ទូរស័ព្ទលេខ **1-781-888-7779, TTY 711**៖
នឹងភ្នាក់ងារក្នុងស្រុកដែលមានអាជ្ញាប័ណ្ណអាចជួយលោកអ្នក
ប្រសិនបើលោកអ្នកអាចទទួលអត្ថប្រយោជន៍បន្ថែមដោយមិន
ចំណាយអ្វីទាំងអស់។ [ឬ ចូលទៅ UHCCommunityPlan.com]។

UnitedHealthcare®
Community Plan

UnitedHealthcare SCO គឺជាគម្រោងថែទាំសុខភាពសម្របសម្រួលមួយ ដែលមានកិច្ចសន្យាជាមួយ Medicare និងជាប់កិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts Medicaid។ ការចុះឈ្មោះនៅក្នុងគម្រោងគឺផ្អែកទៅលើការបន្តកិច្ចសន្យាជាថ្មីនៃគម្រោងជាមួយ Medicare។ គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្ត ដែលអាចរកបានសម្រាប់អ្នកដែលមានវ័យចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare។ ប្រសិនបើលោកអ្នកមាន MassHealth Standard ប៉ុន្តែលោកអ្នកមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ Original Medicare លោកអ្នកនៅតែមានសិទ្ធិក្នុងការចុះឈ្មោះក្នុងគម្រោង MassHealth Senior Care Option និងទទួលអត្ថប្រយោជន៍ MassHealth ទាំងអស់របស់លោកអ្នកតាមរយៈកម្មវិធី SCO របស់យើង។ ព័ត៌មានអត្ថប្រយោជន៍ដែលបានផ្តល់គឺជាសេចក្តីសង្ខេបខ្លី មិនមែនជាការពិពណ៌នាពេញលេញនៃអត្ថប្រយោជន៍ទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោង។ ការកំហិត -តម្លៃរួមចំណែក និងការកំរិតដទៃទៀតអាចត្រូវយកមកអនុវត្ត។ អត្ថប្រយោជន៍ ការផ្សំរូបមន្ត បណ្តាញឱសថ បណ្តាញគ្រូពេទ្យផ្តល់សេវា ប្រាក់បង់ប្រចាំខែ និង/ឬ ថ្លៃបង់រួមផ្សំពេលទៅពេទ្យម្តងៗ/សហធានាធាប់រ៉ាប់រងអាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ ព្រីមៀម ថ្លៃបង់រួមផ្សំពេលទៅពេទ្យម្តងៗ សហធានាធាប់រ៉ាប់រង និង ថ្លៃបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ ប្រហែលជាខុសៗគ្នាទៅតាមកម្រិតនៃជំនួយបន្ថែម ដែលអ្នកទទួល។ សូមទាក់ទងមកគម្រោងសម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។ អ្នកចុះឈ្មោះមិនតម្រូវឲ្យបង់ប្រាក់ពីហោប៉ៅទេ។

H2226_150326_160615KM
UHCSCO_150326_160615KM

CST7822

# Lowell General Hospital Sponsors ALIVE by Photographer Kim Hak at Ayer Lofts Art Gallery in Lowell

*Proceeds Benefit the Sihanouk Hospital Center of HOPE and the Sonja Kill Memorial Hospital in Cambodia*

LOWELL, MA -Lowell General Hospital is sponsoring the exhibit ALIVE featuring photographs by artist Kim Hak this June at the Ayer Lofts Art Gallery, 172 Middle Street in Lowell, Massachusetts. ALIVE is Hak's personal concept to reveal the intimate memory of old photos and usual objects entrusted to him by local Cambodian families, forty years after the Khmer Rouge Regime. The artful and reverential way in which the objects are photographed reveals insights into their preciousness -often secured and sequestered through the horrible years of the Khmer Rouge regime in Cambodia between 1975 and 1979.

*"All these photographs and objects are deeply significant," Hak says. "They are evidence of the past time in history. War can kill victims, but it cannot kill memory of the survivors. The memory should be alive, known and shared for the current research of human beings, and the preservation of heritage for the next generations."*

ALIVE will be open from noon to 4:00 p.m. each Saturday and Sunday during the month of June, beginning Saturday, June 6 and running through Sunday, June 28, 2015. Proceeds from the sale of each of the 12 pieces, which range from $500 to $1,000, will benefit the Sihanouk Hospital Center of HOPE and the Sonja Kill Memorial Hospital in Cambodia.

"Lowell General Hospital is proud to support this compelling exhibit," says Amy Hoey, Chief Operating Officer of Lowell General Hospital and Circle Health. "We were honored to recently establish a relationship with Sihanouk Hospital Center of HOPE and Sonja Kill Memorial Hospital in Cambodia in late 2014 to form what is often called a "sister hospital" relationship. We look forward to working together to share best practices from our respective organizations, and helping each other better meet the unique health and cultural needs of members of the Cambodian community, both here in Greater Lowell and in Cambodia as well."

គិម ហាក់ តាំងពិព័រណ៍ស្នាដៃរបស់ខ្លួននៅ"ឡូជេណេរាល់ហុសពីថល"នាខែមិថុនានេះ



គិម ហាក់និយាយថា "រូបថតនឹងរបស់តាំងទាំងអស់នោះ មានន័យយ៉ាងជ្រាលជ្រៅ គឺជាភស្តុតាងនៃប្រវត្តិអតីតកាលសង្គ្រាមអាចសម្លាប់ជនរងគ្រោះ តែមិនអាសម្លាប់ការចងចាំបានទេ" ផលចំណេញនៃពិព័រណ៍នេះ នឹងយកទៅជួយពេទ្យកុមារសីហនុនឹងពេទ្យអនុស្សវរីយសុងចាគីលនៅកម្ពុជា ៕

តមកទំព័រទី ០១

## វិបត្តិនយោបាយនៅព្រះរាជាណាចក្រ...

ត្រួតពិនិត្យប្រជាជនយួនចូលមកក្នុងដែនដីខ្មែរកងកំលាំងនេះនឹងត្រូវដកចេញពីតំបន់នេះភ្លាម ។

កាលពីថ្ងៃទី០៨ មិថុនា ឆ្នាំ ២០១៥ ខ្ញុំបានថ្លែងនៅពេលប្រជុំពេញអង្គនៅរដ្ឋសភាថា "នៅថ្ងៃនឹងពេលនេះនៅតំបន់ទល់ដែន ឃុំកក់ញ៉ែ ស្រុកអូរយ៉ាដា ខេត្តរតនគិរី មានតំណាងរាស្ត្រជាច្រើនរូបមកពីគណបក្សសង្គ្រោះជាតិដឹកនាំដោយលោកម៉ៅ មូលនីវណ្ណ តំណាងរាស្ត្រកំពង់ចាម ដែលមានលោកជាមចន្ទនី កង គិមហាក់ អ៊ុំ សំអាន ព្រឹទ្ធសភាម្នាក់លោកស្រី ថាក់លានី និងប្រជាពលរដ្ឋជាច្រើនបានចុះទៅទល់ដែន ហើយខ្ញុំសង្ឃឹមថាប្រជាពលរដ្ឋអស់នេះ នឹងមិនទៅធ្វើឱ្យខូចបង្គោលព្រំដែនអាចនឹងទទួលការផ្តន្ទាទោសដូចមាត្រា ៤១១ នេះទេ ។

តាមមើលត្រង់ចំណុចនេះ គឺចែងច្បាប់ដោយមានផ្តត់គំនិតនៅក្រោមអាណានិគមបរទេស ហើយសរសេរក្រោមការកៀបសង្កត់បរទេស ។ ហើយច្បាប់ផ្សេងខ្លះទៀតចែងទៅតាមចំណង់របស់មនុស្សខ្លះ ដោយមិនគិតពីភាពយុត្តធមិ និងទ្រឹស្តីច្បាប់នោះទេ គឺមានគោលបំណងតែម៉្យាង គឺដើម្បីរំខានដល់ពួកដែលប្រឆាំងនឹងខ្លួន ។ នៅពេលនេះ ព្រះរាជាណាចក្រកម្ពុជាបានឯករាជ្យពេញលេញតាំងពីថ្ងៃទី ២៣ តុលា ១៩៩១ ហេតុនេះរដ្ឋសភាគួរតែស្នើលុបច្បាប់ខ្លះ ឬស្នើវិសោធកម្មច្បាប់ផ្សេងៗឱ្យសមស្របទៅតាមប្រទេសឯករាជ្យនិតិរដ្ឋ និងស្របទៅតាមគំនិតរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

ពីដើមព្រះរាជាណាចក្រកម្ពុជាមានច្រកចេញទៅសមុទ្រអន្តរជាតិបានដោយមិនចាំបាច់សុំអនុញ្ញាតពីប្រទេសជិតខាងដូចសព្វថ្ងៃនេះទេ ។ ហើយកប៉ាល់ដឹកឥវ៉ាន់មកភ្នំពេញយួនហាមមិនឱ្យដឹកកាត់តាមដែរគេ ចំពោះឥវ៉ាន់ប្រើប្រាស់ហើយនោះគឺទាល់តែឥវ៉ាន់ថ្មី ។ នេះគឺគេមានបំណងចង់ខ្ទប់សកម្មភាពផែរស្វ័យតភ្នំពេញតែ





ប៉ុណ្ណោះ គង់តែអនុសញ្ញាអន្តរជាតិមានយ៉ាងដូចម្តេចក៏ដោយ ក៏យួនរំលោភលើខ្មែរដែរ ។

ចំណែកកងកំលាំងខ្មែរដែលយាមតាមព្រំប្រទល់ដែន ដូចជាគោរពបញ្ជាទាហ៊ានយួន បើយ៉ាងដូច្នេះ តើកងកំលាំងខ្មែរអាចការពារផលប្រយោជន៏ជាតិ និងប្រជាពលរដ្ឋនៅតាមប្រទល់ដែនបានឬទេ ? ប្រជាពលរដ្ឋនៅតាមប្រទល់ដែនត្រង់ដែលគេហៅថាតំបន់សរគេហាមមិនឱ្យដាំដំណាំទេ ដោយទាហ៊ានយួនចូលមកដកចោលល្បិចនេះគឺធ្វើឱ្យប្រជាពលរដ្ឋនៅតាមប្រទល់ដែនរស់នៅមិនកើត ហើយរត់ចោលកន្លែងដោយទុកឱ្យទំនេរ ហើយប្រជាពលរដ្ឋយួននឹងមកតាំងទី ។ ហេតុនេះសូមសភាមេត្តាពិចារណាឱ្យបានដិតដល់ពីភាពបាត់បង់បូរណភាពទឹកដីរបស់យើងដែលយើងទាំងអស់គ្នាត្រូវតែការពារ ដែលបណ្តាលឱ្យមានប្រតិកម្មដ៏ខ្លាំងពីលោក ហ៊ុន សែន ។ ឯក្រសួងការបរទេសកម្ពុជា ក៏បានចេញកំណត់ទូតស្នើទៅប្រទេសវៀតណាមនៅថ្ងៃទី១២ ទី១៤ និងទី១៧ មិថុនា តែរដ្ឋាភិបាលកុម្មុយនីស្តវៀតណាមមិនទាន់ឆ្លើយតបនៅឡើយសូម្បីតែមួយម៉ាត់ក៏អត់ដែរ ។

ស្ថានភាពដ៏ធ្ងន់ធ្ងរនេះរាជរដ្ឋាភិបាលខ្មែរត្រូវតែរួមកំលាំងនយោបាយទាំងអស់ដោះស្រាយបញ្ហានេះ ដែលក្រុមអ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបានធ្វើសេចក្តីថ្លែងការណ៏កាលពីថ្ងៃទី ២៥ ខែមិថុនា នេះ ។

នៅថ្ងៃទី១៩ខែធ្នូ ឆ្នាំ២០១៤នៅវិមានរដ្ឋសភាសភាពេញអង្គបានប្រជុំសំរេចស្តីពីសេចក្តីស្នើវិសោធនកម្មជំពូកទី១២ ប្រការ ៤៨ ថ្មី (ពីរ) ពីបទបញ្ជាផ្ទៃក្នុងរបស់សភាក្រោមការយល់ព្រមរវាងគណបក្សទាំងពីរ ដែលមានអាសនៈនៅសភាក្នុងគំនិតសន្ទនារវាងគណបក្សទាំងពីរដែលគេនាំគ្នាហៅថា "វប្បធមិសន្ទនា" ។ ប្រការនេះចែងថា: "ប្រធានក្រុមតំណាងរាស្ត្រនៃគណបក្សនយោបាយក្រៅរដ្ឋាភិបាលដែលមានអាសនៈក្នុងរដ្ឋសភាចាប់ពី២៥ភាគរយឡើងទៅមានឈ្មោះហៅថា ប្រធានក្រុមមតិភាគតិចនៅរដ្ឋសភា ។ ប្រធានក្រុមមតិភាគតិចជាគូសន្ទនាជាមួយនឹងប្រមុខរាជរដ្ឋាភិបាលទាក់ទងទៅនឹងបញ្ហាប្រទេសជាតិ ។ ប្រធានក្រុមមតិភាគតិចមានឋានៈស្មើនាយករដ្ឋមន្ត្រី" ។

ឥឡូវនេះនៅព្រះរាជាណាចក្រកម្ពុជាមានវិបត្តិនយោបាយពីបញ្ហាព្រំដែនកម្ពុជា-វៀតណាមជាច្រើនចំណុចនៅតាមទល់ដែននេះជាបញ្ហាប្រទេសជាតិ ។ តែបើតាមខ្ញុំដឹងមកដល់ថ្ងៃនេះរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជាអត់បានទាក់ទងជាមួយប្រធានក្រុមមតិភាគតិចលោកប្រធាន សម រង្ស៊ី ដែលមានឋានៈស្មើនាយករដ្ឋមន្ត្រីមកសន្ទនានោះទេ ។ បើតាមខ្ញុំយល់រាជរដ្ឋាភិបាលត្រូវតែទាក់ទងនឹងកំលាំងនយោបាយខ្មែរទាំងអស់ ដើម្បីសន្ទនារកគំនិតដោះស្រាយបញ្ហាអធិបតេយ្យភាពប្រទេសយើង ។

តាមមើលអ្នកដឹកនាំរាជរដ្ឋាភិបាលមិនយល់យ៉ាងដូច្នេះទេពីវប្បធមិសន្ទនានេះ ។ បើតាមការចំណាំរបស់ខ្ញុំពីវប្បធមិសន្ទនានោះ គឺត្រឹមតែប្រមុខរាជរដ្ឋាភិបាល និងប្រធានក្រុមមតិភាគតិចដែលមានឋានៈស្មើនាយករដ្ឋមន្ត្រីដឹកដៃគ្នាទៅកាត់អន្ទ្យមនៅប្រសាទអង្គរដឹកដៃគ្នាទៅលេងនៅម៉ាឡេតែប៉ុណ្ណោះ ។ បើត្រឹមតែយ៉ាងដូច្នេះទេ ខ្ញុំសុំជូនយោបល់ថែមទៀត គួរតែដឹកដៃគ្នាទៅលេង កូរេ ថៃ អូស្រាលី អឺរុប អាមេរិកទៀត ដែលនៅទីនោះ ប្រជាពលរដ្ឋខ្មែរគេស្អប់លោក ហ៊ុន សែន ជាខ្លាំង ដើម្បីឱ្យពួកអស់នេះមកជំរាបសួរ និង សន្ទនា ជាមួយលោក ហ៊ុន សែន ។ នេះហើយដែលលោក ហ៊ុនសែន ហៅថានយោបាយ " ឈ្នះ- ឈ្នះ" នោះ ។

**លិម គិមយ៉ា**
**តំណាងរាស្ត្រមណ្ឌលកំពង់ធំ**
**សមាជិកគណៈកម្មការសេដ្ឋកិច្ចហិរញ្ញវត្ថុធនាគារនិងសវនកម្មនៃរដ្ឋសភា**



## AMERICAN MUFFLER & BRAKE

យានដ្ឋានខ្មែរជួសជុលរថយន្តទូទៅតម្លៃសមរម្យ



Known as A muffler man. Customize pipe, exhaust & welding. come to see us we can make the different.

Shock & Struts, Tune-up, Axle Trans, Timing Belt, Customized Pipe Exhaust Clutch, Water Pump, Starter and much more...

WE FIX-U $SAVE

1380 Park Ave.
Cranston, RI 02920
Cell: 203-522-2174
www. amufflerman.com

Monday-Saturday
8:00 am-7:00 pm
Phone: 401-944-3390

Open Sunday
9:00 am-3:00 pm
Fax: 401-944-3390

**Mony, Chay, Sokheang, Sokheng & Jimmy**

WE ARE AT FIVE LOCATIONS

| | | | |
|---|---|---|---|
| 1412 Park Ave. | 335 Whalley Ave. | 1355 South Main St. | 219N. Colony Rd. |
| Bridgeport, CT 06604 | New Haven, CT 06511 | Waterbury, CT 06706 | Wallingford, CT 06492 |
| (203) 333- 0355 | (203) 777- 9800 | (203) 757-7575 | (203) 284-0861 |

## BUSINESS FOR SALE
## HENG EXPRESS

## លក់ភោជនីយដ្ឋានអាស៊ីនៅរ៉ូដអាយឡិន

Dine in-Take out
536 Cranston St.
Providence, RI 2907
18 Years in Business. Rent $1,000 per month, property tax is not included. Help training 1 month after purchased business. Call Soknieng at **401-274-6660**

## រកអ្នកធ្វើការ -ជាងធ្វើក្រចកស្រី ឬបុរស

ប្រាក់ខែជូនទៅតាមបទពិសោធន៏ពី $៥០០-$១.០០០ ក្នុង១អាទិត្យ
កន្លែងធ្វើការរវល់ច្រើន
Trenton, NJ ចម្ងាយ៤៥នាទី ពីហ្វីឡាដែលហ្វៀ
សម្រាប់អ្នកនៅឆ្ងាយមានកន្លែងឱ្យសំណាក់
ទូរស័ព្ទ : **609-227 1939**

## Help wanted – Nail Tecknician M or F

Salary base on experience $500-$1,000/week
Busy location, Trenton, NJ 45mn.from Phylly
For long distance, Provided accommodation
Call **609-227 1937**

## Your classify ad is here for only $50 per month

ពាណិជ្ជកម្មរបស់អ្នកនៅទីនេះ
ចំណាយចំណាយត្រឹមតែ
**$50** ក្នុង១ខែ

***CALL:***
***978.677.7163***

*EMAIL: SOBENPIN@KHMERPOST.US*

## សិក្សាពីឥស្លាម

**សួរ :** មានចម្ងល់អ្វីទេពីឥស្លាម?
**ឆ្លើយ :** សូមទៅមើលគេហទំព័រ www.peacetv.tv ឬគេហទំព័រមួយទៀត www.gainpeace.com.
Q) Any Questions on Islam?
A)watch www.peacetv.tv
visit www.gainpeace.com.



## CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៏ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

**ការធានារ៉ាប់រងគ្រួសារ**
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្កការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

**ការធានារ៉ាប់រងជំនួញ**
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខ៏ខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

## ខូម័រ សិប្បកម្មឆ្លាក់បសំណាកក្រានីត
## COLMER MONUMENT WORKS

Memorials of Distinction
អាសយដ្ឋាន:1025 Lawrence Street Lowell, MA 01852-4898
**(978) 452-7821**



| | |
|---|---|
| Granite Memorials | ផ្នូររាងបញ្ឈរធ្វើពីថ្មក្រានីត |
| Granite & Bronze Markers | ផ្នូរផ្តេកមានឆ្លាក់ស៊ីរីទ្ធលេថ្មក្រានីត |
| Cemetery Lettering in Khmer | មានឆ្លាក់អក្សរខ្មែរលើថ្មនៃផ្នូរ |

COLMER Monument Works

ភាពថ្លៃថ្នូរ កិត្តិយស និងការគោរពជូនលោកអ្នក
*Honor. Dignity. Respect for All*

តពីលេខមុន

រៀបរៀងដោយ សាគូ សាមុត
និង ថៃ មករា

# វប្បធម៌សន្ទនា

សិក្ខាសាលា ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥
នៅទីក្រុងប៉ារីស ប្រទេសបារាំង

ក្រោមអធិបតីភាព
**លោកប្រធាន សម រង្ស៊ី**

---៚៚៚✻៙៙៙---

## ០៦ – លោកស្រី ជូឡុង សូមូរ៉ា



ប្រវត្តិសាស្ត្រថ្មីៗ ទស្សវត្សទី៦០ ទី៧០ ទី៨០ ។ លោក នែលសុន ម៉ន់ដេឡា បានប្រើប្រាស់ជាដំបូង ក្នុងការតស៊ូរបស់គាត់ គឺអំពើហិង្សា ។ ករណីអាហ្វ្រិកនេះ គឺជាករណីធ្ងន់បំផុត ជាងប្រទេសខ្មែរយើងទៅទៀត ។ ដូចជាឧទាហរណ៍ គឺ ក្នុងរដ្ឋធម្មនុញ្ញ មាត្រាទី ១ របស់គេ គឺបានបែងចែកសង្គមរបស់ខ្លួនតាម ពណ៌សម្បុរស្បែក ៖ ស្បែកសដែលមានម្ដាយឪពុកមកពីប្រទេសហូឡង់ដ៍, ឪពុកឬម្ដាយ ជាជាតិអង់គ្លេស, កូនកាត់, អ្នកស្រដៀងឥណ្ឌា និងចុងក្រោយគឺពួកស្បែកខ្មៅ ។ ដល់ពេលមួយ មិនមែនតែពួក ស្បែកខ្មៅសំលាប់ពួកស្បែកសប៉ុណ្ណោះទេ គឺពួកស្បែកខ្មៅសំលាប់ពួកស្បែកខ្មៅខ្លួនឯងដែរ ។ គាត់យល់ថា អំពើហិង្សានេះនឹងបន្សល់នៅក្នុងសង្គមរបស់ប្រទេសគាត់ ។ គាត់ក៏ចាប់ផ្ដើមបញ្ចេញអាកប្បកិរិយាបែបអហិង្សា យល់អំពីបញ្ហារបស់អ្នកដទៃទៀត តាំងពីគាត់នៅជាប់ក្នុងគុកនៅឡើយ ។ ពួកស្បែកស ឃើញដូច្នោះ ក៏ស្មានថាទន់ភ្លន់ស្មើនឹងទន់ជ្រាយ ហើយបានប្រើមធ្យោបាយតែមួយ និង ដដែលៗ រាល់ការជួបគ្នាជាមួយគាត់ ដោយនិយាយថា យើងអាចធ្វើការជាមួយ អ្នកឯងបាន តែសហការីរបស់អ្នកឯងមិនល្អទេ ។ ប្រពន្ធ កូនស្រីៗ និងមនុស្សរបស់គាត់ក៏ផ្ដន្ទាទោសគាត់ ខឹងនឹងគាត់ខ្លាំងណាស់ក្នុងរឿងអហិង្សានេះ ដោយបានចោទគាត់ថាក្បត់



ចិត្តសកម្មជនដែលបានស្លាប់ ទន់ជ្រាយ ត្រូវគេទិញក្បាល ។ ទីបញ្ចប់គាត់ បានឆ្លើយវិញថា ពេលនាដែលគូប្រជែងរបស់យើង ចង់សន្ទនាជាមួយយើង វាល្អជាងគេចង់កំចាត់យើង ។ ហើយនៅពេលណាដែលគូប្រជែងនោះ សូមសន្ទនាជាមួយយើង មានន័យថា គេយល់ហើយ គឺមកពីយើងមានកំលាំងខ្លាំង ឯកំលាំងរបស់គេកំពុងតែទន់ខ្សោយហើយ ។ គាត់បានបញ្ជាក់ទៅពួកស្បែកសឲ្យយល់ថា នៅពេលណាដែលពួកគាត់ឈ្នះ ពួកគាត់នឹងមិនប្រព្រឹត្តអំពើឃោរឃៅ អំពើហិង្សា អំពើពុករលួយដូចពួកស្បែកស តែងតែធ្វើមកលើពួកស្បែកខ្មៅឡើយ ។ បើពួកខ្ញុំស្មើនឹងអ្នកឯង គឺមិនមែនស្មើក្នុងអំពើអាក្រក់ទេ គឺស្មើក្នុងលទ្ធភាព និងអំពើល្អ ។ គាត់មានភារកិច្ចដ៏លំបាកមួយទៀត គឺទាមទារឲ្យពួកស្បែកខ្មៅមានសិទ្ធិបោះឆ្នោត ។ ការចង់បានអំណាចហ្នឹង គឺមិនមែនសំរាប់នៅស្មៀមដើរលេង ដេកស៊ីនោះទេ គឺចង់កសាងស្រុកឲ្យទៅជាអរិយប្រទេស ដែលមានភាពជឿនលឿន ហើយអភិវឌ្ឍសេដ្ឋកិច្ចឲ្យត្រឹមត្រូវ ។ ក្រោយពីប្រទេសគាត់ទទួលសន្តិភាព មកវិញជាលទ្ធផលគឺប្រទេសរបស់គាត់ បានជោគជ័យផ្នែកសេដ្ឋកិច្ចខ្លាំងជាងប្រទេសអាហ្វ្រិកដទៃទៀត និងប្រទសមួយចំនួននៅអាស៊ី ។

ជាទីបញ្ចប់លោកស្រីបានអំពាវនាវដល់ អ្នកដែលនៅស្ទាក់ស្ទើ មិនទាន់យល់អំពីរឿងនេះ ថាទុកឲ្យពេលវេលាជាអ្នកបញ្ជាក់ នូវលទ្ធផលនាពេលអនាគត ។

វីដេអូ ៖ https://www.youtube.com/watch?v=d8S3b_xl_F8

១២ម៉៤៧ ដល់ ១៤ម៉០០ ពិសាភោជនិយហារថ្ងៃត្រង់។



## ០៧ – លោក សាគូ សាម៉ុត



លោកបានអាន អត្ថបទរបស់អាចារ្យ ហ្រ្វង់ស្វ័រ ប៉ុងសូ ៖ ខ្សែបន្ទាត់នយោបាយ ចុងក្រោយ របស់ប្រទេសកម្ពុជាសព្វថ្ងៃ គឺការបង្កើត វប្បធម៌សន្ទនា ។ ការរៀបចំ គ.ជ.ប. ឡើងវិញ ដើម្បីឲ្យមានតម្លាភាពនិងមានកំហុសតិចជាងមុន។ គណបក្សទាំងពីរបានចេញលិខិតណែនាំមួយ ដើម្បីអនុវត្តវប្បធម៌នេះ ។ ខ្ញុំគិតថា គណបក្សសង្គ្រោះជាតិ គឺជាសំលេងតែមួយគត់សំរាប់កសាងរួមគ្នានូវ អនាគតរបស់ប្រទេស ។

អត្ថបទដើមជាភាសាបារាំង ៖

Au Cambodge, la vie politique des derniers mois s'est caractérisée par la création d'une "Culture du dialogue" entre les deux partis politiques : le Parti du Peuple Cambodgien (PPC), au pouvoir, et le Parti du Salut National Cambodgien (PSNC), de Sam Rainsy). Après cinq mois de discussions difficiles, les deux camps se sont mis d'accord sur l'aménagement d'un Comité Electoral National (CEN), en principe neutre, qui pilotera les futures élections de 2018, avec, espérons-le, plus de transparence et moins de fraudes. La loi électorale a été également revisée et modifiée. Tout n'est pas parfait, mais l'espoir est là. La base du PSNC rechigne, mais personnellement, je pense que c'est l'unique voie pour construire ensemble l'avenir du pays. Il vrai que le parti au pouvoir ne tient pas à quitter ses privilèges exorbitants. Le Premier minister tient désormais à utiliser cette " culture du dialogue" pour interdire toute critique, qualifiée comme autant d'insulte ou de diffamation. Un code de conduite entre les deux parties vient d'être mis sur pieds... វីដេអូ៖ https://www.youtube.com/watch?v=q0zI0XnWQcQ



## ០៨ – កញ្ញា ហាឡូ ម៉ារី



កញ្ញាបានអានអត្ថបទ របស់លោក រដ្ឋ ហ្សង់ព្យែរ ៖ ផ្លែផ្កាដែលបានពី វប្បធម៌នេះ គឺការបង្កើតស្ថាប័ន សំខាន់ៗនៅក្នុងសភា ។ ម្ខាងៗត្រូវហ៊ានប្រឈមនឹង ហានិភ័យរៀងៗខ្លួន ដើម្បីដោះស្រាយបញ្ហាប្រទេស ។

អត្ថបទដើមជាភាសាបារាំង ៖

**Le Cambodge, enfin, évolue**

Chers amis,

Un chef de gouvernement et le chef de l'opposition se rencontrent à l'étranger pour recevoir ensemble la communauté de leurs concitoyens. Or l'un a tout fait pour éliminer l'autre pendant 20 ans.

Où voit-on cela ? au Cambodge - ou plus exactement, ce samedi même, à Kuala Lumpur où les Khmers de Malaisie rencontraient Hun Sen, Premier ministre, en compagnie de Sam Rainsy qui incarne l'opposition de leur patrie.

C'est un pas nouveau dans un processus qui a commencé après le séisme des élections législatives de juillet 2013. Ayant confisqué la victoire de l'opposition et conservé la majorité à l'Assemblé nationale selon les méthodes inchangées de son pouvoir sans partage, Hun Sen, cependant, avait reconnu Rainsy pour interlocuteur et accepté d'entamer avec lui une négociation. En gage de ce dialogue, Sam Rainsy, de son côté, avait accepté, sans le remettre en cause, le résultat officiellement proclamé des élections.

Leur compromis a porté son premier fruit en août 2014, avec la normalisation constitutionnelle qu'avait



permis le retour au parlement de l'opposition. L'institution d'une Commission électorale indépendante en est le deuxième fruit, obtenu au début de 2015 à l'issue de mois d'âpres discussions.

Hun Sen détient toujours seul le pouvoir ; son cercle rapproché et ses partisans conservent les sources d'enrichissement multiples qui l'accompagnent dans ce qui demeure un Etat de non-droit. En montrant de l'estime pour le leader de l'opposition et en coopérant avec lui, Hun Sen prend le risque de perdre leur confiance, car il leur signale, entre autres, que l'ère du pillage sans retenue de la richesse nationale dont ils ont pu jouir touche à sa fin.

En affichant sa déférence pour le dictateur Hun Sen, notre ami Rainsy, de son côté, prend un très grand risque. Son seul capital est la popularité qu'il avait construite sur l'intransigeance absolue qui fut la sienne au long d'années faites de combats et d'exils. Il risque de voir fondre ce capital et, plus grave encore, d'être mal compris par ces hommes et femmes même qui, pendant vingt ans, l'ont soutenu au mépris de leurs intérêts et, trop souvent, de leurs vies.

Mais il fallait que l'un et l'autre prît ces risques pour que, sans violence, un pouvoir tolérable et digne puisse enfin, un jour, se former pour se charger de l'avenir du Cambodge.

En ce 25 avril 2015, saluons avec joie cette perspective - qui reste lointaine, mais qu'ouvre la courageuse convergence des deux hommes.

à vous,

侯尚寧
Jean-Pierre Roth

វីដេអូ ៖ https://www.youtube.com/watch?v=q0zI0XnWQcQ



## ០៩ – លោកស្រី អ៊ុច គារាទចិត្រ



យើងតែងតែមានវប្បធម៌នេះគ្រប់គ្នា តាំងពីក្នុងពោះម្ដាយមកម្ល៉េះ ដែលម្ដាយ ឬជីដូនច្រៀងបំពេរជាដើម ។ ភាពស្លូតបូត ភាពទន់ភ្លន់ គឺជាសក្ខីភាព នៃភាពរុងរឿងរបស់ពូជពង្សខ្មែរយើង។ ការបណ្ដេញចេញពីភូមិមួយទៅភូមិមួយ គឺជាសកម្មភាពប្រល័យពូជសាសន៍ ។ កូនខ្មែរទាំងក្រៅស្រុក ទាំងក្នុងស្រុកត្រូវមូលមតិគ្នា ឲ្យ មានការទុកចិត្តគ្នាទៅវិញទៅមក រួមជាកំលាំងមួយ ជំរុញវប្បធម៌សន្ទនា ជាមួយលោកប្រធាន សម រង្ស៊ី លោកអនុប្រធាន កឹម សុខា ពន្យល់ឲ្យបានជាក់ស្ដែងពីវប្បធម៌ខ្មែរ មរតកខ្មែរ ហើយលើកយកយុត្តិធម៌ជាច្បាប់វិន័យ មកវិនិច្ឆ័យទៅតាមទោស ។ ប្រសិនជាអ្នកទទួលយក វប្បធម៌សន្ទនា គ្មានសេចក្ដីស្មោះត្រង់ទេ នោះមិនមែនជាវប្បធម៌សន្ទនាទេ ហើយនឹងក្លាយទៅជាវប្បធម៌សំលាប់ជាតិខ្មែរដូចគ្នា រលាយទាំងជីវិត រលាយទាំងទឹកដីមាតុភូមិទៀតផង ។

វីដេអូ ៖ https://www.youtube.com/watch?v=VxpnKm81dYM



## ១០ – ព្រះតេជគុណ ខិន ផេន



ព្រះពុទ្ធអង្គ មិនដែលហាមឃាត់ មិនឲ្យយើងនិយាយគ្នាទេ ។ ការនិយាយគ្នាជាការល្អ នេះបើតាមបែបព្រះពុទ្ធសាសនា ។ ប៉ុន្តែគ្រាន់តែត្រូវមានការប្រុងប្រយ័ត្ន ។ រឿងនិទាន " ព្រះរាជាផ្ដាំកូនថា កុំឲ្យឃើញវែង កុំឲ្យឃើញខ្លី " ។ កុំឲ្យឃើញខ្លី គឺមានន័យថា កុំឲ្យប្រញាប់ប្រញាល់បែកមិត្ត រីឯកុំឲ្យឃើញវែង គឺកុំឲ្យមានការចងពារនឹងគ្នា ។ ទុក្ខយើងធ្ងន់ណាស់ ។ សូមយើងឲ្យមូលគ្នា សូម្បីតែខាង បក្សរបស់លោក ហ៊ុន សែន ក៏គួររួបរួមគ្នាកសាងជាតិ ។ រួមបញ្ញាគ្នាឲ្យបានច្រើន និងសាមគ្គីគ្នា ដើម្បីដោះស្រាយបញ្ហាប្រទេសយើង ។

វីដេអូ ៖ https://www.youtube.com/watch?v=7smmvsuYTmQ

## ១១ – លោក សុខ យឿន



រំលឹកពីជីវប្រវត្តិ ៖ ខ្ញុំធ្លាប់ត្រូវបានយួនចាប់ដាក់គុក ច្រើនដង ។ លោកប្រធាន គឺជាជំរើសតែមួយគត់ ។ គណបក្សជាតិខ្មែរ គឺជាគណបក្សសំរាប់តម្រង់ផ្លូវ រដ្ឋាភិបាលឲ្យដើរត្រង់ផ្លូវ ។ កូនទាហ៊ានភ្ញាក់ឡើងស៊ីបាយកក កូនអ្នកធាក់រ៉ឺម៉កភ្ញាក់ឡើងស៊ីនំប៉័ង ។ ពាក្យ " វប្បធម៌សន្ទនា " នេះ មិនងាយនរណា អាចរកឃើញយកមកប្រើប្រាស់បាននោះទេ ។



ការជួបពិភាក្សាគ្នា គឺជារឿងសាមញ្ញបំផុត សំរាប់អ្នកដឹកនាំនៅលើពិភពលោក ។ វប្បធម៌នេះ ជួយឲ្យប្រជាពលរដ្ឋខ្មែរមិនព្រួយបារម្មណ៍នឹងអំពើផ្សេងៗ ។ ពាក្យចាស់លោកថា "ថោកអ្វីនឹងដៃ ថ្លៃអ្វីនឹងមាត់" ។ បើមិនមានការស្មោះត្រង់នឹងគ្នាទេ នោះវប្បធម៌សន្ទនានេះនឹងមិនគង់វង្សឡើយ ។ សូមគាំទ្រទាំងស្រុង នូវវប្បធម៌សន្ទនានេះ ។

វីដេអូ ៖ https://www.youtube.com/watch?v=qpvXIQCiCpE

## ១២ – លោក ឈី ពឿន



វប្បធម៌នេះ បានធ្វើឲ្យមានការផ្លាស់ប្ដូរ ១៨០អង្សា ។ សូមឲ្យមាន ការយោគយល់គ្នា។ សូមឲ្យមានចរន្តតែមួយ តាំងពីលោកប្រធាន ដល់ពួកយើងនៅប្រទេសបារាំងនេះ។

វីដេអូ ៖ https://www.youtube.com/watch?v=m35qZwSWtGc

## ១៣ – លោក ខាន់ ខណ្ឌារិន



ជាវិធានការមួយ ដ៏សមស្របពិសេសពិសាល ក្នុងការដោះស្រាយបញ្ហាប្រទេសយើង ។ ដូច្នេះ គួរតែយើងនាំគ្នាគោរពទាំងអស់គ្នា។ យើងគួរឃើញនូវអ្វី ដែលយើងធ្លាប់បានឆ្លងកាត់ ។ ប្រទេសជិតខាងបន្តចិញ្ចឹមចិត្តលេបទឹកដីយើង ។ គេបានសាកល្បងជាច្រើនដងដើម្បីឲ្យដឹងថាតើកូនខ្មែរយើងដឹងខ្លួនដែរឬទេ ?

វីដេអូ ៖ https://www.youtube.com/watch?v=m35qZwSWtGc



តទៅលេខក្រោយ

តមកពីទំព័រទី ១៦

## លោក ហ៊ុន សែន ក្លាយជាប្រធាន...

២០១៨ជាការរៀបចំធម្មតាសម្រាប់សន្និបាតគណបក្សប្រជាជន ប៉ុន្តែមិនបានធ្វើនៅឯសន្និបាតបក្សលើកចុងក្រោយរបស់ខ្លួនកាលពីខែមករាឡើយ។

សេចក្តីថ្លែងការណ៍របស់គណបក្សប្រជាជនបាននិយាយថា "ឱ្យបន្ទាប់ពីសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៣៨ អាណត្តិឱ្យរដ្ឋាភិបាលទី៥របស់គណបក្សប្រជាជនកម្ពុជានាថ្ងៃទី២០ខែមិថុនា ដើម្បីជ្រើសតាំង លោក ហ៊ុន សែន ជាប្រធាន និងលោក ស ខេង និងលោក សាយ ឈុំ ជាអនុប្រធានមក ក៏មានលេចឮពាក្យចចាមអារ៉ាមបំពុលក្នុងសាធារណមតិថា លោក ហ៊ុន សែន នឹងឈប់ធ្វើជានាយករដ្ឋមន្ត្រីទៀតហើយ"។

"ចំពោះបញ្ហានេះ គណបក្សប្រជាជនកម្ពុជាសូមប្រកាសថា លោក ហ៊ុន សែន នៅតែបន្តធ្វើជានាយករដ្ឋមន្ត្រីដដែល និងជាបេក្ខភាពនាយករដ្ឋមន្ត្រីសម្រាប់អាណត្តិក្រោយៗទៀត ទៅតាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្សប្រជាជនកម្ពុជា។

ទាក់ទងកាលពីថ្ងៃអាទិត្យ លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា ការជ្រើសរើសលោក ខេង និងលោក ឈុំ ជាអនុប្រធាន សម្រេចដោយគណៈកម្មការអចិន្ត្រៃយ៍ និងអនុម័តយល់ព្រមដោយគណៈកម្មាធិការកណ្តាល ហើយថា គ្មាននរណាម្នាក់ត្រូវចាត់ទុកថាជា "អនុប្រធានទី១ទេ"។

លោក ឥសាន បាននិយាយថា "អនុប្រធានទាំងពីរជាវីរជនមកពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្ស ហើយមិនចាំបាច់ដាក់លេខរៀងទេ ពីព្រោះនៅពេលយើងដាក់លេខរៀង ម្នាក់នឹងខ្ពស់ជាងហើយម្នាក់នឹងទាបជាង។ សមិទ្ធផលរបស់ពួកគាត់ស្មើគ្នា ហើយពួកគាត់នឹងមានការទទួលខុសត្រូវរៀងៗខ្លួន"។

អ្នកនាំពាក្យរូបនេះបានបន្ថែមថា សេចក្តីសម្រេចដាក់លោក ហ៊ុន សែន លោក ខេង និងលោក ឈុំ លើសន្លឹកឆ្នោតតែមួយសម្រាប់ការយល់ព្រមដោយសន្និបាតគណបក្សប្រជាជនកម្ពុជា មិនមែនមានប្រជាធិបតេយ្យតិចជាងការអនុញ្ញាតឱ្យគណៈកម្មាធិការកណ្តាលបោះឆ្នោតរើសបេក្ខជនផ្សេងៗគ្នានោះទេ។

លោកមានប្រសាសន៍ថា "យើងអនុវត្តនីតិវិធីដែលមានស្រាប់របស់យើងដែលចែងក្នុងលក្ខន្តិក និងវិធានផ្ទៃក្នុងរបស់បក្ស ហើយលក្ខន្តិក និងវិធានផ្ទៃក្នុងរបស់បក្សយើង គឺមានប្រជាធិបតេយ្យពេញលេញ បើធៀបទៅនឹងគណបក្សផ្សេងទៀត"។

លោក ឥសាន បានមានប្រសាសន៍ដែរថា បដា និងផ្ទាំងបដាគណបក្សប្រជាជនកម្ពុជាដែលធ្លាប់ឃើញបង្ហាញរូបលោក ជា ស៊ីម ជាប្រធានបក្ស លោក ហ៊ុន សែន ជាអនុប្រធាន និងលោក ហេង សំរិន ប្រធានសភាជា "ប្រធានកិត្តិយស" នឹងត្រូវដកចេញបណ្តើរ ហើយដាក់ជំនួសវិញ ដោយបដាថ្មី ដែលបង្ហាញតែមុខលោក ហ៊ុន សែន និងលោក សំរិន ប៉ុណ្ណោះ។

លោកបានមានប្រសាសន៍ថា "ប្រសិនបើយើងដាក់អនុប្រធានពីរ វាមើលទៅឃើញមិនល្អទេ។ យើងដាក់តែមេដឹកនាំកំពូលប៉ុណ្ណោះ"៕

**និត**


Khmer Owned & Operated

Independence Home Care

Health Services LLC

ថែរក្សាសុខភាពដល់លំនៅដ្ឋានរបស់អ្នកទូរទាំងរដ្ឋ

Licensed Home Care Provider / Companion Services

Certified Medicare/Medicaid • Joint Commission Accreditation • Home Nursing Care Provider Licensed by RI Department of Health

**Approved Provider of All State Programs:** Department of Elderly Affairs / Department of Human Services

**Skilled Nursing**
- Registered Nurses
- Home Health Aide
- Physical Therapy
- Occupational Therapy
- Speech Therapy
- Medical Social Worker

**Unskilled Nursing**
- Companionship
- Personal Care
- Bathing
- Dressing
- Safety
- Meal Preparation and Housekeeping
- Medication Reminders
- Errands and Assistance with Transportation

**Employment**
**Nurses & CNAs**
- Helping Over 100 Rhode Island Elderly Southeast Asians
- We Employ Over 50 Southeast Asians
- FREE ASSESMENT



*Let our family, take care of yours.*



**CALL US TODAY!**
**(401) 437-8337**
**www.independencehs.com**
Available 24/7

**1179 Elmwood Ave.**
**Providence, RI 02907**

- See our Khmer Video about Home Care at our website -

តមកទំព័រទី ១៥

## គណបក្សសង្គ្រោះជាតិគ្រោង...

លោក អ៊ុំ សំអាន ដែលបានដឹកនាំក្រុមនិស្សិតតវ៉ាប្រឆាំងសន្ធិសញ្ញាព្រំដែនជាមួយវៀតណាម កាលពីឆ្នាំ២០០៥ បានមានប្រសាសន៍ថា "យើងបានស្នើសុំឱ្យរដ្ឋាភិបាលប្រគល់ផែនទីឱ្យយើង ប៉ុន្តែរដ្ឋាភិបាលបានបដិសេធនឹងយើងម្តងហើយម្តងទៀត ហើយគ្មានចម្លើយច្បាស់លាស់ទេ ពាក់ព័ន្ធបញ្ហាព្រំដែនដែលយើងមិនអាចទទួលយកបានឡើយ។ មូលហេតុដែលយើងគ្រោងកោះហៅ ពួកគាត់ គឺដោយសារតែ ទី១ ពួកគាត់បដិសេធមិនប្រគល់ផែនទីទាំងនោះឱ្យយើង និងទី២ ដោយសារតែលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្តល់ចម្លើយកាលពីម្សិលមិញដែលមិនបានដោះស្រាយក្តីបារម្ភរបស់ខ្ញុំ"។

លោកបានបន្តថា លោកនឹងស្នើសុំឱ្យថ្នាក់ដឹកនាំរដ្ឋាភិបាលលាតត្រដាងឈ្មោះភូមិចំនួនពីរដែលត្រូវបានដោះដូរឱ្យទៅវៀតណាមជាថ្នូរនឹងការឱ្យកម្ពុជារក្សាទុកភូមិរបស់លោក ហេង សំរិន ប្រធានរដ្ឋសភានៅក្នុងខេត្តកំពង់ចាម។

លោកបានលើកឡើងទៀតថា "ឱ្យលោក ហ៊ុន សែន មិនបានប្រាប់ខ្ញុំពីឈ្មោះភូមិ និងទីតាំងរបស់វាទេ ហើយគ្រាន់តែលើកឡើងថា លោកបានពន្យល់បកស្រាយអំពីវានៅក្នុងរដ្ឋសភារួច ហើយកាលពីឆ្នាំ ២០១២ ប៉ុន្តែនៅពេលនោះគាត់មិនបានបញ្ចេញឈ្មោះភូមិដែលត្រូវបានដោះដូរទាំងនោះទេ"។

លោកបានមានប្រសាសន៍ថា បើយោងតាមច្បាប់ចម្លងនៃផែនទីឆ្នាំ១៩៥២ របស់លោកដែលរដ្ឋាភិបាលនិយាយថា ខ្លួនបានប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់ការដោះដូរដី និងការកំណត់ព្រំដែនជាមួយវៀតណាមនោះ គឺវាមិនអាចទៅរួចទេដែលថាភូមិរបស់លោក ហេង សំរិន ស្ថិត នៅក្នុងទឹកដីវៀតណាម ហើយត្រូវការការដោះដូរបែបនេះនោះ។

កាលពីម្សិលមិញលោក វ៉ា គឹមហុង បានបដិសេធមិនធ្វើអត្ថាធិប្បាយទេ ជុំវិញបញ្ហាព្រំដែន ប៉ុន្តែបានបង្ហាញថា លោកនឹងគោរពតាមការកោះហៅឱ្យចូលរដ្ឋសភា។ លោកបានមានប្រសាសន៍ថា "ពេលនេះខ្ញុំជាប់រវល់ប្រជុំ ប៉ុន្តែខ្ញុំនឹងរង់ចាំមើលលិខិតកោះហៅរបស់ពួកគាត់"។

លោក សុខ ឦសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានឆ្លើយស្រដៀងគ្នាពាក់ព័ន្ធនឹងលទ្ធភាពដែលលោក ហ៊ុន សែន និងលោក ហោ ណាំហុង ដែលសុទ្ធតែជាសមាជិកសភាអាចនឹងចូលសភាដើម្បីឆ្លើយសំណួរជុំវិញបញ្ហាព្រំដែន។

លោកបានមានប្រសាសន៍ថា "វាមិនអីទេ បើពួកគាត់ធ្វើទៅតាមបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងរដ្ឋធម្មនុញ្ញ។ បើពួកគាត់មិនអនុវត្តតាមច្បាប់វានឹងមិនអាចទៅរួចឡើយ"។

ប៉ុន្តែទន្ទឹមនឹងនេះ លោក សុខ ឦសាន ក៏សុំឱ្យលោក អ៊ុំ សំអាន និងលោក ម៉ៅ មុនីវណ្ណ ផ្តល់ ផែនទីរបស់ពួកគាត់ឱ្យរដ្ឋាភិបាលមើលជាមុនសិនដែរ។ លោកបានមានប្រសាសន៍យ៉ាងដូច្នេះថា "រដ្ឋាភិបាលធ្វើការងារឱ្យព្រំដែនបានត្រឹមត្រូវ ហើយ។ ហើយសម្រាប់បញ្ហាដែលពួកគាត់ចោទប្រកាន់រដ្ឋាភិបាលថា ប្រើប្រាស់ផែនទីក្លាយក្លាយ ឬមិនត្រឹមត្រូវនោះ យើងចង់ឱ្យពួកគាត់បង្ហាញយើងនូវផែនទីពិតប្រាកដ ដើម្បីឱ្យយើងពិនិត្យផ្ទៀងផ្ទាត់"។

នៅក្នុងលិខិតរបស់លោក ហ៊ុន សែន ផ្ញើជូនទៅលោក អ៊ុំ សំអាន កាលពីថ្ងៃសុក្រ លោក ហ៊ុន សែន បានបដិសេធថា រដ្ឋាភិបាលមិនដែលដោះដូរដីដែលប្រជាពលរដ្ឋកម្ពុជាកំពុងរស់នៅឱ្យទៅវៀតណាមនោះទេ។ លោកនាយករដ្ឋមន្ត្រីបានសរសេរថា "រដ្ឋាភិបាលគ្មានគោលការណ៍យកភូមិដីស្រែចម្ការ និងភូមិឋានដែលកាន់កាប់ និងបង្កបង្កើនផលដោយប្រជាពលរដ្ឋកម្ពុជាឱ្យទៅវៀតណាមឡើយ"៕ **សុខុម**

Continued from page 15

## CNRP Plans to Summon...

According to the 2005 treaty with Vietnam, Mr. Kimhong, Cambodia's head of the joint border committee, has the prerogative to negotiate changes to the 1952 border where a strict adherence to the line would require the forced relocation of existing Cambodian or Vietnamese communities. Yet the opposition has accused the border committee of frequently cutting Cambodian communities into Vietnam in its talks, or otherwise being too amenable to ceding territory.

Mr. Kimhong declined to comment on the border issues Tuesday but indicated he may honor a summons to the National Assembly. "I'm busy at a meeting right now but I will wait to see their letter of summons," he said.

CPP spokesman Sok Eysan provided a similar answer regarding the likelihood of Mr. Hun Sen and Mr. Namhong, who are themselves members of the National Assembly, answering questions in parliament about the border.

"It's fine if they do it in accordance with the National Assembly's internal rules and the Constitution," Mr. Eysan said. "If they don't comply with the law, it will be impossible."

Yet Mr. Eysan also challenged Mr. Sam An and Mr. Monyvann to provide their maps to the government first.

"The government has done the [border] work correctly. And for the matters of them accusing the government of using a fake or incorrect map, we want them to show us the real one, so then we can verify it," Mr. Eysan said.

In his letter to Mr. Sam An on Friday, Mr. Hun Sen denied the government had ever knowingly swapped land to Vietnam that was being lived on by Cambodians.

"The government has no principle to take the villages, farmland and residential villages being occupied and cultivated by Cambodian citizens to give to Vietnam," the prime minister wrote.


ហ្វេយ៍មឹកខេប ផ្ទះសម្រាប់ពិធីបុណ្យសព

Fay McCabe Funeral Home

105 Moore Street. Lowell, MA 01852

978-459-9222



បម្រើសហគមន៍ខ្មែរដោយការយកចិត្តទុកដាក់ កិត្តិយស និងការគោរពជាង៣០ឆ្នាំមកហើយ

- Serving All Faiths — បម្រើសេវាកម្មគ្រប់ជំនឿ
- Traditional Funerals — កម្មវិធីបុណ្យសពជាលក្ខណៈប្រពៃណី
- Cremation Services — មានផ្តល់សេវាបូជាសព
- Pre Arranged Funerals — រៀបគំរោងមុនកម្មវិធីបុណ្យសព

Locates 1 mile from Glory Buddhist Temple, between Gorham St. & Lawrence St.

ទីកន្លែងនៅចំងាយ១ម៉ាយពីវត្តពន្លឺពុទ្ធចក្ក ចន្លោះផ្លូវ Gorham St. & Lawrence St.

*លោកអ្នកនឹងក្រុមគ្រួសារទទួលបាននូវការយកចិត្តទុកដាក់ និងការបម្រើល្អប្រពៃពីទីនេះ ។*

www.faymccabe.com

**មានបុគ្គលិកនិយាយភាសាខ្មែរ**

## **តមកទំព័រទី ១២** គណបក្សសង្គ្រោះជាតិនៅអាមេរិក...

បន្ទោសស្តីអំពីការចាប់យក"វប្បធម៌សន្ទនា"ជា មួយគណបក្សប្រជាជនមក។ តើមានអ្វីកើតឡើងខ្លះ?

**ពិន សំខុន:** តើលោកយល់ព្រមតាមសេចក្តីសម្រេចចិត្តរបស់លោក សម រង្ស៊ី ដែរឬទេ?

**វណ្ណៈ ម៉ែនៈ** អរគុណខ្មែរផុសដែលបានអនុញ្ញាត្តិឱ្យខ្ញុំបានបញ្ចេញយោបល់ក្នុងរឿងនេះ ! តាមពិតទៅមិនមានអ្វីគួរភ្ញាក់ផ្អើលទេ បើតាមអនុសាសន៍របស់ឯកឧត្តមប្រធាន សម រង្ស៊ី ធ្វើកាលពីនៅពេលប្រជុំរដ្ឋកាលីហ្វ័រនីញ៉ា ថានៅរដ្ឋនិមួយៗ គេអាចបង្កើតក្រុមទ្រទ្រង់២-៣ក៏បានដែរ ដូច្នេះគឺជាក្រុមទ្រទ្រង់ មិនមែនជាសាខាបក្សទៀតទេ ។ ហេតុនេះហើយបានជាមានលិខិតអបអរសាទរពីគំនិតចុងក្រោយនេះ ពីខាង "NA" ក៏មានពីខាង USA

**ខ្មែរផុសៈ**កាលពីពេលបោះឆ្នោតក្រុម "NA" តំណាងដោយលោកគ្រូពេទ្យ ឆាន ទូច រីឯក្រុម "USA"តំណាងដោយលោក វណ្ណៈ ម៉ែន គឺមានបំណងបោះឆ្នោតនៅស.រ.អា នេះដើម្បីបង្រួបបង្រួមគ្នាឱ្យនៅតែមួយខ្ញុំថានេះត្រូវ ឬទេ?

**វណ្ណៈ ម៉ែនៈ** បាទមែន! បេក្ខជន នឹងគណកម្មការសុទ្ធតែទៅពីក្រុម២ខុសគ្នាទាំងអស់ ក៏ប៉ុន្តែសមាជិកអ្នកមកបោះឆ្នោតទាំងអស់មិនបានដឹងទេថា មានក្រុមដល់ទៅ២នោះទេ គេមកបោះឆ្នោតឱ្យសង្គ្រោះជាតិតែមួយប៉ុណ្ណោះ...

**ខ្មែរផុសៈ** ខ្ញុំមិនទាន់យល់ច្បាស់នៅឡើយទេ តើឥឡូវនេះមានអង្គភាព២ឬក៏អត់ ?







**វណ្ណៈ ម៉ែនៈ** បាទមានបែកជា២មែន! តាំងតែពីក្រុមលោក ឆាន ទូច ទទួលយកការតែងតាំងដោយឯកឧត្តមប្រធានទៅនោះ ខាងម្ខាងទៀតគេឥតបានទទួលយកការតែងតាំងនោះទេម្ល៉ោះហើយលោក ខឹម ស៊ីនួន ត្រឡប់មកយកដំណែងប្រធានស.រ.អា.វិញដដែលបន្តទៅទៀតទៅតាមរូបមន្តដូចពីមុនទាំងអស់ ។

**ខ្មែរផុសៈ** បន្ទាប់ពីលោក ឆាន ទូចឡើងជាប្រធាន"អាមេរិកខាងជើង"មកក្រុមនោះបានតែងតាំងលោក នាង សុវណ្ណដារា ជាអនុប្រធាននៅNA និងជាប្រធាននៅMA លោក ខៃ រដ្ឋា ជាប្រធានយុវជនNA... ចុះលោក វណ្ណ ម៉ែន ខ្លួនឯង នៅខាងណា តួរនាទីជាអ្វី ?

**វណ្ណៈ ម៉ែនៈ** នៅពេលទស្សនកិច្ចលោកប្រធាននៅឡូវែលលោកបានប្រាប់ឱ្យខ្ញុំដកខ្លួនរង់ចាំតួរនាទីមួយ ដែលខ្ញុំត្រូវបំពេញនៅឯកម្ពុជា... ក្នុងការរង់ចាំនេះ ខ្ញុំមិនចូលទៅខាងណាទាំងអស់ បើខាងណាត្រូវការខ្ញុំ គឺខ្ញុំទៅជួយគេខាងនោះដោយរីករាយ ។

**ខ្មែរផុសៈ** មានឧទាហរណ៍នៃករណីមួយបានកើតឡើង ក្រុមអង្គរក្សលោក សម រង្ស៊ី ៦រូបបានរងរបួសដោយគ្រោះថ្នាក់រថយន្ត... លោក ខឹម ស៊ីនួន បានយកថវិកា១ពាន់ដុល្លារ ទៅជួយក្រុមអង្គរក្សទាំងនោះ តែខាងក្រុមលោក ឆាន ទូច មិនសប្បាយចិត្តដោយយល់ថា លុយដែលនៅក្នុងហិបលោក ស៊ីនួន ត្រូវតែប្រគល់មកឱ្យគណកម្មការថ្មីដែលលោក សម រង្ស៊ី ទើបតែងតាំង តើលោកមើលឃើញទំនាស់នោះ ត្រូវដោះស្រាយរបៀបណា?

**វណ្ណៈ ម៉ែនៈ** បាទ ក្នុងរូបមន្តនៃក្រុមទ្រទ្រង់គណបក្សសង្គ្រោះជាតិមួយក្រុមខាងលោក ខឹម ស៊ីនួន មានស្វយ័តភាពនឹងប្រើប្រាស់ថវិការដែលខ្លួនរកបាននោះ ដោយមិនចាំបាច់យកហិបប្រាក់នោះទៅប្រគល់ឱ្យលោក ឆាន ទូច នោះទេ...

**ខ្មែរផុសៈ** ដើម្បីទប់ស្កាត់ ត្រីងៀតឆ្វៀតពងក្រុមណាក៏បង្កើតបានដើររៃអង្គាសលុយប្រជាជនបានហើយតែមិនប្រគល់ប្រាក់នោះទៅគណបក្សតើអាចធ្វើឱ្យទៅជាក្រុមទ្រទ្រង់តែមួយនោះ បានឬទេ?

**វណ្ណៈ ម៉ែនៈ** បើមានឆន្ទៈជាការស្រួលបំផុតគឺលោក សម រង្ស៊ី ទៅណែនាំខាង "អាមេរិកខាងជើង"ដែលច្រើនតែមកពីគណបក្ស សម រង្ស៊ី ឱ្យមកចូលរួមតែមួយ... រីឯលោក កឹម សុខា ទៅណែនាំខាង"សហរដ្ឋអាមេរិក"ដែលច្រើនតែមកពីខាងគណបក្សសិទ្ធមនុស្សឱ្យមករួមបញ្ចូលគ្នា វាជាការស្រេច... តែខ្ញុំស្តាយណាស់ បើទុកដូចសព្វថ្ងៃនេះ ខាង "អាមេរិកខាងជើង" ធ្វើការតែជាមួយគណបក្សខ្លួន ចំណែកខាង "សហរដ្ឋអាមេរិក" ក៏ធ្វើការជាមួយតែពួកសិទ្ធមនុស្ស ចំណែកឯអ្នកដែលគេចង់តែជួយតែគណបក្សសង្គ្រោះជាតិមិនប្រកាន់គណបក្សខាងណាមួយនោះ គេមិនអាចចូលរួមបានទេ !!

**ខ្មែរផុសៈ** សូមអរគុណ លោក វណ្ណៈ ម៉ែន !

## **តមកទំព័រទី ០២** គោលដៅលំហែកាយថ្មី....

ភ្លេងចម្រៀងតាមផ្លូវនាមាត់សមុទ្រឮលាន់រងំ ខ្យល់នាមាត់សមុទ្របោកផ្កើមបក់ទៅរកឯនាយសមុទ្រវិញទៅហើយ ពួកយើងអស់កម្លាំងផ្តើមទន់ត្របកភ្នែកតែសាធារណជន នៅតែខ្លាំងក្លានៅបន្តរភាពអ៊ូអរបាននៅឡើយ។

ស្អែកនេះ ជាថ្ងៃទី២ខែមិថុនា២០១៥ យើងត្រូវឡើងយន្តហោះត្រឡប់ទៅបុស្តុនវិញ តែម៉ោងចេញដំណើររបស់យើងនៅម៉ោង១០យប់ឯណោះ ដូច្នេះយើងនៅសល់ពេល១ថ្ងៃពេញសម្រាប់ទៅទស្សនាកន្លែងដែលសែសសល់នៃផ្នែកខាងកើតរបស់រដ្ឋសៅការ៉ូឡាយណា ។ នៅតាម"ហាយវេ"សំដៅទៅខាងជើងនៃដងផ្លូវមាត់សមុទ្រអាត់ឡង់ទិក យើងនៅប្រមាណតែ១ម៉ោងប៉ុណ្ណោះក៏ទៅដល់ព្រំប្រទល់នៃរដ្ឋន័តការ៉ូឡាយណា ខាងត្បូងទៅហើយ ហើយមិនមានឃើញអ្វីប្លែកគ្នាពីសៅការ៉ូឡាយណាសោះឡើយ។ យើងបានទស្សនា មើធីលប៊ីច មួយជុំចូលទៅហូបអាហារនៅហាងថៃតែមួយជាចុងក្រោយ ពីព្រោះគ្មានហាងខ្មែរទេ ហើយសំដៅទៅទៅវាលយន្តហោះនៅម៉ោង៥ល្ងាចតែម្តង។ យើងប្រគល់រថយន្តដែលជួលរួចហើយ ចូលឆែកឥវ៉ាន់រួចចូលទៅចាំជើងយន្តហោះរបស់យើងតែជាអកុសលយន្តហោះត្រូវពន្យាពេល៤ម៉ោង គឺម៉ោង២ភ្លឺ ទើបចេញដំណើរ ដែលក្តីបារម្ភណ៍គឺ ប៊ុណ្ណារ៉ូ មិនព្រមសម្រាកទាល់តែសោះ។

មិនចាំបាច់រ៉ាយរ៉ាប់ពីការលំបាកក្នុងការចាំជើងយន្តហោះ នៅពេលយប់នៃចំណតយន្តហោះតូចនោះទេ យើងដឹងថា យើងទាំងអស់គ្នាពុំបានបិទភ្នែកមួយស្រឡេតទេ រហូតដល់ម៉ោង៧ព្រឹក ទើបយើងបានមកដល់ផ្ទះ រីករាយណាស់ដោយបានជួបគ្រែជាទីស្រឡាញ់របស់យើងវិញ៕









ការវិភាគរបស់ព្រះតេជគុណបណ្ឌិត ហុក សាវណ្ណ

# អំពីអត្ថន័យនៃការស្បថ(សម្បថ) Oath


ព្រះតេជគុណបណ្ឌិត ហុក សាវណ្ណ

សម្បថនេះជាទំនៀមទម្លាប់របស់ប្រជាជនជំនាន់ដើមសម័យបច្ចុប្បន្ននេះក៏នៅគេយកមកអនុវត្តដែរ ដែលមានន័យពីរយ៉ាងន័យម្យ៉ាងសំដែងភាពល្អរបស់ខ្លួនឱ្យអ្នកដទៃជឿទុកចិត្តដោយយកវត្ថុសក្តិសិទ្ធិដឹងឮជាសាក្សីន័យមួយទៀតចំពោះអ្នកនយោបាយទុច្ចរិតការស្បថគឺជាការភូតកុហកដើម្បីបិទបាំងនូវកំហុសរបស់ខ្លួនធ្វើឱ្យប្រជាជនជឿខុស។ ចំពោះព្រះពុទ្ធសាសនាកម្មផលជាអ្នកកាត់ទោសមនុស្សសត្វដែលសាងល្អសាងអាក្រក់ជាស្វ័យប្រវត្តិពុំរង់ចាំស្បថឡើយទោះបីលាក់បិទបាំងក៏ដោយ។

ការបោះឆ្នោតអាណត្តិទី៥ឆ្នាំ២០១៣ បើចង់ដឹងថា លួចសន្លឹកឆ្នោតឬមិនលួចបើគេសង្ស័យសុំឱ្យបើកហិបឆ្នោតរាប់ឡើងវិញនៅកន្លែងខ្លះត្រូវបើករាប់ឱ្យគេឃើញទាំងអស់គ្នាទៅបើមិនព្រមត្រូវចោទថា ពិតជាលួចសន្លឹកឆ្នោតហើយ។ ភ័ស្តុតាងមួយទៀតដែលចោទថា លួចអាសនៈពិតណាស់ គឺលោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានប្រកាសលទ្ធផលមុនគណៈកម្មាធិការជាតិរៀបចំបោះឆ្នោតប្រកាសទៅទៀតហើយ បើគណបក្សប្រជាជនឈ្នះឆ្នោតហេតុអ្វីបានជាចលនាទ័ពពេញទីក្រុងភ្នំពេញ។

កាកបាទក្រហមតាមអនុសញ្ញាអន្តរជាតិជាអង្គការឯករាជ្យនិងអព្យាក្រិត្យត្រូវជួយសង្គ្រោះគ្រប់ប្រភេទមនុស្សមានទុក្ខទាំងអស់ទោះសត្រូវរបស់ខ្លួនក៏ដោយ។

ចំពោះកាកបាទក្រហមខ្មែរតើជាអង្គការអព្យាក្រិត្យឬទេ? សូមលើកឧទាហរណ៍ខ្លះឆ្នាំ២០១៤នៅផ្លូវវេងស្រេងកងទ័ពឆ័ត្រយោង និងកងសន្តិសុខបានវាយប្រហារបាញ់សម្លាប់កម្មករធ្វើបាតុកម្មអហិង្សាសុំតម្លើងប្រាក់ខែស្លាប់៥នាក់និងរបួសជាច្រើននាក់គេពុំឃើញកាកបាទក្រហមខ្មែរដឹកអ្នកត្រូវរបួសទៅមន្ទីរពេទ្យនិងផ្តល់អំណោយអ្វីឡើយ។

ផ្ទុយទៅវិញកងសន្តិសុខដែលត្រូវរបួសនៅជិតវិមានប្រជាធិបតេយ្យកាកបាទក្រហមខ្មែរបានជួយយ៉ាងសកម្មនេះជាសកម្មភាពលំអៀង។ បើស្បថនឹងមានទោសកុហក១ទៀត។

សូមដកស្រង់ខ្លះនូវសច្ចាប្រណិធានរបស់រាជរដ្ឋាភិបាលដែលមានចែងក្នុងរដ្ឋធម្មនុញ្ញសច្ចាប្រណិធានទូលព្រះបង្គំយើងខ្ញុំនាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលសូមធ្វើសច្ចាប្រណិធាននៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជនិងទេវតារក្សាស្វេតច្ឆត្រដូចតទៅ :

-ក្នុងពេលប្រតិបត្តិការតាមមុខតំណែងខ្លួននិងក្នុងការបំពេញបេសកកម្មដែលប្រជារាស្ត្រកម្ពុជាបានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូបទូលព្រះបង្គំយើងខ្ញុំសូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញបំរើជានិច្ចទាំងក្នុងបច្ចុប្បន្នទាំងក្នុងអនាគតនូវផលប្រយោជន៏របស់ប្រជារាស្ត្រប្រជាជាតិនិងមាតុភូមិកម្ពុជា។ ទូលព្រះបង្គំយើងខ្ញុំសូមសច្ចាថាមិនកេងប្រវញ្ច័នូវផលប្រយោជន៏ជាតិសំរាប់ផ្ទាល់ខ្លួនឬសំរាប់គ្រួសារឬសំរាប់បក្សពួកឬសំរាប់ភាគីរៀងៗខ្លួនឡើយ។

-ទូលព្រះបង្គំយើងខ្ញុំសូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ចទាំងក្នុងបច្ចុប្បន្នទាំងក្នុងអនាគតនូវឯករាជ្យទាំងស្រុងនៃមាតុភូមិកម្ពុជា,អធិបតេយ្យជាតិពេញបរិបូណ៌បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់នៅក្នុងព្រំដែនដីគោកនិងព្រំដែនសមុទ្រដែលកម្ពុជាធ្លាប់មានក្នុងជំនាន់ឆ្នាំ១៩៦៣ដល់១៩៦៩,ឯកភាពជាតិហើយមិនអនុញ្ញាតឱ្យមានការបែងចែកឬការធ្វើអបគមន៏ណាមួយឡើយ។

-ក្នុងដំណោះស្រាយបញ្ហាទាំងឡាយលើផ្ទៃរាបជាតិនិងអន្តរជាតិទូលព្រះបង្គំយើងខ្ញុំនឹងបំបាត់ចោលទាំងស្រុងនូវអំពើហិង្សាគ្រប់បែបយ៉ាង។ ប៉ុន្តែព្រះរាជាណាចក្រកម្ពុជាសូមរក្សាទុកនូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅដើម្បីការពារជាតិមាតុភូមិខ្លួន។

-ទូលព្រះបង្គំយើងខ្ញុំសូមប្តេជ្ញាគោរពជានិច្ចទាំងក្នុងបច្ចុប្បន្នទាំងក្នុងអនាគតនូវលទ្ធិប្រជាធិបតេយ្យសេរីនិយមដែលមានរបបសភានិងពហុបក្សព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្សដូចមានចែងក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស។

នេះជាពាក្យស្បថចូលកាន់តំណែងតើទាំង៥អាណត្តិគោរពបានត្រឹមត្រូវឬទេ?

វត្តខ្មែរកាណាដា,ថ្ងៃ១៤ មិថុនា ២០១៥

www.hoksavann.org; savannhok@yahoo.com

AccuCare
Home Care Agency
Group Adults Foster Care Program

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

Homecare Agency
Group Adult Foster Care Program (GAFC)
MassHealth

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



Compassionate Care & Reliable
Professional & Cultural Sensitive
Management & Staffs speak Khmer

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។

*Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.*

**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**
To be eligibled for GAFC you must:
-រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)
-អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)
-មាស់ហែលស្តង់ដា (eligible for Masshealth Standard)
-ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀក-ពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)
-មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក (have physician statement of your condition)
-ត្រូវបានវាយតំលៃផ្នែកសុខភាព និងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )

**ផលប្រយោជន៍ទទួលបាន :**
Benefits you will get:
-ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)
-ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)
-ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីឈើ (an individual care plan developed by a registered nurse and case manager)
-វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)
-សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:

អ៊ុក តុលាយុត្តិ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# ប្រជុំស្តីពីសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយនៅ សភាពេញអង្គនៅថ្ងៃទី៨ ឧសភា ២០១៥ នៅវិមានរដ្ឋសភា


លឹម គិមយ៉ា

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយជាឧបករណ៍មួយដែលសំខាន់សំរាប់ជួយដល់ការរស់នៅប្រជាពលរដ្ឋ និងព្យាករពេលគ្រោះអាសន្នក្នុងកាលៈទេសៈមួយដែលយើងនឹងអាចជួបនៅពេលណាមួយទៅអនាគត។ ជាសំណាងមួយបើតាមអ្នកវិទ្យាសាស្ត្រភូមិសាស្ត្រប្រទេសយើងគ្រោះមហន្តរាយដោយភ្នំភ្លើងដោយរំជួលផែនដីដោយសូណាមី ដូចជាមិនជាបញ្ហាអ្វីទេ ។ តែដោយមានការកាប់បំផ្លាញព្រៃឈើពីពួកឧក្រិដ្ឋជនពួកមានអំណាចបានធ្វើឱ្យធាតុអាកាសដូរទៅជាមានភ្លៀងខ្លាំងខុសចំឡែកបង្កើតឱ្យមានទឹកជំនន់សឹងតែរាល់ឆ្នាំ បាក់ដី ដោយទឹកជំនន់ និងបូមខ្សាច់ព្រមទាំងមានខ្យល់កំបុតត្បូងជាញឹកញាប់ក្នុងមួយឆ្នាំៗដែលបណ្តាលឱ្យប្រជាពលរដ្ឋយើងខាតបង់ជីវិតជាច្រើនរយនាក់ ផ្ទះសំបែងព្រមទាំងទ្រព្យសម្បត្តិជាច្រើនរយលានដុល្លា ថែមទាំងការខូចខាតផលិតផលកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ។ ថែមពីនេះទៅទៀត គឺជម្ងឺឆ្លងផ្សេងៗ។ ហេតុនេះការគ្រោងសំរាប់ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ និងការកាត់បន្ថយគ្រោះថ្នាក់នេះជាការត្រឹមត្រូវដែលខ្ញុំយល់ថាត្រូវមែន។

បើមើលពីនិយមន័យពាក្យ "គ្រោះមហន្តរាយ"នៅឧបសម្ព័ន្ធនៃច្បាប់បានពន្យល់ថា: "សំដៅដល់ការរំខានធ្ងន់ធ្ងរនៃដំណើរការរបស់សហគមន៍ ឬសង្គមដែលធ្វើឱ្យមានការបាត់បង់ និងប៉ះពាល់ធ្ងន់ធ្ងរដល់មនុស្ស សម្ភារៈ សេដ្ឋកិច្ច ឬបរិស្ថាន ហើយកម្រិតនៃការប៉ះពាល់ហួសពីលទ្ធភាពរបស់សហគមន៍ ឬសង្គមដែលទទួលរងការប៉ះពាល់ក្នុងការប្រើប្រាស់លៃលកដោះស្រាយដោយធនធានខ្លួនឯង" ដូចជាអត់ច្បាស់សោះ បើយើងនិយាយឱ្យស្រួលស្តាប់ គឺយឺតដូចកៅស៊ូ ឬរួញដូចរស៊ែរ គឺអាចទាញ ឬបង្រួញទៅតាមការបកស្រាយរបស់អ្នកទទួលខុសត្រូវ និងអាជ្ញាធរ។ ហេតុនេះក្នុងគំនិតច្បាប់ សូមរាជរដ្ឋាភិបាលកែសំរួលនិយមន័យពាក្យ "គ្រោះមហន្តរាយ" ឱ្យបានច្បាស់ ហើយដាក់ឧទាហរណ៍ឱ្យផង គង់តែរាយរាប់មិនអស់ គួរតែសរសេរថា "ជាដើម" ដូចជាទឹកជំនន់ បាក់ដី ភ្លើងឆេះព្រៃ គ្រោះថ្នាក់ចរាចរ និងអគ្គីភ័យជាដើម។ ហើយកាលពីថ្ងៃព្រហស្បត្តិ៍មុនឯ.ឧ.បណ្ឌិត រដ្ឋប្រធានគ២ បានលើកឧទាហរណ៍គ្រោះថ្នាក់បង្កដោយសត្វព្រៃ ដូចជាដំរី ខ្លា ក្រពើជាដើម ខ្ញុំសុំបន្ថែមដោយសត្វពស់ដោយប្រជាពលរដ្ឋយើងបានទទួលរងគ្រោះជាញឹកញាប់ដោយគ្មានការព្យាបាលឬយកចិត្តទុកដាក់ពីបុគ្គលិកសុខាភិបាល ដោយមានឧទាហរណ៍កាលពីយុវជនចុះទៅវាស់ដី នៅពេលនោះពស់ចិកប្រជាពលរដ្ឋតែបុគ្គលិកសុខាភិបាលមិនបានចាក់ថ្នាំឱ្យទេ ដោយយកលេសថាថ្នាំអស់នេះទុកសំរាប់តែពួកយុវជន ដោយបណ្តោយទុកចោលឱ្យអ្នករងគ្រោះស្លាប់ដោយចុកចាប់នឹងជាតិពិសពស់នោះ។ គ្រោះថ្នាក់កាលពីថ្ងៃទី២៦ ឧសភា នៅក្រុងបាវិតដែលបណ្តាលដោយរថយន្តក្រុងដឹកឥវ៉ាន់រត់ពន្ធរបស់ក្រុមហ៊ុនយួនមួយបណ្តាលឱ្យមានអ្នករងគ្រោះបាត់បង់ជីវិតជាច្រើននាក់ និងរបួសធ្ងន់ជាច្រើន។

ហេតុនេះសូមរាជរដ្ឋាភិបាលមេត្តាបន្ថែមក្នុងច្បាប់នេះ ឬដាក់ក្នុងសារាចរអនុវត្តច្បាប់ថា គ្រោះថ្នាក់ដែលលើកពីលើនេះ គឺជាគ្រោះមហន្តរាយផងដែរ ។

បើតាមវាក្យខ័ណ្ឌទី១ នៃមាត្រា៣៥ ជំពូកទី៦ ស្តីពីសិទ្ធ និងកាតព្វកិច្ចចែងថា "បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការការពារជីវិតសេចក្តីថ្លៃថ្នូរ ទ្រព្យសម្បត្តិ និងជំនួយសង្គ្រោះនៅក្នុងពេលមានគ្រោះមហន្តរាយ។ "ហេតុនេះក្រសួងមានសមត្ថកិច្ច និងអង្គការផ្សេងៗ ដូចជាអង្គការកាកបាទក្រហមជាដើមត្រូវគោរពមាត្រា៣៥ នេះឱ្យបានច្បាស់លាស់ ពីព្រោះនៅអតីតកាលថ្មីៗមានឧទាហរណ៍ដោយមន្ត្រីសមត្ថកិច្ចគ្រប់គ្រងគ្រោះមហន្តរាយមានការខ្វះការទទួលខុសត្រូវចំពោះភារកិច្ច ឬការបំពេញភារកិច្ចដោយមិនត្រឹមត្រូវក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយបង្កឱ្យមានការខូចខាតដល់ទ្រព្យសម្បត្តិឯកជនហើយខ្លះដល់ជីវិតអ្នករងគ្រោះទៅទៀត ។

ចំពោះអង្គការកាកបាទក្រហម បើតាមគោលសីលធម៌របស់អង្គការគេជួយមនុស្សទាំងអស់ដែលទទួលរងគ្រោះមហន្តរាយគ្រប់ៗគ្នា ។ហើយគង់តែនៅពេលចំបាំងក៏ដោយ ក៏អង្គការកាកបាទក្រហមនេះជួយព្យាបាលរបួសដល់យុទ្ធជននៃបដិបក្សដោយមិនរើសអើង ។

តែចំឡែកអង្គការកាកបាទក្រហមខ្មែរមានការរើសអើងក្នុងការជួយដល់ប្រជាពលរដ្ឋដែលគ្នាទទួលរងគ្រោះមហន្តរាយគ្រប់បែបយ៉ាង ។ បើប្រសិនជាអ្នកទទួលរងគ្រោះមិនមែនជាអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជាទេ អ្នកទទួលរងគ្រោះនោះច្បាស់ជាមិនបានទទួលជំនួយពីអង្គការកាកបាទក្រហមខ្មែរទេ ។

ខ្ញុំសូមលើកឧទាហរណ៍ និងការពិចារណាផ្សេងទៀតស្តីវាក្យខ័ណ្ឌទី១ នៃមាត្រា៣៥ ជំពូកទី៦ ស្តីពីសិទ្ធ និងកាតព្វកិច្ចនេះ ។ កាលពីឆេះផ្សារកំពង់ធំ ដែលជាមណ្ឌលរបស់ខ្ញុំបាទ អ្នករងគ្រោះបាននិយាយថា នៅពេលភ្លើងកំពុងឆេះផ្សារ ហើយតូបគាត់ភ្លើងមិនទាន់ឆេះទេ ។ មន្ត្រីសមត្ថកិច្ចគ្រប់គ្រងអគ្គីភ័យបានតថ្លៃជាមួយអ្នករងគ្រោះដោយទា៥០.០០០រៀល តែគាត់មានតែ៤០.០០០ រៀលនៅក្នុងហោប៉ៅ ហើយគាត់សុំតែប៉ុណ្ណឹងសិន ហើយចាំគិតគ្នាតាមក្រោយទៅទៀត ។តែមន្ត្រីសមត្ថកិច្ចមិនព្រមស្តាប់ ក៏ទុកបណ្តោយឱ្យភ្លើងឆេះតូបនោះអស់។ ឧទាហរណ៍របៀបនេះមានជាច្រើនគ្រប់ទីកន្លែងគង់តែកណ្តាលទីក្រុងភ្នំពេញក៏មានដែរ ។ ខ្ញុំសូមលើកឧទាហរណ៍មួយទៀត ពីភ្លើងឆេះផ្ទះប្រជាពលរដ្ឋនៅជិតពេទ្យព្រះកុសមៈដែលគេហៅថាពេទ្យលោកសង្ឃ ។ ឡានទឹកជាច្រើនគ្រឿងចតចាំការពារផ្ទះអ្នកកំប្លែងម្នាក់ដែលគេហៅថានាយកុយ ហើយឈរមើលភ្លើងឆេះផ្ទះប្រជាពលរដ្ឋឯទៀត ។ ហេតុនេះ ពួកមន្ត្រីសមត្ថកិច្ចគ្រប់គ្រងអគ្គីភ័យអស់នេះ ជាជនឧក្រិត ត្រូវតែផ្តន្ទាទោសឱ្យធ្ងន់ដូចជាជនឧក្រិតដែរ ។

ឯចំណែកពួកជួយសង្គ្រោះបន្ទាន់ក៏យ៉ាងដូច្នេះនៅពេលគ្រោះថ្នាក់ចរាចរម្តងៗ ឃើញតែពួកអស់នេះ ឈរតថ្លៃសង្គ្រោះបន្ទាន់ជាមួយគ្រួសាររងគ្រោះជាជាងមើលថែទាំអ្នកទទួលរងគ្រោះ ។ ហេតុនេះសូមរាជរដ្ឋាភិបាលមេត្តាដាក់ក្នុងសារាចរអនុវត្តច្បាប់ពីតម្លៃជួយសង្គ្រោះបន្ទាន់ឱ្យក្រុមហ៊ុនសង្គ្រោះបន្ទាន់អនុវត្តដោយមិនចាំបាច់តថ្លៃ ដូចជាអមនុស្សធម៌ពេក ។ ហេតុនេះ ពួកសង្គ្រោះបន្ទាន់ដែលមានភារៈកិច្ចក្នុងការជួយសង្គ្រោះត្រូវតែបំពេញភារៈកិច្ចរបស់ខ្លួនដែលច្បាប់តំរូវ និងការគោរពល័ក្ខខ័ណ្ឌអាជីព ។

ឯចំណែកមន្ទីពេទ្យក៏ដោយពេលអ្នកជម្ងឺមកដល់ក្រុមពេទ្យមិនដែលសួរពីជម្ងឺអ្វីទេ សំនួរដំបូង តើមានលុយ ឬអត់បើអត់គឺមិនព្រមមើលទេ ហើយទុកឱ្យស្លាប់ដោយអមនុស្សធម៌ ដូចជាមានករណីជាច្រើនស្ត្រីដែលមានផ្ទៃពោះប្រុងនឹងឆ្លងទន្លេជាដើម។ បើប្រៀបធៀបទៅនឹងប្រទេសជិតខាង ដូចជា យួន និងសៀម គឺក្រុមពេទ្យគេមើលជម្ងឺសិនបានគេសួរលុយតាមក្រោយ ។

ឧទាហរណ៍ទាំងអស់នេះយើងអាចសន្និដ្ឋានថា ពួកដែលមានភារកិច្ច និងកាតព្វកិច្ចជួយសង្គ្រោះអ្នករងគ្រោះទាំងអស់ដោយខ្វះខាតក្នុងការទទួលខុសត្រូវចំពោះភារកិច្ច ឬមិនបានបំពេញភារកិច្ចដោយត្រឹមត្រូវ គឺជាជនឧក្រិដ្ឋត្រូវតែផ្តន្ទាទោសឱ្យធ្ងន់ដូចជាជនឧក្រិដ្ឋដែរ ។

**តទៅទំព័រទី ២៨**

**KhmerPost USA, LLC**
**សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក**
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us
តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA
**ផ្សាយពាណិជ្ជកម្ម Advertising**
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us
**អ្នកនិពន្ធ Editorials**
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us

អ្នកនិពន្ធកិត្តិយស **Contributed Writers:**
Kim Phien, Richard Howe,Jr.

**ច្នៃសោភ័ណភាពកាសែត Design Artist**
Heng Chhunleng
នាយករដ្ឋបាល Office Manager **978-677-7163**
Thach Vanna ថាច់ វណ្ណា

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at 100.00 or 120 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

# ទូលព្រះបង្គំមិនហ៊ានរាយការណ៍ទេ ទាន ! (តពីភាគ៣)

**ដោយៈ បញ្ញ សីលា តពីលេខមុន**

យើងខ្ញុំត្រូវបង្ខំឱ្យបង់ថ្លៃស្នាក់នៅនឹងចំណី អាហារយ៉ាងធ្ងន់ធ្ងរហួសកម្រិត ហើយទទួល បានចំណីអាហារព្រមទាំងសេវាកម្មយ៉ាងទាប ទាបជាងនៅសណ្ឋាគារគ្មានផ្កាយនៅឯឋានក្រោម ទៀត ហើយកម្រិតតម្លៃឡើងរាល់ឆ្នាំយ៉ាងលឿន ជាងសរព្រហ្មមាសថ្លៃងទៅកាន់នគរយ័ត្សទៅ ទៀតយើង ខ្ញុំទ្រាំលែងបានតទៅទៀតហើយ ទាន!...”។

...ទូលព្រះបង្គំយើងខ្ញុំមិនអាចបន្តការស្នាក់ នៅនឹងបង់ថ្លៃសេវាកម្មផ្សេងៗបានទៀតទេទាន, ព្រោះក៏វិតតម្លៃឆ្នាំនេះឡើងជាងពីឆ្នាំមុនទ្វេជា១០-២០ដងឯណោះ។ រកបានបន្តិចបន្តួចនៅឯឋាន ក្រោមមកដល់ឋាននាយត្រូវបង់សេវាកម្មដឹក ជញ្ជូនតាមតម្លៃម៉ាក្បៀណូរសឹងដាច់ខ្យល់ស្លាប់ ទៅហើយ មកជួបនឹងតម្លៃទ្វេគុណជាច្រើនដង រាប់មិនឈ្នះនៅឋាននេះទៀតទូលព្រះបង្គំយើងខ្ញុំ ត្រឡប់ទៅផែនដីវិញបានស្អីច្រះច្រំលក់កេរអាករ ទាំងអស់សងបំណុលគេសឹងមិនរួចរកផ្ទះនៅមិន បានប្រពន្ធកូនចៅមុខតែត្រូវជ្រកនៅតាមសំយាប ផ្ទះគេមិនខាន...”។ សម្លេងតបវិញហាក់ដូចមាន សេចក្តីក្រោធលាយឡំធ្វើឱ្យយើងដឹងថានោះជា



វាចារតបរបស់ទេពអគ្គលេខាៈ“អវសោឯងជា នរណា? អ្នកណាហៅឱ្យមក? ហេតុអីទើបត្រូវ មកឋានយើងនេះ?...”។ សម្លេងតបវិញហាក់ដូច បាក់អំនួតអស់រលីងៈ“សូមព្រះអង្គមេត្តាសន្តោស ប្រោសប្រណីទូលបង្គំជាអនុរក្សថៃរក្សាផែនដី គោកធ្លោកនគរសុវណ្ណភូមិ ទូលបង្គំមកទីនេះ ដោយបំណងផ្ទាល់ខ្លួនតែប៉ុណ្ណោះ គឺទូលបង្គំសុំ យកដង្វាយមកថ្វាយព្រះអង្គពេលមកដល់ភ្លាម នោះ ព្រះអង្គបានទទួលរួចមកហើយផងដែរ គឺ ទូលបង្គំសុំព្រះអង្គមេត្តាជួយបញ្ចៀសគ្រោះភ័យ ដែលនឹងកើតមានឡើងនៅដំណាច់ឆ្នាំនេះ គឺទូល បង្គំមកគឹតគូរជាមួយព្រះអង្គឱ្យបានមុនកុំឱ្យខក ការ សូមទានជ្រាប!”។ ព្រះទេពអគ្គលេខាបន្ត ទៅទៀតៈ “បើដឹងខ្លួនថា ត្រូវមកពឹងពាក់ឱ្យ យើងជួយម្តេចក៏សំដីធ្លោះៗម្លេះ? ត្រូវដឹងថា យើង មិនបានពឹងឱ្យអ្នករាល់គ្នាមកជួបយើងទេ! យើង គ្មានឱ្យអ្នករាល់គ្នាយកដង្វាយមកថ្វាយនាំយើង ឱ្យក្លាយជាដំណាងទេព្តាពុករលួយអយុត្តិធមិខូច សីលធមិក្រិត្យក្រមនៃលោកដ៏ជាទិអរិយ៏ស្ងប់ សុខនេះឡើយ! តើអ្នករាល់គ្នាបានដឹងខ្លួនថា បាន ប្រព្រឹតរំលោភបំពាននូវគតិច្បាប់ទីនេះយ៉ាងធ្ងន់ ធ្ងរដែលមិនអាចអត់ឱនឱ្យបានេះឬទេ? បើអ្នក រាល់គ្នាទ្រាំមិនបាននឹងសេវាកម្មផ្សេងៗនៅទីនេះ ទេ អ្នករាល់គ្នាអាចត្រឡប់ទៅផែនដីគោកធ្លោក សុវណ្ណភូមិវិញដោយសិរីគ្មាននរណាហាមឃាត់ អ្នកទាំងអស់គ្នាទេ រួចចាំដល់ពេលព្រះសក្កទេវ រាជត្រូវការកោះហៅអ្នករាល់គ្នាយើងនឹងចាត់ ចែងរាជរថទៅដឹកជញ្ជូនអ្នកគ្រប់គ្នាដោយឥតគិត ថ្លៃ-ហ្វ្រី អហ្វ ឆាគ!-ដែរ អ្នករាល់គ្នាយល់ ឬនៅ?។ ចូរកុំចង់មកលេងល្បែងអុកឡុកធ្វើ បាតុកម្មឬពហិការបំផ្លាញសេចក្តីសុខស្ងប់នាឋាន ដ៏ប្រសើរនេះតាមវិធីពួអ្នកមានអំណាចនៅនាភព ផែនដីគាំទ្រដោយរដ្ឋាភិបាលធ្វើបាតុកម្មប្រឆាំង នឹងបាតុកម្មត្រឹមត្រូវរបស់អ្នកក្រីក្រគ្នាធ្វើឡើង ដើម្បីសុំតែរស់មួយចំអែតសុំទាមទារដីកេរកម្ម សិទ្ធិដែលគ្នាត្រូវគេរឹបអូសប្លន់យកទាំងកំរោល នោះឱ្យសងមកគ្នាវិញ ពួកអ្នកមានទ្រព្យមាន អំណាចបានធ្វើបាតុកម្មប្រឆាំង ដោយចោទប្រកាន់ ថាគ្នាបានចូលរុករានដីទឹកខ្លួនដោយអាងខ្លួនឯង មានបង្កាន់ដៃ ឬប្លង់កម្មសិទ្ធស្របច្បាប់មក តែពី ខ្លួនមានលុយមានអំណាច រួចក៏ចាប់គ្នាវាយដំដាក់ ខ្នោះច្រកគុកស្រេចតែចិត្តគ្មានត្រាបណី។ ចូរកុំ ចង់លេងល្បែងពាលយ៉ាងនោះនៅទីនេះជាមួយ ទេពនិករឱ្យសោះ។ **តទៅទំព័រទី៣១**

LOWELL ELDER CARE
978-596-1111
# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល
345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com

**អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?**
គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង៍ គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

**ទីតាំងនៃមណ្ឌល**
ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





**មណ្ឌលផ្តល់សេវាដល់មនុស្សចាស់**
- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

**Our Services**
- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

**សូមហៅលេខទូរស័ព្ទ (978) 596-1111**

តមកទំព័រទី ០៩

## ផ្លូវថ្មើជើងថ្មីៗទៀតនៅឡូវែល...

ចាប់យកជីវភាពអ្នកក្រុងនឹងទីកន្លែងដូចជាកណ្តាលក្រុងឡូវែលមកធ្វើជាជីវិតថ្មី។ ឧបករណ៍ដ៏សំខាន់មួយនៃជីវភាពក្រុងថ្មីនោះ គឺលទ្ធភាពមកធ្វើការអាចជិះកង់បាន ឬក៏អាចជិះរថយន្តក្រុងជំនួសការបើកបររថយន្តឯកជនផ្ទាល់ខ្លួនទៅគ្រប់កន្លែង។

ការដែលសាលាក្រុងឡូវែលប្រឈមមុខនឹងឧបស័គ្គដ៏ធំបំផុតមួយនោះគឺ តើត្រូវគូសគ្រោងកែផ្លូវចាស់ដ៏កំព្រួកពីអតីតកាលនោះរបៀបណា? វានឹងត្រូវចំណាយលុយធំណាស់ ដើម្បីកែទាំងមូលឱ្យបាននោះ គេត្រូវតែកែហើយធ្វើឱ្យបានស្រួលនឹងមានសុវត្ថិភាពសម្រាប់អ្នកដើរនឹងសម្រាប់អ្នកជិះកង់។ ការទាំងនេះមានសារសំខាន់ ជាពិសេសនៅតាម សំសុង កុណិចត័រ ពីព្រោះមានផ្លូវដែលរួមតូច

One of the biggest challenges facing the city of Lowell in 2015 is how to undo the poorly designed roadways from the past. It is too expensive to do them over entirely, so they must be modified to make them easier and safer for use by walkers and bicyclists.

This is especially important along the Sampson Connector because that is a stretch of roadway filled with important and interesting places. Starting at the Pollard Memorial Library on Merrimack Street and heading south towards the Lowell Connector, there is the Smith Baker Center, the National Park Visitor Center, the Arts League of Lowell Gallery, the Whistler House Museum of Art, the Quilt Museum, The American Textile History Museum, Mill No. 5, the Hamilton Canal District, Western Avenue Studios, Pailin Plaza, the Asian-owned restaurants and stores on Chelmsford Street, the South Common, and the Gallagher Train and Bus Terminal.

These are all great places that make Lowell and interesting place to live, but because the existing roads are not safe or convenient for pedestrians, these places are isolated from visitors and from each other. There is no easy solution to this problem but that should not stop city government and the people of Lowell for trying to make this area safer and easier for walking. It would be a great boost to the city's economy and would make Lowell a better place to live.




Continued from page 16

## EU Commits More Than...

of commune and national elections," said Mr. Puthea, a former election observer who now sits on the NEC.

Mr. Puthea said the E.U. is providing the money specifically for the creation of a new digital voter registry that will include the collection of biometric data through fingerprints and photographs.

"The 10 million euros will cover research, the sending of election observers and also election materials for voter registration, such as computers, generators, webcams, fingerprint scanning and the installation of big servers at the [NEC's] Phnom Penh computer center," he explained.

"This financial help will mean a lot for elections in Cambodia, and make the voters feel more confident [in the 2017 and 2018 elections] and help to gain people's trust."

Mr. Cautain, the E.U. ambassador, said in an email that Monday's meeting was "fruitful" and that a final decision on funding would be made in the coming months.

"The E.U. explained that 10 million euro had been earmarked to support the Electoral process in Cambodia. The final decision on this funding should be taken by the E.U. in October 2015 with tentatively a start of implementation in January 2016," he said.

Continued from page 05

## A More Walkable...

the Whistler House Museum of Art, the Quilt Museum, The American Textile History Museum, Mill No. 5, the Hamilton Canal District, Western Avenue Studios, Pailin Plaza, the Asian-owned restaurants and stores on Chelmsford Street, the South Common, and the Gallagher Train and Bus Terminal.

These are all great places that make Lowell and interesting place to live, but because the existing roads are not safe or convenient for pedestrians, these places are isolated from visitors and from each other. There is no easy solution to this problem but that should not stop city government and the people of Lowell for trying to make this area safer and easier for walking. It would be a great boost to the city's economy and would make Lowell a better place to live.

តមកទំព័រទី ១៦

## សហភាពអឺរ៉ុបសន្យាផ្តល់មូលនិធិប្រហែល...

ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបកាលពីម្សិលមិញបានជួបប្រជុំជាមួយ គ.ជ.ប. ដែលធ្វើជាប្រធានដោយលោក ស៊ិក ប៊ុនហុក អតីតសមាជិកសភាគណបក្សប្រជាជនកម្ពុជា ហើយបានប្រកាសថា សភាសហភាពអឺរ៉ុបនឹងផ្តល់មូលនិធិចំនួន១០លានអឺរ៉ូ(ប្រហែល១១.៣លានដុល្លារ)ដល់គ.ជ.ប. នៅចុងឆ្នាំនេះ។

លោក ហង្ស ពុទ្ធា អតីតអ្នកសង្កេតការណ៍បោះឆ្នោតដែលឥឡូវនេះជាសមាជិក គ.ជ.ប. បានមានប្រសាសន៍ថា "សហភាពអឺរ៉ុបបានបង្ហាញថាខ្លួននឹងជួយផ្តល់ថវិកា១០លានអឺរ៉ូមានប្រសិទ្ធភាពចាប់ពីខែមករាឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ សម្រាប់រយៈពេលនៃការបោះឆ្នោតឃុំ-សង្កាត់ និងការបោះឆ្នោតជាតិ"។

លោក ហង្ស ពុទ្ធា បានមានប្រសាសន៍ថា សហភាពអឺរ៉ុបបានផ្តល់មូលនិធិជាពិសេសសម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោតថ្មីតាមប្រព័ន្ធឌីជីថលដែលនឹងរួមមានការប្រមូលទិន្នន័យជីវមាត្រតាមរយៈក្រយៅដៃនិងរូបថតជាដើម។

លោកបានពន្យល់ថា "ទឹកប្រាក់១០លានអឺរ៉ូនឹងគ្របដណ្តប់ការស្រាវជ្រាវការបញ្ជូនក្រុមអ្នកសង្កេតការណ៍បោះឆ្នោត និងសម្ភារបោះឆ្នោតសម្រាប់ការចុះឈ្មោះបោះឆ្នោតផងដែរ ដូចជាកុំព្យូទ័រ ម៉ាស៊ីនភ្លើង វិបខេម ការស្កេនក្រយៅដៃ និងការដំឡើងស៊ើវើ (server) ធំនៅមជ្ឈមណ្ឌលកុំព្យូទ័រនៅភ្នំពេញរបស់ គ.ជ.ប."។

លោកបានបន្ថែមថា "ជំនួយហិរញ្ញវត្ថុនេះនឹងជួយដល់ការបោះឆ្នោតបានច្រើនក្នុងប្រទេសកម្ពុជា និងធ្វើឱ្យអ្នកបោះឆ្នោតកាន់តែមានទំនុកចិត្តក្នុងការបោះឆ្នោតនៅឆ្នាំ២០១៧ និងឆ្នាំ២០១៨ ហើយនឹងជួយឱ្យប្រជាជនទទួលបានទំនុកចិត្ត"។

លោក កូតាំង ជាឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបបានលើកឡើងនៅក្នុងអ៊ីម៉ែលថា កិច្ចប្រជុំកាលពីម្សិលមិញនេះប្រកបដោយ "ផ្លែផ្កា" ហើយថា សេចក្តីសម្រេចចុងក្រោយស្តីពីការផ្តល់មូលនិធិនេះនឹងធ្វើឡើងនៅក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ។

លោកបានមានប្រសាសន៍ថា "សហភាពអឺរ៉ុបបានពន្យល់ថា ទឹកប្រាក់១០លានអឺរ៉ូនេះសម្រាប់គាំទ្រដល់ដំណើរការបោះឆ្នោតក្នុងប្រទេសកម្ពុជា។ សេចក្តីសម្រេចចុងក្រោយស្តីពីការផ្តល់មូលនិធិនេះត្រូវបានចាត់ចែងដោយសហភាពអឺរ៉ុបនៅខែតុលា ឆ្នាំ២០១៥ ជាមួយនឹងការចាប់ផ្តើមអនុវត្តនៅខែមករា ឆ្នាំ២០១៦"៕

**សារុន**

# ព័ត៌មានសំខាន់អន្តរជាតិ និងទាន់សភាពការណ៍

## អនុសាសន៍របស់ថ្នាំថ្មី កូលេស្តេរ៉ូ (Cholesterol)

**រៀបរៀងដោយ: បុគ្គលិកស្ម័គ្រចិត្ត KO**
**ដកស្រង់ចេញពីកាសែតញូយ៉កខ្មែម (New York Time)**
**"ជាតិខ្លាញ់ក្នុងឈាម" យល់ព្រម**
**និងចេញប្រើបាស្រ់ជាផ្លូវការ ។**
**ថ្ងៃអង្គារទី៩ មិថុនា ឆ្នាំ២០១៥**

**សំលេងឆ្នោះដែលមាន:** ១៣គាំទ្រទល់ និង៣ប្រឆ្នាំងក្រុមអ្នកឯកទេសបានលើសំណើរសុំឱ្យនាយកដ្ឋានថ្នាំ និងម្ហូបអាហាររបស់សហរដ្ឋអារិក (Food & Drug Administration) ធ្វើការយល់ព្រមដើម្បីចេញអោយប្រើបាស្រ់ជាផ្លូវការនៃថ្នាំកូលេស្តេរ៉ូ "ជាតិខ្លាញ់ក្នុងឈាម"ថ្មីនេះ ។ សូមបញ្ចប់ថា ថ្នាំកូលេស្តេរ៉ូ (Cholesterol)គឺ ជាថ្នាំដែលមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការការពារជំងឺគាំងបេះដូង (heart attack) ដែលគេយល់ថា វាជាជំងឺមួយសំលាប់មនុស្សច្រើនជាងគេបង្អស់លេខមួយក្នុងសហរដ្ឋអាមេរិកយើងនេះ។ ជំងឺគាំងបេះដូងនេះកើតមានឡើងនៅពេលដែលចរាចរនៃអុកស៊ីសែនក្នុងសរសៃឈាមឈប់ធ្វើចលនារបស់ខ្លួននៅកន្លែងសាច់ដុំរបស់បេះដូង។ ប្រសិនបើសាច់ដុំរបស់បេះដូងអត់មិនបានទទួលអុកស៊ីសែននោះទេ វាធ្វើអោយសាច់ដុំនៃបេះដូងនេះចាប់ផ្តើមស្លាប់ដែលជាមូលហេតុធ្វើអោយមានជំងឺគាំបេះដូង។

ប្រសិនបើនាយកដ្ឋានឱសថ និងម្ហូបអាហារនៃសហរដ្ឋអាមេរិកសំរេចអនុម័តឱ្យឱសថនេះ ចេញប្រើបាស្រ់ជាផ្លូវបានមាននោះវាជាលើកទី១ហើយចំពោះឱសថថ្មីស្រឡាងនេះ ដែលស្ថិតនៅក្នុងចំណោមឱសថផ្សេងៗទៀតដែលមានចំណាត់ថ្នាក់ខ្ពស់ដូចគ្នានេះបានចេញឱ្យប្រើបាស្រ់ជាផ្លូវការ និងសាធារណៈ។ ឱសថថ្មីស្រឡាងនេះមានសក្តានុពលខ្លាំងណាស់ក្នុងការកាត់បន្ថយនូវកំរិតនៃជាតិខ្លាញ់នៅក្នុងឈាមរបស់មនុស្សយើង។ ដូចជាយើងដឹងហើយថា: បើយើងមានកូលេស្តេរ៉ូ (Cholesterol) ច្រើនកាលណា វានឹងអាច

## ឃាតករប្រកាន់ពូជសាសន៍បានបាញ់សំលាប់មនុស្សនៅទីក្រុង ឆាឡឺស្តុន (Charleston) នៃរដ្ឋ សៅ ការូឡាណា (South Carolina)

**ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៥**

នាថ្ងៃសុក្រនេះក្នុងតុលាការសមាជិកក្រុមគ្រួសារនៃជនរងគ្រោះបានសំដែងនូវមនោសញ្ចេតនាពិតរបស់ពួកគេចំពោះឃាតករដៃឆៅជនជាតិស្បែកសរ និងមានសក់ទងដែងដែលបានបាញ់សំលាប់មនុស្ស៩នាក់សុទ្ធតែជនជាតិស្បែកខ្មៅដែល ពួកគេកំពុងតែសិក្សាគម្ពីរនៃគ្រិស្តសាសនានៅក្នុងព្រះវិហារ ជនជាតិអាហ្វ្រិកកាន់សាសនាគ្រិស្តប្រូតេស្តង់ (Emanuel African Methodist Episcopal Church)នៅទីក្រុង ឆាឡឺស្តុន (Charleston) នៃរដ្ឋ សៅ ការូឡាណា (South Carolina)។ ជនជាតិស្បែកខ្មៅ៩នាក់ ដែលបានស្លាប់នោះក្នុងចំណោមអ្នកស្លាប់នោះមានចៅអធិការព្រះវិហារគ្រិស្តសាសនា និងជាសមាជិកព្រឹទ្ធភាពនៃរដ្ឋ សៅ ការូឡាណា ឈ្មោះ ឃ្លឹមនតេ ផឹន្គនី (Reverend and State Senator Clementa Pinckney)។ ការបញ្ចេញនូវមនោសញ្ចេនានេះគ្រប់ដណ្តប់ ទៅដោយភាពសោកស្តាយនឹងការយំនិងបង្ហូរទឹកភ្នែកយ៉ាងសម្ដោសម្ដៅរបស់សមាជិកក្រុមគ្រួសារនៃជនរងគ្រោះ។ ទន្ទឹងនឹងនេះដែលសមាជិកក្រុមគ្រួសារនៃជនរងគ្រោះក៏បានផ្តល់នូវការអភ័យទោសដល់ឃាដកររូបនេះ ប៉ុន្តែពួកគេសង្ឃឹមថា ឃាតកររូបនេះគួរតែសារភាព និងមានវិប្បដិសារីអំពីឃាដកម្មរបស់ខ្លួន។ ពួកគេក៏សង្ឃឹមថា ច្បាប់នឹងតុលាការនឹងសំរេចចំពោះឃាតកម្មដ៏ឃោឃៅរបស់ឃាដកររូបនេះ។



ដាយឡែនរូហ្វ



កាន់ទុក្ខនៅវិហារប្រតេស្តង់នៅឆាលេសស្តុន

លោកស្រី ហ្វិលីសៀ សានដើស្ស (Felicia Sanders) ដែលជាម្តាយរបស់ជនរងគ្រោះម្នាក់ឈ្មោះ តៃវ៉ានសា សានដើស្ស (Tywanza Sanders) បាននិយាយទៅកាន់ឃាដករ ឌីឡាន ស្តូម រូហ្វ (Dylann Storm Roof) ផ្ទាល់។ លោកស្រីបានមានប្រសាសន៍ថា: "ពួកយើងសូមស្វាមគន៍អ្នកយ៉ាងពេញទំហឹងមកចូលរួមជាមួយក្រុមសិក្សាគម្ពីររបស់យើងរៀងរាល់យប់ថ្ងៃពុធ"។ លោកស្រីបានមានប្រសាសន៍បន្តទៀតថា:"អ្នកឯងបានសំម្លាប់មនុស្សស្អាតស្អំបំផុតមួយចំនួនដែលខ្ញុំបានស្គាល់ពួកគេ"។ លោកស្រីបានបន្តទៀតថា: "រៀងរាល់ភាពរឹងប៉ឹង (ចរិត) នៅក្នុងខ្លួនរបស់ខ្ញុំបានបាត់បង់អស់ហើយ ខ្ញុំនឹងមិនអាចដូចជាខ្ញុំពីមុនបាននោះទៀតទេ (Every fiber in my body hurts, and I'll never be the same…)" ។

សូមបញ្ជាក់ថា:លោកស្រីគឺជាមនុស្សម្នាក់ដែរនៅក្នុងបន្ទប់សិក្សាគម្ពីរនោះដែរ នៅពេលដែលឃាតកររូបនេះបានបាញ់រះសម្លាប់មនុស្ស៩នាក់ មូលហេតុដែលលោកស្រីបានរស់មានជីវិត នោះដោយសារតែលោកស្រីធ្វើពុតជាស្លាប់។

លើកក្រោយ ខ្ញុំសូមធ្វើការអធិប្បាយអំពីប្រវត្តិសាស្ត្រនៃចលនាសិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូរ និងសេរីភាពនៃមនុស្សជាតិ និងលទ្ធិប្រជាធិបតេយ្យរបស់សហរដ្ឋអាមេរិកយើងនេះបន្តិចបន្តួច:សូមកត់សំគាល់ថាព្រះវិហារជនជាតិអាហ្វ្រិកកាន់សាសនាគ្រីស្តប្រូតេស្តង់ (Emanuel African Methodist Episcopal Church) មានទីតាំងនៅក្នុងទីក្រុង ឆាឡឺស្តុន (Charleston) តាំងពីឆ្នាំ១៨១៦មកម្ល៉េះនៅពេលដែលសមាជិកជនជាតិអាហ្វ្រិកកាន់សាសនាគ្រិស្តប្រូតេស្តង់បានបង្កើតនូវក្រុមជំនុំសាសនារបស់ខ្លួន។ ព្រះវិហាគ្រិស្តសាសនានេះដែលគេហៅថា: "Mother Emanuel" ដែរជាទីស្នាក់ការកណ្តាលរបស់ចលនានៃសកម្មភាពសិទ្ធិមនុស្សរាប់ទសតវ្សកន្លងមក។ ព្រះវិហារគ្រិស្តសាសនានេះក៏ត្រូវបានគេដុតបំផ្លាញម្តងរួចហើយដោយសារតែមានអំពើរីអើមពូជសាសន៍។ អង្គការជនជាតិស្បែសរគ្រិស្តសាសមានឈ្មោះថា គូ គ្លូស្ស គ្លាន (Ku Klux Khan) ហៅកាត់ថា: គ្ខេ គ្ខេ គ្ខេ (គ.គ.គ.) ជាអ្នកទទួលខុសត្រូវនៃការដុតបំផ្លាញនោះ ក៏ប៉ុន្តែព្រះវិហារជនជាតិអាហ្វ្រិកកាន់សាសនាគ្រិស្តប្រូតេស្តង់នេះបានសាងសង់ឡើងវិញក្រោយមក ៕

តមកទំព័រទី ២៩

## ប្រជុំស្តីពីសេចក្តីព្រាងច្បាប់...

ក្នុងមាត្រា៤៥ បានចែងពីករណីនេះ ដែលនឹងផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៦ ខែទៅ ២ ឆ្នាំ និងពិន័យជាប្រាក់ពី១លាន ដល់ ៤ លានរៀល ។ ទោសនេះស្មើនឹងការបំផ្លិចបំផ្លាញការធ្វើឱ្យទ្រុឌទ្រោម និងការធ្វើឱ្យខូចខាតដោយចេតនាតែប៉ុណ្ណោះ គឺក្នុងមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ។ តែនេះមិនមែនប្រជាពលរដ្ឋធម្មតានោះទេ តែជាមន្ត្រីមានសមត្ថកិច្ចដែលមានភារកិច្ចហេតុនេះយើងត្រូវតែផ្តន្ទាទោសឱ្យធ្ងន់ ពីព្រោះការប្រព្រិត្តអំពើឧក្រិដ្ឋអស់នេះ គឺនៅក្រោមការទទួលខុសត្រូវរបស់មន្ត្រីអស់នេះ ។ យ៉ាងដូច្នេះ យ៉ាងស្រាលបំផុត គឺផ្តន្ទាទោសដូចនៅក្នុងមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌនេះ។ គឺដាក់ពន្ធនាគារពី២ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤លាន ដល់១០ លានរៀល ។

នៅក្នុងមាត្រា ៤១១ នេះ ឃើញចំណុចទី ៦ ដែលចែងថា : "កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចបង្គោលព្រំដែនអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា។ "គួឱ្យចំឡែក តាមការយល់ដឹងពីខ្ញុំបាទគ្រប់ប្រទេសក្រោមមេឃលើដីមានតែព្រះរាជាណាចក្រកម្ពុជាមួយទេដែលមានបទល្មើសស្តីអំពីករណីយនេះ ។

នៅថ្ងៃនេះ ពេលនេះនៅតំបន់ទល់ដែន ឃុំកក់ញ៉ៃ ស្រុកអូរយ៉ាដា ខេត្តរតនគិរី មានតំណាងរាស្ត្រជាច្រើនរូបមកពីគណបក្សសង្គ្រោះជាតិដឹកនាំដោយលោកម៉ៅមូលនីវណ្ណតំណាងរាស្ត្រខេត្តកំពង់ចាមដែលមានលោក ជាម ចន្ទនី កងគិមហាក់ អ៊ុំ សំអានព្រឹទ្ធសភាម្នាក់ លោកស្រី ថាក់លានី និងប្រជាពលរដ្ឋជាច្រើនបានចុះទៅទល់ដែនដោយមានទាហ៊ានយួនចូលមករំលោភលើទឹកដីខ្មែរ ។ ហើយខ្ញុំសង្ឃឹមថា ប្រជាពលរដ្ឋទាំងអស់នេះ នឹងមិនទៅធ្វើឱ្យខូចបង្គោលព្រំដែនអាចនឹងទទួលការផ្តន្ទាទោសដូចមាត្រា៤១១នេះទេ ។

តាមមើលត្រង់ចំណុចនេះ គឺចែងដោយមានផ្នត់គំនិតនៅក្រោមអាណានិគមបរទេស ហើយសរសេរក្រោមការក្បៀបសង្កត់បរទេស ។ ហើយច្បាប់ផ្សេងខ្លះទៀតចែងទៅតាមចំណង់របស់មនុស្សខ្លះដោយមិនគិតពីភាពយុត្តធមិ និងទ្រឹស្តីច្បាប់នោះទេ គឺមានគោលបំណងតែម្យ៉ាង គឺដើម្បីរំខានដល់ពួកដែលប្រឆាំងនឹងខ្លួន ។ នៅពេលនេះ ព្រះរាជាណាចក្រកម្ពុជាបានឯករាជ្យពេញលេញតាំងពីថ្ងៃទី ២៣ តុលា ឆ្នាំ១៩៩១ ហេតុនេះរដ្ឋសភាគួរតែស្នើលុបច្បាប់ខ្លះ ឬស្នើវិសោទកម្មច្បាប់ផ្សេងៗឱ្យសមស្របទៅតាមប្រទេសឯករាជ និតិរដ្ឋ និងស្របទៅតាមគំនិតរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

ពីដើមព្រះរាជាណាចក្រកម្ពុជាមានច្រកចេញទៅសមុទ្រអន្តរជាតិបានដោយមិនចាំបាច់សុំអនុញ្ញាតពីប្រទេសជិតខាង ដូចសព្វថ្ងៃនេះទេ ។ ហើយកប៉ាល់ដឹកឥវ៉ាន់មកភ្នំពេញយួនហាមមិនឱ្យដឹកកាត់តាមផែរគេ ចំពោះឥវ៉ាន់ប្រើប្រាស់ហើយនោះ គឺទាល់តែឥវ៉ាន់ថ្មី ។ នេះគឺគេមានបំណងចង់ខ្ទប់សកម្មភាពផែរស្វ័យតភ្នំពេញតែប៉ុណ្ណោះ គង់តែអនុសញ្ញាអន្តរជាតិមានយ៉ាងដូចម្តេចក៏ដោយក៏យួនរំលោភលើខ្មែរដែរ ។

ចំណែកកងកំលាំងខ្មែរដែលយាមតាមព្រំប្រទល់ដែន ដូចជាគោរពបញ្ជាទាហ៊ានយួន បើយ៉ាងដូច្នេះ តើកងកំលាំងខ្មែរអាចការពារផលប្រយោជន៏ជាតិ និងប្រជាពលរដ្ឋនៅតាមប្រទល់ដែនបានឬទេ ? ប្រជាពលរដ្ឋនៅតាមប្រទល់ដែនត្រង់ដែលគេហៅថា តំបន់សរគេហាមមិនឱ្យដាំដំណាំទេ ដោយទាហ៊ានយួនចូលមកដកចោល ល្បិចនេះគឺធ្វើឱ្យប្រជាពលរដ្ឋនៅតាមប្រទល់ដែនរស់នៅមិនកើតហើយរត់ចោលកន្លែងដោយទុកឱ្យទំនេរ ហើយប្រជាពលរដ្ឋយួននឹងមកតាំងទី ។ តំណាងរាស្ត្រខ្លះបានទាមទាឱ្យបង្ហាញជាសាធារណៈផែនទីដែលជាមូលដ្ឋានគូសព្រំប្រទល់ដែនតែ ឯ.ឧ. វ៉ាគិមហុងមិនព្រមទេ។ នេះជាសិទ្ធិប្រជាពលរដ្ឋត្រូវតែដឹងពីផែនទីនេះ។ ហេតុនេះសូមសភាមេត្តាពិចារណាឱ្យបានដិតដល់ពីភាពបាត់បង់បូរណភាពទឹកដីរបស់យើងដែលយើងទាំងអស់គ្នាត្រូវតែការពារ ។

**លិម គិមយ៉ា**
**តំណាងរាស្ត្រមណ្ឌលកំពង់ធំ**
**សមាជិកគណៈកម្មការសេដ្ឋកិច្ចហិរញ្ញវត្ថុធនាគារនិងសវនកម្មនៃរដ្ឋសភា**

The Cambodian-American Biweekly Newspaper

សារព័ត៌មានខ្មែរ-អាមេរិក ចេញពីរសប្តាហ៍ម្តង

a free local newspaper reaching over 20,000 Cambodian readers in the Greater Lowell area every two weeks

ផ្តល់ជូនកាសែតឥតគិតថ្លៃដល់អ្នកអានខ្មែរច្រើនជាង២០០០០នាក់នៅតំបន់ឡូវែលរាល់ពីរសប្តាហ៍ម្តង

Soben Pin, Managing Partner អ្នកគ្រប់គ្រង សុបិន្ត ពិន

978.677.7163 (Office) 978. 656.8141 (Mobile)

សូមកក់ពាណិជ្ជកម្មអ្នកជាមួយយើងខ្ញុំ ហើយទទួលបានការបញ្ចុះតម្លៃ២០%

Reserve Your 2015 Ads with us today and receive up to 20% OFF!

Sample of our affordable pricing បញ្ជីតម្លៃពាណិជ្ជកម្មក្នុងតម្លៃសមរម្យ

| ទំហំទំព័រ<br>Page Size | ប្រវែង<br>Length x Width | 1ខែ<br>1 month<br>10%OFF |
|---|---|---|
| 1/2 page color | (6.5"x10") | $484 |
| 1/4 page color | (6.5"x5") | $264 |
| 1/8 Classify ad | (3.25"x5") | $100 |
| Business Card | | $50 |

Our 2015 Publishing Dates កាលវិភាគបោះពុម្ព

| | |
|---|---|
| July | 10th & 24th |
| August | 7th & 21st |

*all ad materials are due one week prior to publishing date.

រាល់គំរូពាណិជ្ជកម្មត្រូវបញ្ជូន1សប្តាហ៍មុនចូលរោងពុម្ព




## Call or Visit our Sales Office

45 Merrimack Street. Suite 218A. Lowell, MA 01852

Tel: 978.677.7163. Cell: 978. 656.8141 Fax: 978.677.7092

Email: sobenpin@khmerpost.us or KhmerPostUSA@gmail.com

www.khmerpost.us | www.facebook.com/KhmerPostUSA

# CENTURY PHARMACY & OPTICAL

937 Gorham St | ALL MAJOR INSURANCES ACCEPTED | Tel: 978-455-6554

យើងខ្ញុំ
សូមជូនពរ
មហាប្រសើរ
ដល់លោក
អ្នក



នាឱកាស
ចូលឆ្នាំ
មមែ
ព.ស
២៥៥៩

- យើងខ្ញុំមានផ្តល់សេវាបំរើការជូនឱសថដល់ទីលំនៅ ។
- យើងខ្ញុំទទួលកាតម៉ាសហ៊ារ, និងកាតធានារ៉ាប់រង សុខភាពផ្សេងៗទៀត
- សេវាបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
- យកចិត្តទុកដាក់លើបញ្ហាផ្ទល់ខ្លួននៃអតិថិជនរាល់រូប ។
- វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
- មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
- យើងខ្ញុំទទួលការផ្ញើថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។ ជាឱសថស្ថានមួយអាចផ្តល់ភាពជឿជាក់ដល់គ្រួសារអ្នក ។






យើងខ្ញុំនិយាយភាសាខ្មែរ ។

**លេខទូរស័ព្ទ 978-455-6554**

**លេខហ្វាក់ 978-455-9476**

## 937 Gorham St Lowell, MA, 01852

# របៀបផាត់មុខ តាមរបៀបធម្មជាតិ



បច្ចេកទេសតុបតែងមុខបែបងាយៗ និងមើលទៅដូចធម្មជាតិនេះ ក្រៅពីជួយឱ្យសម្រស់ស្រស់ស្អាតទ្វេរដង ហើយវាថែមទាំងអាចជួយបិទបាំងស្នាមជ្រីវជ្រួញរបស់អ្នកបានទៀតផង។ ចាប់ផ្ដើមតរៀមស្បែកមុនពេលតុបតែងផ្ទៃមុខដោយលាបឡេធ្វើឱ្យស្បែកមានសំនើមស្ដើងៗឱ្យសព្វផ្ទៃមុខ។ អ្នកអាចប្រើដៃឬអេប៉ុង ក៏បានដើម្បីផាត់ពង្រាបធ្វើឱ្យមើលទៅស្បែកមានភាពរាបស្មើរលោងល្អ និងជួយឱ្យគ្រឿងសម្អាងជាប់បានយូរ។

បន្ទាប់មកអ្នកត្រូវបន្ថែមម្សៅ ដើម្បីទ្រាប់ផ្ទៃមុខដែលមានពណ៌ប្រហាក់ប្រហែលនឹងស្បែករបស់អ្នក។ អ្នកត្រូវប្រើម្រាមដៃផាត់ ឬជូតឱ្យបានស្អាតគ្រប់ចំនុចលើផ្ទៃមុខ។ រួចអ្នកគួរបន្ថែមខនស៊ីលើនៅក្រោមភ្នែក ដើម្បីបិទបាំងស្នាមជាំ ដោយអ្នកគួរតែជ្រើសយកផលិតផលណាដែលផ្ដល់ជាតិសំនើមខ្ពស់មានលាយផ្សំដោយវីតាមីនដែលអាចជួយការពារស្បែកនៅក្រោមភ្នែក។ ការលាបនៅកន្លែងក្រោមភ្នែកនេះ គេនិយមប្រើពណ៌លឿងដែលមើលទៅមានលក្ខណៈស៊ីគ្នាល្អ។

ជាមួយគ្នានេះដែរប្រសិនបើអ្នកបែកញើសអ្នកគួរប្រើក្រដាស់ផ្ដិតញើស ដើម្បីកុំឱ្យកកម្សៅនៅលើមុខ។ ចំពោះការថែមពណ៌ថ្ពាល់គេនិយមប្រើពណ៌ទឹកក្រូច ឬពណ៌ផ្កាឈូកខ្ចី ឬក៏បន្ថែមពណ៌ចាំងភ្លឺផ្លេកខ្លះកាន់តែល្អ។

ចំណែកឯការពត់រោមភ្នែកវិញ អ្នកត្រូវពត់ដោយប្រុងប្រយ័ត្ន ដើម្បីកុំឱ្យរោមភ្នែកបាក់។ អ្នកត្រូវផាត់រោមភ្នែកទាំងលើទាំងក្រោមដោយផាត់ម៉ាស្ការ៉ា។ ការផាត់រោមភ្នែកចាត់ទុកថា ជាបេះដូងពីព្រោះសំខាន់នៃការតុបតែងមុខរោមភ្នែកនឹងតម្រៀបស្អាតល្អក្រាស់នឹងជួយធ្វើឱ្យភ្នែកមើលទៅកាន់តែមុតភ្លឺថ្លា។ អ្នកអាចប្រើម៉ាស្ការ៉ាសម្រាប់រោមចិញ្ចើមពណ៌ត្នោតមកផាត់ចិញ្ចើមដើម្បីឱ្យមើលទៅទន់ភ្លន់។ ចុងក្រោយគេបង្អស់ គឺជាការលាបបបូរមាត់។ អ្នកត្រូវជ្រើសរើសក្រែមដែលមានវីតាមីនជំនួយស្បែកមាត់ជួយឱ្យស្បែកមាត់មានសំនើម។ ហើយអ្នកត្រូវលាបពណ៌ណាដែលមិនលេខធ្លោរពេក នឹងស្រអាប់ពេកជាការល្អបំផុត៕




តមកពីទំព័រទី ២៦ ទូលបង្គំមិនហ៊ានរាយការណ៍...

យើងព្រមទទួលដង្វាយរបស់អ្នករាល់គ្នាព្រោះយើងមិនអាចដាច់មេត្តាដែលបានឃើញអ្នករាល់គ្នាខំមកពឹងពាក់ហើយៗអត់រវល់អើពើទុកឱ្យអ្នករាល់គ្នាអស់សង្ឃឹមត្រឡប់ក្រោយបែរវាដាច់ព្រហ្មវិហារធម៌ពេក ពួកអ្នករាល់គ្នាបែជាក្មេងក្មាងក្រអើតក្រទម យើងអស់សង្ឃឹមខ្លាំងណាស់ចូរកុំភ្លេចថាយើងគ្មានពឹងឱ្យអ្នករាល់គ្នាធ្វើដំណើរតាមផ្លូវម៉ាក្បេរណ្ឌូរទេ អ្នករាល់គ្នាធ្វើអីៗដោយចិត្តឯងតែប៉ុណ្ណោះ ហេតុនេះយើងគ្មានទទួលខុសត្រូវអ្វីទាំងអស់ ចូរអ្នករាល់គ្នាចុះទៅឋានកណ្ដាលវិញសិនទៅ,ចាំព្រះសក្កទេវរាជត្រូវការកោះហៅចាំយើងឱ្យនាយសារថីទៅនាំខ្លួនចូលមកគាល់ព្រះអង្គ...”។ ស្របគ្នាពេលនោះអ្នកទីពីរមានអាការៈភ័យញ័រចំប្រប់ក្រាបវាន់ទារសុំថ្វាយយោបល់។ ទេពអគ្គលេខាសួរដំណើរដើមទងជននេះក៏បានដឹងថា គេជាទេពតាម្ចាស់ទឹកម្ចាស់ទន្លេព្រែកបឹងបួរនឹងសមុទ្រនៃនគរគោកធ្លោកហើយមិនព្រមត្រឡប់ទៅវិញកើតទេមុននឹងបានទេពអគ្គលេខាសន្យាជួយស្រោចស្រង់ទោសរបស់ខ្លួនចំពោះសក្កទេវរាជ ។ មិនទាន់បានទូលថ្វាយទេពអគ្គលេខាថាម៉េចនៅឡើយផងស្រាប់តែមានអតិថិជនមួយក្រុមទៀតដង្ហែគ្នាចូលមកដល់ព្រមជាមួយគ្នាតែម្ដង។ ទេពអគ្គលេខាហាក់ ឆ្ងល់ក្នុងដួងហឫទ័យថាពួកនេះវាចង់បបួលគ្នាបះបោរផ្ដួលរំលំស្ថានទេវលោកហើយទេដឹងសហទេពកញ្ញាឡើងស្លាំងព្រះភ័កឈរនៅស្ងៀមមិនហ៊ានហាព្រះឱសចេញស្ដីដល់មួយម៉ាត់ឡើយ ភាពឆ្នះឆ្នើមរបស់ព្រះនាងរួញបាត់អស់ទៅណារលីងគ្មានសល់។ ឃើញអតិថិជនទាំងអស់ដែលព្រះនាងបានទារយកសេវ៉ាប្រចាំទិវាលើកគ្នាមកព្រមគ្នាយ៉ាងនេះព្រះនាងភ័យខ្លួន ខ្លាចព្រះសក្កទេវរាជជ្រាបពីអំពើប្រមូលមាសពេជ្រកែវកងពីអ្នកទាំងនោះ ព្រះនាងមុខជាត្រូវទទួលទោសឱ្យទៅចាប់កំណើតនៅស្ថានកណ្ដាលមិនអាចគេចផុតបានឡើយ...។ ទោះបីទេពអគ្គលេខាបានស្គាល់អតិថិជនទាំងអស់នោះរួចស្រេចអស់ទៅហើយ ព្រោះម្នាក់ៗសុទ្ធតែបានទៅគាល់ព្រះអង្គម្ដងរួចទៅហើយជាមួយនឹងដង្វាយផ្សេងៗពេលដែលពួកគេមកពីផែនដីសុវណ្ណភូមិដល់ស្ថានទេវលោកភ្លាម។ តែធ្វើហាក់មិនស្គាល់មិនដឹងមិនមានទំនាក់ទំនងអ្វីនឹងគ្នាទាល់តែសោះ ទេពអគ្គលេខាសួរដោយសម្លេងសំឡុតគំរាមធ្វើឱ្យអ្នកចង់មកបង្ករឿងជាមួយព្រះអង្គចុះញ៉មបាក់បបខ្លបខ្លាចមិនហ៊ានហើបមាត់ : ”មើល! អ្នកទាំងអស់គ្នាជាអ្នកណា? ម៉េចក៏ហ៊ានធ្លើមធំ ចូលមកទីនេះគ្មានការអនុញ្ញាតយ៉ាងនេះ? អ្នកទាំងអស់គ្នាដឹងថា មានកម្រិតទម្ងន់ទោសដល់ថ្នាក់ណាទេ? អ្នកទាំងអស់គ្នាចង់ធ្វើអី?

តទៅលេខក្រោយ







# រឿងភ្នំសន្ទុក (នៅខេត្តកំពង់ធំ)

ចាស់ៗដំណាលតៗគ្នាមកថា "កាលពីព្រេងនាយនៅស្រុកសន្ទុក ខេត្តកំពង់ធំ សព្វថ្ងៃនេះ មានស្តេចមួយអង្គទ្រង់មានព្រះអគ្គមហេសី ព្រះរាជបុត្រ ស្រីស្នំក្រមការ សេនាទាហាន និងនាហ្មឺនសព្វមុខមន្ត្រីជាច្រើនស្តេចទ្រង់មានព្រះរាជបញ្ជាឱ្យឆ្ការព្រៃមួយកន្លែងសង់ប្រាសាទព្រះរាជវាំង និងគុក ភូមិប្រាសាទ រហូតមកដល់សព្វថ្ងៃ ។ លុះសង់បានប្រាសាទនោះហើយព្រះរាជាទ្រង់ត្រាស់បង្គាប់ឱ្យឆ្ការព្រៃមួយកន្លែងទៀត ឆៀងខាងជើងខាងលិចប្រាសាទនោះ ធ្វើទីសម្រាប់ស្រីស្នំ មានកំពែងជុំវិញ ទីនោះជាប់មានឈ្មោះថា ភូមិវាំងរហូតមកដល់សព្វថ្ងៃ។

លុះធ្វើព្រះរាជវាំងហើយ ទ្រង់ត្រាស់បង្គាប់ឱ្យកាប់ឆ្ការព្រៃមួយកន្លែងទៀត នៅខាងលិចប្រាសាទ សង់ឃ្លាំងសម្រាប់ដាក់ព្រះរាជទ្រព្យសឹងមានគល់សសរកប់ក្នុងដីដល់សព្វថ្ងៃនេះ ជាភស្តុតាងស្រាប់ទីនោះ ជាប់មានឈ្មោះថា ភូមិសង់ឃ្លាំង តែក្រោយពីនោះ យូរមកគេហៅថា ភូមិតាំងក្រសាំងវិញ ដែលសព្វថ្ងៃរាជការតាំងសាលាស្រុកសន្ទុកនៅទីនោះ ។ តាមរឿងនោះមានដំណាលថា" កាលនោះ ព្រះរាជាបានត្រាស់បង្គាប់ឱ្យធ្វើកន្លែងមួយទៀត នៅខាងលិចឆៀងខាងត្បូង ភូមិតាំងក្រសាំង សម្រាប់ជាលំនៅពួកអ្នកងារចាំបក់ថ្វាយស្តេចទីនោះជាប់មានឈ្មោះថា ភូមិចាំបក់ ដល់សព្វថ្ងៃនេះ ។ នៅខាងលិចឆៀងខាងត្បូងភូមិចាំបក់នោះមានបឹងមួយធំជាទីដែលព្រះរាជាតែងនាំព្រះអគ្គ-មហេសី និងព្រះរាជបុត្រ ព្រះស្នំ ព្រមទាំងរេហ៍ពលទៅក្រសាលសប្បាយដោយការចាប់ត្រី រើសខ្យងដកព្រលិត បេះត្រកួន ជាក្រយាស្ងោយ ។ ថ្ងៃមួយព្រះរាជបុត្រីដែលទ្រង់យាងទៅក្រសាលទីនោះមិនស្រួលព្រះទ័យទ្រង់ព្រះកន្សែងពួកស្រីស្នំក៏ច្រៀងបំពេបីបមថ្នមថ្នាក់បោសអង្អែលទីនោះជាប់មានឈ្មោះថា បឹងបំពេ និងបឹងខ្យង ដល់មកសព្វថ្ងៃនេះ ។ នៅខាងជើងបឹងបំពេនោះ មានភ្នំមួយហៅ ភ្នំធំ ស្រះខ្មៅ ភ្នំពេនជុំ ។ ភ្នំទាំងនេះជាប់គ្នាជាទីដែលព្រះរាជាតែងទ្រង់នាំព្រះអគ្គមហេសីឡើងទៅក្រសាលបេះផ្លែឈើ មានផ្លែស្រគំ ភ្នំភ្លែង ព្រីង ព្រូស ពិល ពៅ បង្គោ សិរមាន់ ជើងចាប និងផ្លែឈើឯទៀតៗជាច្រើនដោយសេចក្តីសប្បាយ ។ ថ្ងៃមួយព្រះរាជាទ្រង់នាំព្រះរាជអគ្គមហេសីព្រមទាំងព្រះរាជបុត្រទៅក្រសាលលើភ្នំនោះ ព្រះរាជបុត្រទ្រង់ប្រឈួនជាខ្លាំងព្រះអង្គគង់នៅលើភ្នំនោះពុំបានទ្រង់ចាត់ឱ្យឆ្ការព្រៃមួយអន្លើធ្វើព្រះពន្លានៅជើងភ្នំ ហើយក៏នាំបណ្តោះព្រះអគ្គមហេសីព្រះរាជបុត្រ និងស្រីស្នំ ព្រមទាំងរេហ៍ពលចុះពីលើភ្នំនោះ តាមផ្លូវជ្រុងខាងលិចមកសំចតឈប់សម្រាកនៅក្នុងព្រៃមួយទីនោះជាប់មានឈ្មោះថា ភូមិបណ្តោះតមក តែសព្វថ្ងៃហៅថាៗ មកថា ភូមិក្រកោះវិញ ។ បន្ទាប់មកព្រះរាជាទ្រង់នាំព្រះរាជបុត្រមកគង់នៅព្រះពន្លា ដែលធ្វើនៅជើងភ្នំនោះ បានទ្រង់រកពេទ្យហ្មមកព្យាបាលព្រះរោគព្រះរាជបុត្រមិនមានធ្វេសប្រហែសសោះ ប៉ុន្តែទោះបីមានឱសថ និងពេទ្យហ្មយ៉ាងពូកែព្យាបាល



យ៉ាងណាក៏ព្រះរោគព្រះរាជបុត្រនោះ នៅតែមិនបានស្រាកស្រាន្តឡើយ រឹតតែប្រឈួនថែមខ្លាំងឡើងៗ ដរាបដល់អស់ព្រះជន្មនៅទីនោះ ។ ព្រះរាជា និងព្រះរាជអគ្គមហេសីទ្រង់ព្រះកន្សែងស្រីស្នំ និងពួកពលទាំងអស់យំសោកគ្រប់គ្នា ។ ព្រះរាជាទ្រង់ចាត់ចែងធ្វើឈាបនកិច្ចជាឱឡារិកនៅទីនោះ ។ ទីជើងភ្នំដែលព្រះរាជាធ្វើព្រះពន្លាថែរក្សាព្រះរោគព្រះរាជបុត្រលុះដល់អស់ព្រះជន្មជាអាសន្ននោះ ជាប់មានឈ្មោះថា ភ្នំអាសន្នមានទុក្ខតមកគេហៅយារៗមកថា ភ្នំសន្ទុក និងភូមិសន្ទុកវិញ មកដល់សព្វថ្ងៃ ។ ក្រោយពេលដែលព្រះរាជានិងព្រះអគ្គមហេសីទ្រង់មានទុក្ខជាទម្ងន់ទ្រង់ចេញព្រះរាជដំណើរចាកទីនោះ ទៅឈប់សុំចតនៅមាត់ស្ទឹងសែន ដើម្បីលំហើយព្រះរាជហឫទ័យរំដោះទុក្ខតែមិនដូច្នោះបែរជារឹតតែកើតទុក្ខផ្ទួនឡើង ។ គ្រានោះ សាមណេរមួយអង្គបាននិមន្តទៅជួបនឹងព្រះរាជានៅទីនោះ ។ លោកបានឃើញព្រះរាជា និងព្រះអគ្គមហេសីសោយទុក្ខជាទម្ងន់ដូច្នោះបានថ្វាយព្រះពរសួរ ព្រះ-រាជាក៏ទ្រង់ថ្លែងសេចក្តីទុក្ខអំពីព្រះរាជបុត្រដែលរំលត់ខន្ធទៅនោះ ។ ទោះបីសាមណេរបានអធិប្បាយពន្យល់ធម៌អាថ៌ល្អិតល្អន់យ៉ាងណាក៏ព្រះរាជា និងអគ្គមហេសីនៅតែមិនបាត់សេចក្តីវិយោគសោកស្តាយឡើយ ។ សាមណេរជ្រាបរឿងនោះ ក៏ថ្វាយព្រះពរថា "បើព្រះអង្គចង់ឃើញព្រះរូបព្រះរាជបុត្ររបស់ព្រះអង្គសូមទ្រង់ឱ្យជាងយកម្សៅ ឬដីមកសូន ធ្វើជាព្រះរូបព្រះរាជបុត្រទុក គ្រាន់ទតលំហែព្រះទ័យរំដោះទុក្ខ"។ ព្រះរាជាបានឮព្រះពុទ្ធដីកាលោកសាមណេរនោះហើយ ក៏មានព្រះរាជហឫទ័យត្រេកអរ ទ្រង់ចាត់ឱ្យជាងធ្វើសំណាកព្រះរូបព្រះរាជបុត្រទុកនៅទីព្រៃមួយ លុះធ្វើព្រះរូបព្រះរាជបុត្ររួចហើយ ព្រះរាជាទ្រង់ទតទ្រង់សព្វព្រះរាជហឫទ័យ ក៏ទ្រង់បានស្រាកស្រាន្តទុក្ខសោកនោះ ដោយសារបានទតសំណាកព្រះរូបព្រះរាជបុត្រជាតំណាង ។ កន្លែងដែលធ្វើព្រះរូបព្រះរាជបុត្រនោះ ជាប់ឈ្មោះថា ភូមិសំណាកមកដល់សព្វថ្ងៃ ។ ក្រោយមកព្រះរាជាទ្រង់បាននាំព្រះរាជអគ្គមហេសីនឹងព្រះស្នំ ព្រមទាំងពួកពលទៅក្រសាលនៅទីមួយខាងជើងទីតម្កល់ព្រះរូបសំណាកនោះ ទ្រង់បានទតឃើញឆ្អឹងក្បាលក្រពើធំមួយដែលស្លាប់យូរហើយ ៕

